# របត់ថ្មី នៃទំនាក់ទំនងកម្ពុជា-ចិន ក្នុងសតវត្សរ៍ទី២១

កម្ពុជានិងចិនមានទំនាក់ទំនងជាមួយគ្នាក្នុងប្រវត្តិសាស្ត្រជាង២ពាន់ឆ្នាំកន្លងមកហើយ ដែលនៅពេលនោះមានរូបភាពច្រើនតែទៅលើទំនាក់ទំនងតាមរយៈការធ្វើជំនួញផ្លូវទឹក ការជ្រាបចូលនៃវប្បធម៌ និងការផ្លាស់ប្តូរជនជាតិចិនចូលមករស់នៅកម្ពុជាជាដើមប៉ុណ្ណោះ ប៉ុន្តែទំនាក់ទំនងការទូតរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន បានចាប់ផ្តើមជាផ្លូវការនៅ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៥៨។ ថ្វីត្បិតតែកម្ពុជានិងចិន ទើបតែបានភ្ជាប់ទំនាក់ទំនងការទូតជាផ្លូវការនៅ ឆ្នាំ១៩៥៨ ក្តី ក៏ប៉ុន្តែសម្តេចនរោត្តម សីហនុ និងនាយករដ្ឋមន្ត្រីចិននាពេលនោះ គឺឯកឧត្តម ជូ អេនឡាយ បានជួបគ្នា និងកសាងទំនាក់ទំនងមិត្តភាពតាំងពីឆ្នាំ១៩៥៥ នៅពេលដែលមេដឹកនាំទាំងពីរបានចូលរួមនៅក្នុងសន្និសីទបណ្តាប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុងបានឌុង ប្រទេសឥណ្ឌូនេស៊ីមកម្ល៉េះ។ ហើយបើតាម អតីតលេខាផ្ទាល់សម្តេច សីហនុ លោក Julio Jeldres បានសរសេរនៅក្នុងអត្ថបទមួយនៅឆ្នាំ២០១២ថា សម្តេច សីហនុ សព្វព្រះទ័យលោក ជូ អេនឡាយ ព្រោះថ្នាក់ដឹកនាំប្រទេសមហាអំណាចចិនរូបនេះ ចេះដាក់ខ្លួន ឱនលំទោន គោរពទ្រង់។ គារវកិច្ចដ៏ទន់ភ្លន់របស់លោក ជូ អេនឡាយ បានធ្វើឱ្យសម្តេចឪ សីហនុ ទ្រង់មានព្រះទ័យយល់ថា ចិនដែលជាប្រទេសមហាអំណាច ផ្តល់តម្លៃស្មើមុខស្មើមាត់ដល់ព្រះអង្គ និងប្រទេសកម្ពុជា។[1]

ទំនាក់ទំនងកម្ពុជា-ចិន ត្រូវបានបង្អាក់បន្តិច បន្ទាប់ពីក្រុមលោកសេនាប្រមុខ លន់ ណុល និងព្រះអង្គម្ចាស់ស៊ីសុវត្ថិសិរីមតៈ បានធ្វើរដ្ឋប្រហារទម្លាក់សម្តេចនរោត្តមសីហនុចេញពីតំណែង រួចបង្កើតរបបសាធារណរដ្ឋខ្មែរដែលមានទំនោរទៅរកសហរដ្ឋអាម៉េរិក ប៉ុន្តែទំនាក់ទំនងកម្ពុជា-ចិន បានវិលត្រឡប់មកល្អប្រសើរវិញ និងកាន់តែជិតស្និទ្ធក្នុងនាមជាសម្ព័ន្ធមិត្ត នៅបន្ទាប់ពីការឡើងកាន់អំណាចរបស់ក្រុមខ្មែរក្រហម ដែលបានដាក់ឈ្មោះរបបរបស់ខ្លួនថា «កម្ពុជាប្រជាធិបតេយ្យ»។

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំហើយ ចិននៅតែបន្តជួយពួកខ្មែរក្រហមដែលបានភៀសខ្លួនទៅជ្រកនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដោយចិនបានជួយឧបត្ថម្ភអាវុធដល់ខ្មែរក្រហម ឱ្យធ្វើសង្គ្រាមទល់នឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងបានជួយជាជំហរដល់ពួកខ្មែរក្រហមនៅក្នុងកិច្ចចរចាទីក្រុងប៉ារីស។ ប៉ុន្តែនៅទីបំផុត ជំនួយរបស់ចិនដល់ពួកខ្មែរក្រហម ត្រូវបានបញ្ចប់នៅចុងឆ្នាំ១៩៩៣ ឆ្នាំដែលកម្ពុជាបានស្គាល់នូវការបោះឆ្នោតតាមបែបប្រជាធិបតេយ្យលើកដំបូង បន្ទាប់ពីបានពើបប្រទះនឹងសង្គ្រាមប្រមាណ៣ទសវត្សរ៍ និងបានបង្កើតរដ្ឋសភាជាតិនិងរាជរដ្ឋាភិបាលថ្មីមួយរបស់កម្ពុជានាសម័យរាជាណាចក្រទីពីរ។

[1] RFI, "កម្ពុជា-ចិន៖ ទំនាក់ទំនងដែលផ្តល់ប្រយោជន៍ដល់គ្នាទៅវិញទៅមក", ចុះផ្សាយថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩

## I. ទំនាក់ទំនងនយោបាយកម្ពុជា-ចិនមុននិងក្រោយការបោះឆ្នោតឆ្នាំ ១៩៩៨

### ១. របត់នៃទំនាក់ទំនងរវាងគណបក្សប្រជាជនកម្ពុជានិងបក្សកុម្មុយនីស្តចិនចាប់ពីឆ្នាំ ១៩៩៨

ចាប់ពីឆ្នាំ១៩៩៣មក មិនខុសពីបណ្តាប្រទេសធំៗដទៃទៀតនោះទេ សាធារណរដ្ឋប្រជាមានិតចិនមានទំនាក់ទំនងជិតស្និទ្ធជាមួយថ្នាក់ដឹកនាំគណបក្សហ៊្វុនស៊ិនប៉ិច(FUNCINPEC) ជាជាងថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា។ ហេតុផលនោះ ក៏ព្រោះតែថ្នាក់ដឹកនាំចិនយល់ឃើញថា កិត្យានុភាពរបស់សម្តេចនរោត្តមសីហនុ និងទម្ងន់របស់ហ៊្វុនស៊ិនប៉ិច នៅលើឆាកនយោបាយកម្ពុជា មានប្រៀបជាងគណបក្សប្រជាជនកម្ពុជា។ ហើយដោយទំនាក់ទំនងរវាងសម្តេចនរោត្តមសីហនុ និងឯកឧត្តម ហ៊ុន សែន ពេញមួយទសវត្សរ៍ទី៩០មានភាពមិនទៀងទាត់ វាបានក្លាយទៅជាឧបសគ្គធំមួយដែល មិនផ្តល់ឱកាសឱ្យចិនខិតទៅរកឯកឧត្តម ហ៊ុន សែន ដោយងាយស្រួលបាននោះឡើយ។[2] ទោះជាយ៉ាងណាក៏ដោយ ដោយសារការចុះអន់ថយនៃឥទ្ធិពលនយោបាយរបស់គណបក្សហ៊្វុនស៊ិនប៉ិចក្នុងប្រទេស ជាមួយនឹងការរីកចម្រើនជាលំដាប់នៃទំនាក់ទំនងល្អប្រសើរ ជាមួយនឹងរដ្ឋាភិបាលដែលដឹកនាំដោយឯកឧត្តម ហ៊ុន សែន ពិសេសរវាងគណបក្សកុម្មុយនីស្តចិន និងគណបក្សប្រជាជនកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន នៅខែសីហា ឆ្នាំ១៩៩៧ បានទទួលស្គាល់នូវរាជរដ្ឋាភិបាលថ្មីរបស់កម្ពុជា ក្រោយព្រឹត្តិការណ៍ផ្ទុះអាវុធ ថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧។

ជាដំណាក់កាលចំណាប់ផ្តើមនិងការវិវត្តដ៏សំខាន់នៃទំនាក់ទំនងរវាងប្រទេសទាំងពីរ នៅខែកុម្ភៈ ឆ្នាំ១៩៩៩ ឯកឧត្តម ហ៊ុន សែន បានអញ្ជើញធ្វើដំណើរទស្សនកិច្ចផ្លូវការជាលើកដំបូងក្នុងនាមជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាទៅកាន់សាធារណរដ្ឋប្រជាមានិតចិន។ ក្នុងដំណើរទស្សនកិច្ចជាលើកដំបូងនេះ កម្ពុជាទទួលបាននូវការផ្តល់ប្រាក់កម្ចីគ្មានការប្រាក់ក្នុងទំហំ ២០០លានដុល្លារ ជាមួយនឹងការសន្យាពីភាគីចិនថា នឹងផ្តល់ជូននូវជំនួយក្នុងទឹកប្រាក់ ១៨,៣លានដុល្លារបន្ថែមទៀត។ វាគឺជាជំនួយដែលមានទំហំទឹកប្រាក់ធំបំផុតមួយ បើប្រៀបធៀបទៅនឹងជំនួយដែលចិនធ្លាប់បានផ្តល់ទៅកាន់ប្រទេសដទៃផ្សេងទៀត។ បន្ថែមពីលើនេះទៅទៀតនៅឆ្នាំ២០០០ សាធារណរដ្ឋប្រជាមានិតចិន ក៏បានឧបត្ថម្ភក្នុងការកសាងវិទ្យាស្ថានកងទ័ពជើងគោក នៅថ្កុកតាសេក ក្នុងខេត្តកំពង់ស្ពឺ ដែលមានទឹកប្រាក់ទំហំ ១,៥លានដុល្លារអាម៉េរិក ជាមួយនឹងសម្ភារៈយោធាមួយចំនួនទៀតផងដែរ។ នេះបានក្លាយទៅជាសក្ខីភាពដ៏សំខាន់មួយ នៃទំនាក់ទំនងរវាងប្រទេសទាំងពីរ បន្ទាប់ពីគណបក្សប្រជាជនកម្ពុជា បានក្លាយទៅជាគណបក្សធំទីមួយ និងជាគណបក្សកាន់អំណាចនៅកម្ពុជា។

[2] RFI, "ចិន និងកម្ពុជា៖ ពីមិត្តភាពរវាងថ្នាក់ដឹកនាំ មកជាមិត្តភាពរវាងប្រទេស និងប្រទេស" ចុះផ្សាយថ្ងៃទី០២ ខែមេសា ឆ្នាំ ២០១៤

## ២. ការចូលជាសមាជិកអាស៊ានរបស់កម្ពុជា ឱកាសនៃការពង្រឹងតួនាទីរបស់កម្ពុជាក្នុងឆាកអន្តរជាតិ

ជាតថភាព ប្រសិនបើគ្មានព្រឹត្តិការណ៍ថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ នោះទេ តាមការគ្រោងទុក ព្រះរាជាណាចក្រកម្ពុជា នឹងត្រូវបញ្ចូលទៅជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ នៅក្នុងឆ្នាំ១៩៩៧ជាមួយនឹងប្រទេសឡាវ និងវៀតណាម។ តែទោះជាយ៉ាងណា នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ កម្ពុជាបានក្លាយទៅជាសមាជិកទី១០ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា "អាស៊ាន"។

កម្ពុជា បានសម្រេចចូលជាសមាជិកអាស៊ាន ដោយផ្អែកលើកត្តាគោលការណ៍បួនយ៉ាងគឺ៖

- គោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ដែលអាស៊ានបានប្រកាន់យក

- ស្មារតីសហគមន៍ជាគោលការណ៍មូលដ្ឋានគ្រឹះ គឺអាស៊ានធ្វើការសម្រេចលើកិច្ចការនានាផ្អែកតាមការសម្រេចជាឯកច្ឆន្ទ (កុងសង់ស៊ីស «Consensus»)

- ការទទួលបាននូវផលប្រយោជន៍ពីសមាហរណកម្មអាស៊ាន ដែលទាក់ទងនឹងការកសាងសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងការតភ្ជាប់

- អាស៊ាន ជាច្រកការទូតរបស់កម្ពុជាឆ្ពោះទៅកាន់តំបន់ និងពិភពលោក តាមរយៈដៃគូសន្ទនារបស់អាស៊ាន ដៃគូខាងក្រៅផ្សេងៗទៀត រួមទាំងអង្គការតំបន់ និងអង្គការអន្តរជាតិ។

ក្នុងនាមជាសមាជិករបស់អាស៊ាន កម្ពុជាទទួលបានឱកាសជជែកនិងពិភាក្សាដោយផ្ទាល់ជាមួយនឹងបណ្តាមហាអំណាច តាមរយៈជំនួបកំពូលថ្នាក់ដឹកនាំអាស៊ាននិងបណ្តាមហាអំណាចទាំងនោះ រួមមាន៖ កិច្ចប្រជុំកំពូលអាស៊ាន-ចិន, កិច្ចប្រជុំកំពូលអាស៊ាន-ជប៉ុន, កិច្ចប្រជុំកំពូលអាស៊ាន-កូរ៉េ, កិច្ចប្រជុំកំពូល អាស៊ាន បូក ៣ ( ចិន-ជប៉ុន-កូរ៉េ ), កិច្ចប្រជុំកំពូល អាស៊ាន-ឥណ្ឌា, កិច្ចប្រជុំកំពូល អាស៊ាន-អាម៉េរិក, និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ាជាដើម។

ដោយមើលឃើញពីសារៈសំខាន់នៃតួនាទីរបស់កម្ពុជាក្នុងអង្គការតំបន់ និងកិច្ចប្រជុំកំពូលជាច្រើនតាមរយៈការសមាហរណកម្មខ្លួនចូលក្នុងបរិបទតំបន់និងពិភពលោកដូចបានរៀបរាប់ សាធារណរដ្ឋប្រជាមានិតចិន បានពង្រឹងនិងពង្រីកនូវទំនាក់ទំនងទ្វេភាគីកម្ពុជា-ចិនកាន់តែជិតស្និទ្ធ ដែលវិវត្តពីទំនាក់ទំនងជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ឈានទៅដល់ទំនាក់ទំនងចាក់ទឹកមិនលិច។ វាជាការពិតណាស់ ដូចដែលពាក្យស្លោកនយោបាយរបស់ចិន ដែលលើកឡើងថា *«គ្មានមិត្ត គ្មានសត្រូវ តែមានផលប្រយោជន៍ ចិនធ្វើទាំងអស់ »* ផលប្រយោជន៍ជាយុទ្ធសាស្ត្រដែលសាធារណរដ្ឋប្រជាមានិតចិនទទួលបានចេញពីទំនាក់ទំនងចាក់ទឹកមិនលិចជាមួយនឹងកម្ពុជាពិតជាមានច្រើន ដែលក្នុងនោះមានដូចជាផលប្រយោជន៍ភូមិសាស្ត្រនយោបាយក្នុងតំបន់អាស៊ាន និងអាស៊ី, ការគាំទ្រគោលនយោបាយ

ចិនតែមួយ, យុទ្ធសាស្ត្រខ្សែក្រវាត់មួយវិថីមួយ គម្រោងធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី និងចំណែកក្នុងដំណោះស្រាយនិងជំហរក្នុងបញ្ហាសមុទ្រចិនខាងត្បូងជាដើម។

## II. ទំនាក់ទំនងជាយុទ្ធសាស្ត្រនៅដើមសតវត្សរ៍ទី២១

### ១. ទំនាក់ទំនងជាយុទ្ធសាស្ត្រ

នៅក្នុងទំនាក់ទំនងទ្វេភាគីកម្ពុជា-ចិន អ្វីដែលសាធារណរដ្ឋប្រជាមានិតចិន ត្រូវការពីកម្ពុជានោះគឺ ការគាំទ្រសម្រាប់គោលនយោបាយចិនតែមួយ ផលប្រយោជន៍ជាយុទ្ធសាស្ត្រនៅក្នុងតំបន់និងពិភពលោក ការគាំទ្រពីកម្ពុជាចំពោះគម្រោងខ្សែក្រវាត់មួយវិថីមួយ និងការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ដែលមានគោលដៅចម្បងឈានទៅការតភ្ជាប់បណ្តាប្រទេសក្នុងតំបន់អាស៊ានទាំងមូលក៏ដូចជាតំបន់អាស៊ីផងដែរ ហើយតាមរយៈទំនាក់ទំនងជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយជាមួយកម្ពុជា ចិនក៏មានបំណងចង់បន្ថយ និងរាំងខ្ទប់ឥទ្ធិពលរបស់សហរដ្ឋអាម៉េរិកនៅអាស៊ីប៉ាស៊ីហ្វិក និងពង្រីកឥទ្ធិពលសេដ្ឋកិច្ច នយោបាយ និងការទូតរបស់ខ្លួននៅក្នុងតំបន់អាស៊ានផងដែរ។ លើសពីនេះទៅទៀត ទំនាក់ទំនងចាក់ទឹកមិនលិចជាមួយកម្ពុជា គឺជាកូនសោរគន្លឹះដ៏សំខាន់មួយដែលចិនអាចប្រើប្រាស់ដើម្បីបញ្ចៀសការប្រឈមមុខដាក់គ្នាដោយតានតឹងរវាងចិននិងអាស៊ានទាំងមូល ក្នុងបញ្ហាជម្លោះសមុទ្រចិនខាងត្បូងជាមួយប្រទេសប្រ៊ុយណេ ម៉ាឡេស៊ី វៀតណាម និងហ្វីលីពីន ព្រោះដូចបានដឹងស្រាប់ហើយថា រាល់សេចក្តីសម្រេចចិត្តណាមួយរបស់អាស៊ាន គឺត្រូវឈរនៅលើគោលការណ៍កុងសង់ស៊ីស។

ចាប់តាំងពីដើមសតវត្សរ៍ទី២១ ទំនាក់ទំនងកម្ពុជា-ចិនក្នុងសម័យកាលរាជាណាចក្រទីពីរ ភាគីចិនតែងតែផ្តោតការយកចិត្តទុកដាក់ទៅលើទំនាក់ទំនងជាមួយប្រទេសកម្ពុជាដោយផ្តល់ការជ្រោមជ្រែងគាំទ្រដល់ប្រទេសកម្ពុជាក្នុងការដើរតាមមាគ៌ាអភិវឌ្ឍន៍ដោយសិទ្ធិស្វ័យសម្រេច និងដោយសមស្របនឹងស្ថានភាពរបស់ប្រទេសខ្លួន។

នៅខែវិច្ឆិកា ឆ្នាំ២០០០ ក្នុងដំណើរទស្សនកិច្ចផ្លូវរដ្ឋមកកាន់កម្ពុជារបស់ប្រធានាធិបតីចិន ឯកឧត្តម ជាំង ជឺមីង ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ បានឯកភាពនិងចាត់ទុកដំណើរទស្សនកិច្ចលើកដំបូងបង្អស់របស់ថ្នាក់ដឹកនាំចិន គឺជាចំណុចកំពូលមួយក្នុងប្រវត្តិសាស្ត្រទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ។ ក្នុងដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំចិនលើកដំបូងនេះ មេដឹកនាំប្រទេសទាំងពីរ បានចេញសេចក្តីប្រកាសរួមគ្នាមួយ ស្តីពី «*ការពង្រីកវិសាលភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគី*»។ ហើយជាការឆ្លើយតប សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានបញ្ជាក់ជំហរជាថ្មីថា កម្ពុជានឹងនៅតែបន្តគាំទ្រ «*គោលនយោបាយចិនតែមួយ*»។

នៅខែវិច្ឆិកា ឆ្នាំ២០០២ ក្នុងឱកាសនៃការធ្វើទស្សនកិច្ចផ្លូវការរយៈពេលពីរថ្ងៃមកកាន់កម្ពុជា ឯកឧត្តម ជូ រ៉ុងជី នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិនបានប្រកាសអំពីការលុបចោលនូវបំណុលទំហំ ២០០លានដុល្លារសហរដ្ឋអាម៉េរិក ដែលកម្ពុជាបានខ្ចីកាលចុងឆ្នាំ១៩៩៩។ ជាមួយគ្នា

នោះដែរ ចិនក៏ប្រកាសផ្តល់ប្រាក់កម្ចីឥតការប្រាក់ និងផ្តល់ជំនួយសរុបចំនួន ១២,៥លានដុល្លារសហរដ្ឋអាម៉េរិកបន្ថែមទៀតដល់រាជរដ្ឋាភិបាលកម្ពុជា។ ថ្នាក់ដឹកនាំប្រទេសទាំងពីរ បានព្រមព្រៀងគ្នាកំណត់យកវិស័យកសិកម្ម ការអភិវឌ្ឍធនធានមនុស្ស និងការកសាងហេដ្ឋារចនាសម្ព័ន្ធ ជាវិស័យអាទិភាពសម្រាប់កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។

ក្នុងដំណើរទស្សនកិច្ចជាផ្លូវការលើកទី៣ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន នៅខែធ្នូ ឆ្នាំ២០១០ មេដឹកនាំនៃប្រទេសទាំងពីរ បានព្រមព្រៀងគ្នាបានបង្កើត *«ទំនាក់ទំនងភាពជាដៃគូសហប្រតិបត្តិការជាយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ»* នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ ដែលបានជំរុញឱ្យទំនាក់ទំនងកម្ពុជា-ចិន បានវិវត្តយ៉ាងឆាប់រហ័ស និងកាន់តែស្និតរមួតចាប់ពីពេលនោះរហូតមកដល់បច្ចុប្បន្ន។

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ ក្នុងជំនួបទ្វេភាគីនាឱកាសដែលសម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលលើកទី៤ នៃសន្និសីទអន្តរជាតិសកម្មភាពនិងវិធានការកសាងទំនុកចិត្តនៅអាស៊ី នាទីក្រុងសៀងហៃ ឯកឧត្តម ស៊ី ជិនពីង ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន បានថ្លែងស្នើឱ្យប្រទេសទាំងពីរ ពង្រឹងភាពជាដៃគូរបស់ខ្លួនឱ្យបានកាន់តែខ្លាំងក្លាថែមទៀត ទោះបីជាស្ថានការណ៍អន្តរជាតិប្រែប្រួលយ៉ាងណាក្តី។ ឯកឧត្តម ស៊ី ជិនពីង បានលើកឡើងថា «ប្រទេសចិនបានត្រៀមលក្ខណៈរួចជាស្រេចក្នុងការបន្តទស្សនកិច្ចទៅវិញទៅមកនៃគណៈប្រតិភូជាន់ខ្ពស់ជាមួយកម្ពុជា ដើម្បីលើកកម្ពស់ទំនាក់ទំនងរវាងគណបក្សកាន់អំណាចនៃប្រទេសទាំងពីរ និងចែករំលែកបទពិសោធផ្នែកអភិបាលកិច្ច»។ ប្រធានាធិបតីចិន ក៏បានប្តេជ្ញាគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការការពារសន្តិសុខ និងស្ថិរភាពជាតិ ព្រមទាំងសន្យាបន្តជំនួយសម្រាប់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជាផងដែរ ហើយជាសកម្មភាពជាក់ស្តែងនាពេលកន្លងមកនេះ ចិនបានផ្តល់ជាជំនួយជាបច្ចេកទេស ដូចជាការជួយឧបត្ថម្ភគ្រប់បែបយ៉ាងលើវិស័យកសិកម្មដល់កម្ពុជា ដែលរួមមានទាំងបច្ចេកទេសដាំដំណាំ ប្រព័ន្ធធារាសាស្ត្រ និងការនាំចេញអង្ករជាដើមដោយបានផ្តល់នូវការជួយជ្រោមជ្រែងដល់កសិករកម្ពុជា និងការផ្តល់ជំនួយជាសម្ភារៈសម្រាប់បម្រើដល់ការងារនៅតាមក្រសួង ស្ថាប័ន និងអង្គភាពយោធានានាជាដើម។

ជាកាយវិការឆ្លើយតបទៅនឹងទំនាក់ទំនងដ៏ល្អនេះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោក៏បានយល់ព្រមចូលរួមនូវកិច្ចប្រជុំ វេទិកា និងសន្និសីទកម្រិតមេដឹកនាំជាច្រើនផ្សេងទៀត ដែលចិនបានផ្តួចផ្តើមគំនិតឬទទួលជាម្ចាស់ផ្ទះ ដូចជា សន្និសីទថ្នាក់ដឹកនាំលើកដំបូងស្តីពី យន្តការនៃកិច្ចសហប្រតិបត្តិការទន្លេឡានឆាង និង ទន្លេមេគង្គនៅប្រទេសចិន, ពិព័រណ៍ពាណិជ្ជកម្មចិន-អាស៊ានជារៀងរាល់ឆ្នាំ និងវេទិកាអាស៊ីប៊ូអាវ ជាដើម។ ជាមួយគ្នានោះ ភាគីកម្ពុជាក៏តែងតែបានរួមសហការជាមួយភាគីចិនក្នុងការបង្ក្រាបលើករណីចាប់ជំរិត និងឆបោកតាមបណ្តាញអ៊ីនធឺណិត និងទូរគមនាគមន៍ និង

បានផ្តល់ការគាំទ្រយ៉ាងម៉ឺងម៉ាត់ដល់ប្រទេសចិន ក្នុងការរួមសហការតាមដានចាប់ខ្លួនមន្ត្រីស៊ីសំណូក ដែលរត់គេចខ្លួនមកក្រៅប្រទេសចិនទៀតផង។[3]

## ២. ជំនួយរបស់ចិនមកកម្ពុជាចាប់ពីឆ្នាំ២០០០

### ជំនួយសម្រាប់ការអភិវឌ្ឍ (ODA)

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ធ្លាប់បានថ្លែងសុន្ទរកថា នៅក្នុងឆ្នាំ២០០៦ ថា «ប្រទេសចិននិយាយតិច ប៉ុន្តែធ្វើច្រើន» ដោយក្នុងនោះគេឃើញថា កម្ចីដែលផ្តល់ដោយសាធារណរដ្ឋប្រជាមានិតចិន ពុំមានចងភ្ជាប់ជាមួយនូវលក្ខខណ្ឌច្រើនដូចកម្ចីដែលផ្តល់ដោយបណ្តាប្រទេសនានា ដែលនិយាយអំពីប្រជាធិបតេយ្យ និងសិទ្ធិមនុស្សជាដើមនោះទេ ហើយម្យ៉ាងវិញទៀត កម្ចីរបស់ចិនបានផ្តល់លទ្ធភាពបើកទូលាយដល់កម្ពុជាសម្រាប់យកទៅធ្វើការប្រើប្រាស់មូលនិធិនោះដោយស្វ័យសម្រេចផ្ទាល់ខ្លួន។ ជាការពិតណាស់ នាពេលកន្លងមកកម្ពុជាតែងតែអនុវត្តគម្រោងអភិវឌ្ឍដែលបានទទួលមូលនិធិពីបរទេស និងធ្វើតាមដំណាក់កាលដែលគេផ្តល់ឱ្យ តួយ៉ាងជាឧទាហរណ៍ជាក់ស្តែង នៅពេលដែលទទួលបានជំនួយអភិវឌ្ឍសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធដូចជាការស្ថាបនាផ្លូវថ្នល់ ដែលត្រូវដាក់ឱ្យដំណើរការគម្រោងក្នុងរយៈពេលមួយ មុននឹងជំនួយឬកម្ចីសម្រាប់ធ្វើការក្នុងវិស័យប្រព័ន្ធលូបង្ហូរទឹក វាគឺជាបញ្ហាមួយចំពោះកាលៈទេសៈមុននិងក្រោយនៃការអនុវត្តគម្រោងទាំងពីរ ដែលតាមការពិត ចាំបាច់ត្រូវធ្វើតាមលំដាប់លំដោយ។ តែដោយសារម្ចាស់ជំនួយ គេមានការកំណត់កាលបរិច្ឆេទនៅក្នុងការអនុវត្តគម្រោងដោយឡែករបស់គេ កម្ពុជាបានអនុវត្តតាមកាលបរិច្ឆេទដែលម្ចាស់ជំនួយចង់បាន។

នៅក្នុងដំណើរទស្សនកិច្ចជាលើកដំបូងរបស់ឯកឧត្តមនាយករដ្ឋមន្ត្រី ហ៊ុន សែន នាខែកុម្ភៈ ឆ្នាំ ១៩៩៩ កម្ពុជាទទួលបាននូវការផ្តល់ប្រាក់កម្ចីគ្មានការប្រាក់ក្នុងទំហំ ២០០លានដុល្លារ ជាមួយនឹងការសន្យាពីភាគីចិនថា នឹងផ្តល់ជូននូវជំនួយក្នុងទឹកប្រាក់ ១៨,៣លានដុល្លារបន្ថែមទៀត។

នៅឆ្នាំ២០០៩ សាធារណរដ្ឋប្រជាមានិតចិន បានផ្តល់កញ្ចប់ជំនួយជាប្រាក់កម្ចីសម្បទាន និងប្រាក់ជំនួយឥតសំណងសរុបទំហំ ១,២៣ន់លានដុល្លារសហរដ្ឋអាម៉េរិកមកកាន់កម្ពុជា ដែលធ្វើឱ្យចិនបានក្លាយទៅជាប្រទេសម្ចាស់ជំនួយធំបំផុតរបស់កម្ពុជា។

នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១០ សាធារណរដ្ឋប្រជាមានិតចិន បានប្រកាសលុបចោលបំណុលជាង ៤លានដុល្លារ ដែលរដ្ឋាភិបាលកម្ពុជាសម័យកម្ពុជាប្រជាធិបតេយ្យបានខ្ចីពីចិន។ ការប្រកាសលុបចោលបំណុលនេះបានធ្វើឡើងភ្លាមៗបន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជា បានស្នើសុំទៅកាន់សហរដ្ឋអាម៉េរិកឱ្យពិចារណាលុបចោលបំណុលជាង ៤០០លានដុល្លារដែលរដ្ឋាភិបាលកម្ពុជាសម័យសាធារណរដ្ឋខ្មែរខ្ចីពីសហរដ្ឋអាម៉េរិកដើម្បីធ្វើសង្គ្រាម តែសហរដ្ឋអាម៉េរិកមិនបានឆ្លើយតបតាមការស្នើសុំនោះទេ។

[3] គេហទំព័រគណបក្សប្រជាជនកម្ពុជា, "ទំនាក់ទំនងរវាងប្រទេសកម្ពុជា និងចិន", ចេញផ្សាយថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២ ក្នុងឆ្នាំដែលកម្ពុជាទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន ឯកឧត្តមប្រធានាធិបតីចិន ឯកឧត្តម ហ៊ូ ជីនតាវ (Hu Jintao) បានធ្វើទស្សនកិច្ចរយៈពេល ៤ថ្ងៃមកកាន់កម្ពុជា និងបានសន្យាផ្តល់ជំនួយជិត ៤០លានដុល្លារសហរដ្ឋអាម៉េរិក និងប្រាក់កម្ចីចំនួនជាង ៣០លានដុល្លារដល់កម្ពុជា។ ក្នុងជំនួបជាមួយប្រធានាធិបតីចិននោះផងដែរ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ស្នើសុំឱ្យភាគីចិន ផ្តល់ប្រាក់កម្ចីជារៀងរាល់ឆ្នាំពី ៣០០លានដុល្លារទៅ ៥០០លានដុល្លារសហរដ្ឋអាម៉េរិកដល់កម្ពុជា ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រ និងអគ្គិសនីជាដើម។ ជាមួយគ្នានោះ ឯកឧត្តមប្រធានាធិបតីចិន ក៏បានអះអាងយ៉ាងមុតមាំអំពីការគាំទ្ររបស់សាធារណរដ្ឋប្រជាមានិតចិន ចំពោះបេក្ខភាពរបស់កម្ពុជាក្នុងតំណែងជាសមាជិកមិនអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សម្រាប់ឆ្នាំ២០១៣ ដល់ឆ្នាំ២០១៤ ផងដែរ។

នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៣ ក្នុងដំណើរទស្សនកិច្ចរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ប្រមុខដឹកនាំកម្ពុជា និងចិន បានឯកភាព បន្តកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ យុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយលើគ្រប់វិស័យ ចាប់តាំងពីឆ្នាំ២០១០។ ចិនក៏បានផ្តល់ឱ្យកម្ពុជានូវជំនួយឥតសំណង ៤៨ លានដុល្លារ និងប្រាក់កម្ចីសម្បទាន ៥០០ លានដុល្លារ បន្ថែមលើការចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់គ្នា លើគម្រោងវិនិយោគ និងការអភិវឌ្ឍនៅកម្ពុជា ចំនួន ៨ គម្រោង ដែលសរុបជាទឹកប្រាក់ប្រមាណពីរពាន់លានដុល្លារ។ មេដឹកនាំចិន បានប្រកាសផ្តល់ជំនួយឥតសំណងដល់កម្ពុជា នូវទឹកប្រាក់ ៣០០ លានយ័ន ស្មើប្រមាណ ៤៨ លានដុល្លារអាម៉េរិក និងប្រាក់កម្ចីសម្បទាន ក្នុងកម្រិតការប្រាក់ទាប ចំនួន ៥០០ លានដុល្លារអាម៉េរិក។ ប្រាក់ជំនួយរបស់ចិននេះ ត្រូវប្រើប្រាស់ សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធ ពិសេសប្រែក្លាយផ្លូវលំជនបទទៅជាផ្លូវចាក់កៅស៊ូប្រវែង ៤០០ គីឡូម៉ែត្រ ក្នុងមួយឆ្នាំ និងសម្រាប់សាងសង់ប្រព័ន្ធធារាសាស្ត្រប្រឡាយទឹក ជាដើម។ ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ ចិនជាអ្នកផ្តល់ជំនួយធំជាងគេ សម្រាប់កសាងផ្លូវប្រវែងជាង ២០០០ គីឡូម៉ែត្រ និងស្ពានធំៗ៧កន្លែងនៅកម្ពុជា។ ក្នុងនោះ មានកិច្ចព្រមព្រៀងមួយ និយាយពីគម្រោងសាងសង់រោងចក្រចម្រាញ់ប្រេង រវាងធនាគារ និងក្រុមហ៊ុនចិន សហការជាមួយក្រុមហ៊ុនកម្ពុជា ដែលមានទឹកប្រាក់ ១.៦៧០ លានដុល្លារអាម៉េរិក។ រោងចក្រចំរាញ់ប្រេងកាតនោះ អាចនឹងត្រូវសាងសង់ នៅតាមផ្លូវជាតិលេខ៣ ចន្លោះពីខេត្តកំពត ទៅវាលរេញ ស្ថិតនៅជើងភ្នំបូកគោ ផ្នែកខាងសមុទ្រ ក្នុងទឹកដីខេត្តកំពត។ [4]

ក្នុងកំឡុងដំណើរទស្សនកិច្ចនៅទីក្រុងប៉េកាំង ឆ្នាំ២០១៣ និងឆ្នាំ ២០១៤ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងកម្ចីការប្រាក់ទាប ៥០០ លានដុល្លារ និងជំនួយឥតសំណង ទំហំ ៤៨ លានដុល្លារ។[5] ហើយទិន្នន័យជំនួយបានបង្ហាញថា គម្រោងចំនួន

[4] RFI, "កម្ពុជា-ចិនបន្តសហប្រតិបត្តិការ ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ" ចុះផ្សាយថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣

[5] Reuters, "China pledges $548 million in aid to ally Cambodia", release on April 10, 2013e

១០២ ត្រូវបានទ្រទ្រង់ដោយប្រទេសចិនពីឆ្នាំ២០១០ ដល់ ឆ្នាំ២០១៤ សរុបជាង ៣,៩ ពាន់លានដុល្លារសហរដ្ឋអាម៉េរិក។[6]

នៅថ្ងៃទី០៧ ខែ មិថុនា ឆ្នាំ ២០១៦ ចិនបានប្រកាសអំពីការផ្តល់ថវិកា ៤៥០ លានដុល្លារនៅក្នុងរូបភាពជាជំនួយអភិវឌ្ឍន៍ដល់កម្ពុជាសម្រាប់រយៈពេលពីរឆ្នាំ។

នៅក្នុងដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ប្រធានាធិបតីចិននៅកម្ពុជាកាលពីថ្ងៃទី១៣-១៤ តុលា ២០១៦ ភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនិងពិធីសារចំនួន៣១ ដែលក្នុងនោះ ភាគីចិនបានសម្រេចលុបចោលបំណុលដែលកម្ពុជាជំពាក់ចំនួន៦០០លានយ័ន និងបានផ្តល់ជំនួយបន្ថែមចំនួន ១០០លានយ័នទៀត សម្រាប់ការអភិវឌ្ឍវិស័យយោធាកម្ពុជា។[7]

ប្រទេសចិនបានអនុវត្តគម្រោងដែលមានភាពស្មុគស្មាញនានានៅកម្ពុជា និងដែលគម្រោងទាំងនោះ ត្រូវបានបញ្ចប់ក្នុងរយៈពេលខ្លីជាងបណ្តាគម្រោងរបស់អ្នកវិនិយោគបរទេសដទៃទៀតនៅកម្ពុជា ហើយដែលគម្រោងទាំងនេះរួមមានជាសំខាន់គឺទំនប់ រោងចក្រ និងមូលដ្ឋានយោធា ជាដើម។ [8]

យោងតាមប្រព័ន្ធទិន្នន័យរបស់រាជរដ្ឋាភិបាល ស្តីពី ជំនួយអភិវឌ្ឍន៍ពីបរទេស ចេញផ្សាយក្នុងឆ្នាំ២០១៦ បានបង្ហាញឱ្យឃើញថា ក្នុងរយៈពេល ១៣ឆ្នាំ ជំនួយអភិវឌ្ឍន៍របស់ចិន នៅកម្ពុជា មានចំនួនសរុប ៥៧គម្រោង ក្នុងនោះមាន ៤៧គម្រោង គឺជាប្រភេទប្រាក់កម្ចីមានទឹកប្រាក់សរុបជិត ៣ពាន់លានដុល្លារអាម៉េរិក និងប្រភេទជំនួយឥតសំណងមានចំនួនត្រឹម ១០គម្រោងប៉ុណ្ណោះ ដែលមានទឹកប្រាក់សរុបជិត ១៨០លានដុល្លារអាម៉េរិក។ ក្នុងនោះផងដែរ មានគម្រោងមួយសម្រាប់សាងសង់ពហុកីឡដ្ឋានជាតិមរតកតេជោ ដែលមានទឹកប្រាក់ជំនួយជាង ១៥០លានដុល្លារសហរដ្ឋអាម៉េរិក ជាជំនួយដែលរដ្ឋាភិបាលចិនផ្តល់ជូនកម្ពុជា ដើម្បីត្រៀមសម្រាប់ការទទួលធ្វើជាម្ចាស់ផ្ទះក្នុងព្រឹត្តិការណ៍ស៊ីហ្គេម (SEA Game) ឆ្នាំ២០២៣ និងព្រឹត្តិការណ៍កីឡាលំដាប់អន្តរជាតិដទៃទៀត។ ការសាងសង់ពហុកីឡដ្ឋាននេះ ត្រូវបានបែងចែកជា ៣ជំហាន។ ជំហានទីមួយ១ ជាបន្ទុកចំណាយរបស់រដ្ឋាភិបាលកម្ពុជា ដោយប្រើថវិកាជិត ៣៩លានដុល្លារសហរដ្ឋអាម៉េរិក ហើយបច្ចុប្បន្នសម្រេចបានប្រមាណ ៧០%។ ក្រុមហ៊ុនដែលទទួលបានកិច្ចសន្យាសាងសង់ គឺក្រុមហ៊ុន លី យ៉ុងផាត់ (LYP Group)។ រីឯជំហានទីពីរ នឹងត្រូវប្រើប្រាស់ថវិកាជាង ១៥០លានដុល្លារ ជាជំនួយឥតសំណងរបស់រដ្ឋាភិបាលចិនដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ទើបបានចុះកិច្ចព្រមព្រៀងទទួលយកកាលពីខែតុលា ឆ្នាំ

[6] ទិន្នន័យជំនួយ "ការតាមដានហិរញ្ញវត្ថុអភិវឌ្ឍរបស់ចិន", ២០១០-២០១៤. កម្ពុជា។ http://china.aiddata.org/

[7] RFI, "កម្ពុជាប្រកាសជំហរជាថ្មី គាំទ្រគោលនយោបាយចិនតែមួយ", ចុះផ្សាយថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៦

[8] Dr. YU Hongyuan. វិទ្យាស្ថានសៀងហៃសម្រាប់ការសិក្សាអន្តរជាតិ. សិក្ខាសាលាប្រឹក្សាយោបល់ស្តីពី «ទស្សនៈវិស័យសង្គមស៊ីវិលស្តីពីជំនួយរបស់ចិនដល់ប្រទេសកម្ពុជា» ធ្វើនៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៥, ការិយាល័យ CICP, រាជធានីភ្នំពេញ, ប្រទេសកម្ពុជា។

២០១៥ កន្លងទៅថ្មីៗនេះ។ ដំហានទីពីរ ចាប់ផ្តើមសាងសង់នៅដើមឆ្នាំ២០១៧ ដែលក្រុមហ៊ុនសាងសង់គឺជាក្រុមហ៊ុនចិន។ [9]

គិតត្រឹមខែ កុម្ភៈឆ្នាំ២០១៧ ប្រទេសកម្ពុជាបានទទួលជំនួយអភិវឌ្ឍផ្លូវការ ទាំងជំនួយឥតសំណង និងកម្ចីពីសាធារណរដ្ឋប្រជាមានិតចិនរហូតដល់ ៤,២ ប៊ីលានដុល្លារអាម៉េរិក ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត កសិកម្ម សុខាភិបាល និងវិស័យអប់រំ។[10]

ដោយសារទំនាក់ទំនងដ៏ល្អប្រសើរជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន រដ្ឋាភិបាលចិន បានផ្តល់ប្រាក់កម្ចីសាងសង់ស្ពានឆ្លងកាត់ទន្លេសរុបចំនួន ៧ខ្សែរួមមាន៖ ស្ពានស្ពានកោះធំ ស្ពានជ្រោយចង្វារទី២ ស្ពានសេកុងខេត្តស្ទឹងត្រែង ស្ពានព្រែកក្តាម ស្ពានព្រែកតាមាក់ ស្ពានមេគង្គស្ទឹងត្រែង និងស្ពានតាខ្មៅ។ ជាមួយគ្នានេះ ក្នុងជំនួបសំណេះសំណាលរវាងសម្តេចតេជោ ហ៊ុន សែន និងឯកឧត្តម លី ខឺឈាង នាយករដ្ឋមន្ត្រីចិន នៅប្រទេសម៉ុងហ្គោលី កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ រដ្ឋាភិបាលចិន បានសម្រេចផ្តល់ជំនួយប្រមាណ ៦០០លានដុល្លារ សម្រាប់ការអភិវឌ្ឍនៅកម្ពុជាក្នុងរយៈពេល ៣ឆ្នាំថែមទៀតផង។[11] លើសពីនេះទៅទៀត ចិនបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជួយជំរុញវឌ្ឍនភាពនៃវិស័យហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជា។

គួរបញ្ជាក់ផងដែរថា រាប់ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ ជំនួយសម្រាប់ការអភិវឌ្ឍន៍ផ្លូវការ (ODA) របស់សាធារណរដ្ឋប្រជាមានិតចិនមកកាន់កម្ពុជា ដែលមានទំហំទឹកប្រាក់ខ្ពស់ជាងគេ គឺនៅឆ្នាំ២០១២ ដែលមានទំហំ ៤៦០,៧ លានដុល្លារ និងជំនួយសម្រាប់ការអភិវឌ្ឍផ្លូវការ (ODA) ដែលមានទំហំទឹកប្រាក់ខ្ពស់បន្ទាប់ គឺនៅឆ្នាំ២០១៣ មានទំហំ ៤៣៦,៦ លានដុល្លារអាម៉េរិក។ ហើយបើយោងតាមតារាងរបាយការណ៍ ស្តីពី ដៃគូផ្តល់មូលនិធិអភិវឌ្ឍកម្ពុជារបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នៃគណៈកម្មការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា សាធារណរដ្ឋប្រជាមានិតចិន ជាប្រទេសឈានមុខគេមួយ ដែលបានផ្តល់ជំនួយសម្រាប់ការអភិវឌ្ឍផ្លូវការ (ODA) មកកាន់កម្ពុជា ជាបន្តបន្ទាប់រាប់ចាប់ពីឆ្នាំ ២០១៤ រហូតដល់ឆ្នាំ២០១៨ ដែលមានទំហំ ៣៤៧,៨ លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៤, ទំហំ ៣៣៩,៤ លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៥, ទំហំ ២៦៥,៣ លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៦, ទំហំ២២៣,៥ លានដុល្លារអាម៉េរិកនៅឆ្នាំ២០១៧ និងទំហំ ២៥១,៤ លានដុល្លារអាម៉េរិកនៅឆ្នាំ ២០១៨។

[9] RFA, «តើរដ្ឋាភិបាលកម្ពុជាបង្ហាញពីតម្លាភាពនៃប្រាក់កម្ចីពីប្រទេសចិនកម្រិតណាដល់ពលរដ្ឋ? », ចុះផ្សាយថ្ងៃទី២២ ខែមីនា ឆ្នាំ ២០១៦

[10] Property Area, «ហេតុអីចិនវិនិយោគច្រើននៅកម្ពុជា? តោះស្វែងយល់ពីទំនាក់ទំនងកម្ពុជា-ចិនជាមុនសិន» ចុះផ្សាយថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨

[11] Fresh News, «តើកម្ពុជា-ចិន ភ្ជាប់ទំនាក់ទំនងពីពេលណា? សមិទ្ធផលអ្វីខ្លះកើតចេញពីទំនាក់ទំនងនេះ?», ចុះផ្សាយថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦

| Development Partner Disbursement (USD Million) | | | | | |
|---|---|---|---|---|---|
| Development Partners | 2014 | 2015 | 2016 | 2017 (Est.) | 2018 (Proj.) |
| UN (core fund) | 53.9 | 47.2 | 63.2 | 76.3 | 57.0 |
| World Bank | 50.6 | 17.6 | 20.1 | 39.7 | 54.2 |
| ADB | 129.8 | 137.2 | 109.9 | 146.0 | 181.2 |
| GAVI Alliance | 5.5 | 19.0 | 10.2 | 10.9 | 9.2 |
| Global Fund | 54.6 | 33.3 | 28.2 | 71.7 | - |
| **Sub-Total UN & Multilaterals** | **294.4** | **254.3** | **231.5** | **344.6** | **301.6** |
| EU/EC | 70.3 | 55.8 | 56.0 | 59.8 | 26.7 |
| Czech Republic | 1.2 | 1.2 | 1.3 | 1.2 | - |
| France | 59.5 | 63.3 | 31.9 | 103.3 | 40.6 |
| Germany | 29.8 | 25.8 | 48.4 | 36.5 | 29.7 |
| Ireland | 0.7 | 0.6 | 0.6 | 1.3 | 1.3 |
| Sweden | 33.0 | 21.8 | 30.1 | 20.3 | 13.0 |
| United Kingdom | 0.1 | 0.2 | 1.6 | 2.3 | 0.3 |
| Other EU Members | 6.0 | - | - | - | - |
| **Sub-Total: EU Partners** | **200.6** | **168.7** | **169.8** | **224.6** | **111.6** |
| Australia | 64.9 | 55.9 | 51.9 | 56.3 | 41.3 |
| Canada | 5.7 | 3.8 | 3.0 | 1.6 | 0.7 |
| China | 347.8 | 339.4 | 265.3 | 223.5 | 251.4 |
| Japan | 111.4 | 110.4 | 119.7 | 126.4 | 168.0 |
| New Zealand | 6.0 | 4.9 | 4.0 | 5.3 | 5.5 |
| Republic of Korea | 80.3 | 61.7 | 31.9 | 51.2 | 24.6 |
| Switzerland | 11.8 | 13.0 | 15.8 | 13.8 | 10.0 |
| USA | 91.6 | 101.0 | 71.1 | 76.0 | 35.7 |
| **Sub-Total: Other** | **719.6** | **690.0** | **562.6** | **554.2** | **537.2** |
| **NGOs (core funds)** | 230.7 | 237.7 | 250.3 | 211.3 | 122.7 |
| **Pipeline Projects** | | | | 14.2 | 147.2 |
| **Grand total** | **1445.2** | **1350.7** | **1214.2** | **1348.9** | **1220.3** |

ប្រភព៖ http://www.cdc-crdb.gov.kh/cdc/aid-management-cambodia.html

យោងតាមតួលេខនៅក្នុងរបាយការណ៍ដែលចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា គិតត្រឹមឆ្នាំ២០១៨ កម្ពុជាបានជំពាក់បំណុលបរទេសប្រមាណជា ៧ពាន់លានដុល្លារ ដែលក្នុងនោះមកដល់ឆ្នាំ២០១៩នេះ ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) របស់ចិនមកកាន់កម្ពុជាមានចំនួន ២៧ ដែលសុទ្ធតែជាគម្រោងសំខាន់ៗមានដូចជា កសាងផ្លូវជាតិ កសាងទំនប់ទឹក ប្រឆាំងភេរវកម្ម កែលម្អមធ្យោបាយធ្វើដំណើរសាធារណៈ គ្រប់គ្រងទឹកជំនន់ ប្រព័ន្ធធារាសាស្ត្រ ពហុកីឡដ្ឋានជាតិ ស្ពាន និងអគ្គិសនី ក្នុងនោះកម្ពុជាបានទទួលប្រាក់កម្ចីសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវ និងស្ពានពីសាធារណរដ្ឋប្រជាមានិតចិន ប្រមាណជា ២.៨៦៥ លានដុល្លារអាម៉េរិក។ ប៉ុន្តែទោះបីជាថវិកានោះគឺជាថវិកាបានមកពីបំណុលដែលកម្ពុជាខ្ចីពីចិនក៏ដោយក្តី ក៏វាបានធ្វើឱ្យក្រុមហ៊ុនរដ្ឋនិងឯកជនរបស់សាធារណរដ្ឋប្រជាមានិតចិន មានឥទ្ធិពលនិងដើរតួនាទីយ៉ាងសំខាន់នៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជាផងដែរ ក៏ព្រោះតែក្រុមហ៊ុនដែលទទួលខុសត្រូវក្នុងការស្ថាបនាទាំងនោះ សុទ្ធសឹងជាក្រុមហ៊ុនរបស់ចិនដែលប្រើប្រាស់ជំនួយរបស់ប្រទេសចិនដល់កម្ពុជា ដើម្បីសាងសង់ឬជួសជុលផ្លូវជាតិ ផ្លូវដែក ស្ពាន កំពង់ផែទឹកជ្រៅ ព្រមទាំងទំនប់វារីអគ្គិសនី។ ជាក់ស្តែង ផ្លូវជាតិលេខ៧ពីក្រចេះទៅដល់ព្រំ

ដែនជាប់នឹងប្រទេសឡាវ ផ្លូវជាតិលេខ៧៨តភ្ជាប់កម្ពុជាទៅវៀតណាម ផ្លូវជាតិលេខ៧៦ទៅមណ្ឌលគិរី ទំនប់វារីអគ្គិសនីគីរីរម្យនិងភ្នំកំចាយ ព្រមទាំងកំពង់ផែទីក្រុងព្រះសីហនុសុទ្ធតែជាគម្រោងដែលចិនបានអនុវត្ត។

## ជំនួយនិងកិច្ចសហប្រតិបត្តិការយោធា

នៅឆ្នាំ១៩៩៧ បន្ទាប់ពីសាធារណរដ្ឋប្រជាមានិតកម្ពុជា ទទួលស្គាល់រាជរដ្ឋាភិបាលក្រោយព្រឹត្តិការណ៍ផ្ទុះអាវុធឆ្នាំ១៩៩៧រួចមក សាធារណរដ្ឋប្រជាមានិតចិនបានប្រគល់រថយន្តយោធាចំនួន ១១៦ គ្រឿង និងឡាន Jeep ៧០គ្រឿង ដែលសរុបមានតម្លៃ ២,៨ លានដុល្លារ មកដល់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។

ចាប់តាំងពីឆ្នាំ២០០០ រហូតមកដល់បច្ចុប្បន្ន ក្រសួងការពារប្រទេសនៃសាធារណរដ្ឋប្រជាមានិតចិន បានផ្តល់ជំនួយដល់ក្រសួងការពារជាតិកម្ពុជាជាបន្តបន្ទាប់ តាមរយៈកសាងអគារនិងហេដ្ឋារចនាសម្ព័ន្ធយោធា ការផ្តល់ឧបករណ៍សម្ភារៈពេទ្យ (ដល់មន្ទីរពេទ្យព្រះកេតុមាលា នៃក្រសួងការពារជាតិ) និងការបញ្ជូនក្រុមឯកទេសសំខាន់ៗមកជួយបណ្តុះបណ្តាលហ្វឹកហ្វឺនជូននាយទាហានជំនាញសំដៅលើកកម្ពស់សមត្ថភាពវិស័យយោធានិងវិស័យពង្រឹងវិស័យសុខាភិបាលយោធា តាមរយៈការផ្តល់ឱកាសដល់យោធាកម្ពុជាទៅទទួលការបណ្តុះបណ្តាលនៅសាធារណរដ្ឋប្រជាមានិតចិន ពីមួយឆ្នាំទៅមួយឆ្នាំ។

នៅក្នុងខែឧសភា ឆ្នាំ២០១០ ក្នុងដំណើរទស្សនកិច្ចរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅកាន់ប្រទេសចិន ឯកឧត្តម ហ៊ូ ជិនតាវ ប្រធានាធិបតីចិន បានប្រកាសផ្តល់ជំនួយជាសម្ភារៈយោធាដែលមានតម្លៃសរុប ១០០ លានយ័ន ឬស្មើនឹង១៤លានដុល្លារសហរដ្ឋអាម៉េរិកដល់កម្ពុជា ដែលជាជំនួយយោធាធំបំផុតលើកទី១។ សម្ភារៈទាំងនោះមានរថយន្តយោធាចំនួន២៥៧គ្រឿងដែលត្រូវបានបញ្ជូនមកដល់កម្ពុជារួចហើយនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០។[12] ការផ្តល់ជំនួយជារថយន្តយោធារបស់សាធារណរដ្ឋប្រជាមានិតចិននេះត្រូវបានធ្វើឡើងរយៈពេលមិនដល់ ១ ខែក្រោយពេលដែលសហរដ្ឋអាម៉េរិកបានលុបចោលកិច្ចព្រមព្រៀងផ្តល់ជំនួយរថយន្តស្រដៀងគ្នានេះដល់កម្ពុជា។[13]

[12] RFI, "ចិនផ្តល់ជំនួយសម្ភារៈយោធាលើកទី២ដល់កម្ពុជា", ចុះផ្សាយថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១

[13] ភ្នំពេញប៉ុស្តិ៍, "រថយន្តយោធាជំនួយរបស់ចិនចំនួន ២៥៧ គ្រឿងមកដល់ភ្នំពេញ", ចុះផ្សាយថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០១០



ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការយោធារវាងកម្ពុជានិងចិន នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១១ ក្រសួងការពារជាតិចិនបានផ្តល់ជំនួយធំលើកទី២ ខាងសម្ភារៈយោធាដល់ក្រសួងការពារជាតិកម្ពុជាដែលរួមមានសម្លៀកបំពាក់ ស្បែកជើងប្រយុទ្ធ មួក ខ្សែក្រវាត់ និងខ្សែព័ទ្ធឆៀង (Ceinturon) សរុបចំនួន ៥ ម៉ឺនសម្រាប់ ដើម្បីបំពាក់ឱ្យកងទ័ពកម្ពុជា ៥ម៉ឺននាក់។[14]



ក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងចំនួន២៩ ដែលប្រទេសទាំងពីរបានធ្វើកាលពីថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១១ ប្រទេសចិនបានយល់ព្រមឱ្យកម្ពុជាខ្ចីប្រាក់ប្រមាណ១៩៥លានដុល្លារអាម៉េរិកដើម្បីទិញឧទ្ធម្ភាគចក្រប្រភេទ Z-9 ចំនួន១២គ្រឿងពីប្រទេសចិន[15] ហើយត្រូវបានផ្តល់មកឱ្យកម្ពុជានៅដើមខែមករា ឆ្នាំ២០១៣។ [16] ក្នុងខែមករាដដែលនោះ កម្ពុជា-ចិនក៏បានចុះកិច្ចព្រមព្រៀង

[14] RFI, "ចិនផ្តល់ជំនួយសម្ភារៈយោធាលើកទី២ដល់កម្ពុជា", ចុះផ្សាយថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១

[15] កោះសន្តិភាព, "ចិនឱ្យកម្ពុជាខ្ចីប្រាក់១៩៥លានដុល្លារ ទិញឧទ្ធម្ភាគចក្រយោធារបស់ខ្លួន" ចុះផ្សាយថ្ងៃទី២៣ ខែសីហា ឆ្នាំ ២០១១

[16] VOA, "ទំនាក់ទំនងយោធារវាងកម្ពុជានិងចិនមានសន្ទុះខ្លាំង» " ចុះផ្សាយថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥

ដើម្បីបង្កើតជំនួយបណ្តុះបណ្តាលនិងគ្រឿងបរិក្ខារ ហើយក្រោយមក ចិនបានផ្តល់ជំនួយរថយន្ត ២៦ គ្រឿង និងឯកសណ្ឋានយោធា ៣ ម៉ឺនសម្រាប់ ដល់យោធាកម្ពុជា។ [17]



ក្នុងឱកាសនៃដំណើរទស្សនកិច្ចរបស់ឯកឧត្តម កូ ពូសុង អនុប្រធានគណៈកម្មការយោធាមជ្ឈិមបក្សចិន ដែលអញ្ជើញមកធ្វើទស្សនកិច្ចនៅកម្ពុជា ប្រទេសចិនបានប្រគល់រថយន្ត ៤៦គ្រឿង ដល់ក្រសួងការពារជាតិកម្ពុជា។

នៅខែឧសភា ឆ្នាំ២០១២ មេដឹកនាំចិនបានចុះហត្ថលេខាផ្តល់ជំនួយយោធាដែលមានទំហំទឹកប្រាក់ ២០លានដុល្លារសហរដ្ឋអាម៉េរិក សម្រាប់ការសាងសង់សាលាយោធា និងមន្ទីរពេទ្យយោធា និងបានបន្តទទួលយកកម្លាំងយោធារបស់កម្ពុជា ទៅបណ្តុះបណ្តាលនៅប្រទេសចិនថែមទៀតផង។ មួយខែក្រោយមក សាធារណរដ្ឋប្រជាមានិតចិនក៏បានផ្តល់ប្រាក់កម្ចីចំនួន ៤៣០លានដុល្លារដល់កម្ពុជាបន្ថែមទៀត។ [18] នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤ ប្រទេសចិនក៏បានផ្តល់នូវ រថយន្តចំនួន ២៦ គ្រឿង និងឯកសណ្ឋានយោធា ៣០,០០០សម្រាប់ ដល់ប្រទេសកម្ពុជា។

ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៥ ក្នុងគោលបំណងបង្កើនជំនាញយោធាជូនកងយោធពលខេមរភូមិន្ទ រដ្ឋាភិបាលចិនបានប្រគល់ជំនួយយោធាដល់រាជរដ្ឋាភិបាលកម្ពុជារួមមាន យានយន្តយោធាចំនួន ៤៤គ្រឿងដែលក្នុងនោះមានរថយន្តហ្ស៊ីប រថយន្តមានជើងទម្រ៉ុកកែត[19] ជណ្តើរយន្ត ២០ រថយន្តផ្ទះបាយ ៤ គ្រឿង ផ្ទះបាយចល័ត៤ គ្រឿងបន្លាស់យានយន្តផ្សេងៗចំនួន ១២២ (១ម៉ឺនគីឡូក្រាម) សារធាតុគីមី ១០ ប្រភេទទម្ងន់ ២១០៩ គីឡូក្រាម (ចំនួន ៧០ ប្រអប់) កាំភ្លើងធំ និងកាំភ្លើងប្រឆាំងយន្តហោះ ៨ គ្រឿងនិងអគាររោងជាង ៥០០ ម៉ែត្រការ៉េ។ ជំនួយជាសម្ភារៈយោធារបស់ចិននេះ បានជួយលើកកម្ពស់ជំនាញយោធាជូនកងយោធពលខេមរភូមិន្ទសម្រាប់ក្សាអធិបតេយ្យទឹកដី និងបង្ការអន្តោ

[17] ភ្នំពេញប៉ុស្ដិ៍, "ចិនផ្តល់ជំនួយយោធាដល់រដ្ឋាភិបាលកម្ពុជា" ចុះផ្សាយថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥
[18] RFA, «ប្រវត្តិសង្ខេបនៃទំនាក់ទំនងកម្ពុជា និងចិន (ភាគបញ្ចប់)», ចុះផ្សាយថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦
[19] Cambodia Daily, "ប្រទេសចិនផ្តល់អាវុធធុនធ្ងន់ឲ្យយោធាប្រទេសកម្ពុជា" ចុះផ្សាយថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥

ប្រវេសន៍ខុសច្បាប់ ការនេសាទខុសច្បាប់ ការជួញដូរមនុស្ស ថ្នាំញៀន និងអាវុធខុសច្បាប់ ហើយនិង ចូលរួមចំណែកពង្រឹងការសង្គ្រោះក្នុងគ្រោះមហន្តរាយ។[20]





ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៥ ដំណើរទស្សនកិច្ចរបស់រដ្ឋមន្ត្រីការពារជាតិកម្ពុជា ទៅកាន់ សាធារណរដ្ឋប្រជាមានិតចិន បានជួយពង្រឹងទំនាក់ទំនងយ៉ាងជិតស្និទ្ធថែមទៀតលើវិស័យការពារជាតិ រវាងកម្ពុជា និងចិន ដោយប្រទេសចិនបានផ្តល់ជំនួយយោធាជាច្រើន រួមទាំងការបណ្តុះបណ្តាល និង សម្ភារៈយោធាផងដែរ។[21]

ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥ នៅក្រោយពីកិច្ចប្រជុំរវាងរដ្ឋមន្ត្រីការពារជាតិនៃប្រទេសទាំងពីរ កាលពីថ្ងៃទី ៦ ខែវិច្ឆិកា នៅរាជធានីភ្នំពេញ កម្ពុជា-ចិន បានព្រមព្រៀងបង្កើនទំនាក់ទំនងខាងយោធា បន្ថែម ហើយប្រទេសចិនបានផ្តល់ជំនួយយោធាបន្ថែមមានដូចជាគ្រឿងបរិក្ខារទូរគមនាគមន៍និងវិទ្យុ ដើម្បីបង្កើនសមត្ថភាពរបស់ប្រទេសកម្ពុជា ក្នុងការទាក់ទងទីស្នាក់ការកណ្តាលបញ្ជាការដ្ឋាននៅទូទាំង

[20] ភ្នំពេញប៉ុស្តិ៍, "ចិនផ្តល់ជំនួយយោធាដល់រដ្ឋាភិបាលកម្ពុជា" ចុះផ្សាយថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥

[21] VOA, "ទំនាក់ទំនងយោធារវាងកម្ពុជានិងចិនមានសន្ទុះខ្លាំង» " ចុះផ្សាយថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥

ប្រទេស។ ជំនួយនេះ ក៏រាប់បញ្ចូលទាំងជំនួយខាងការបណ្តុះបណ្តាល និង សាងសង់សាលាយោធា ព្រម ទាំងការបង្កើនលំហាត់និងការផ្លាស់ប្តូរកម្មសិក្សាកងទ័ពផងដែរ។ [22]

នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន និងក្រសួងការពារ ជាតិកម្ពុជា បានសម្ពោធយានដ្ឋានជួសជុលយានយន្តជាជំនួយរបស់កងទ័ពរំដោះប្រជាជនចិន នៅកង ពលតូចលេខ៩៩ ដែលយានដ្ឋាននេះត្រូវបានសាងសង់អស់រយៈពេល២ឆ្នាំ(២០១៤-២០១៦)។

ក្នុងជំនួបពិភាក្សា ការងាររវាងឯកឧត្តមប្រធានាធិបតីចិន ស៊ី ជិនពីង និងសម្តេចអគ្គមហា សេនាបតីតេជោ ហ៊ុន សែន នាទីក្រុងប៉េកាំង ប្រទេសចិន នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ ប្រធានាធា ធិបតីចិន លោក ស៊ី ជិនពីង បានប្រកាសផ្តល់ជំនួយ ជាង ៦៥ លានដុល្លារអាមេរិក សម្រាប់ជួយពង្រឹក សមត្ថភាពរបស់មន្ទីរពេទ្យយោធាកម្ពុជា ដើម្បីជួយដល់អតីតយុទ្ធជន និងប្រជាពលរដ្ឋទូទៅ នៅក្នុងឆ្នាំ ២០១៧។ [23]

នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៨ សម្តេចពិជ័យសេនា ទៀ បាញ់ រដ្ឋមន្ត្រីការពារជាតិនៃព្រះ រាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូយោធាជាន់ខ្ពស់ចូលរួមពិធីចុះហត្ថលេខាលើពិធីសារ ជាមួយ ឯកឧត្តមនាយឧត្តមសេនីយ៍ WEI FENG HE សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួង ការពារជាតិ នៃសាធារណរដ្ឋប្រជាមានិតចិន ស្តីអំពីការផ្តល់ជំនួយយោធាឥតសំណងរបស់ចិនជូនដល់ កម្ពុជា នៅទីស្តីការក្រសួងការពារប្រទេស នាទីក្រុងប៉េកាំង។[24] ជាមួយគ្នានោះដែរ រដ្ឋមន្ត្រីក្រសួងការ ពារប្រទេសចិន បានបញ្ជាក់ថា នឹងបន្តជំរុញការរក្សាផ្លាស់ប្តូរ ប្រតិភូជាន់ខ្ពស់រវាងកងទ័ពទាំងពីរជាបន្ត ទៅទៀត បន្តជួយកសាងសង់វិទ្យាស្ថានទ័ពជើងគោកថ្លុកតាសេក រួមទាំងបន្តជួយហ្វឹកហ្វឺននិងបណ្តុះ បណ្តាលធនធានយោធាកម្ពុជាផងដែរ។

ទំនាក់ទំនងយោធារវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន បានឈាន ទៅដល់ចំណុចកំពូលមួយ នៅបន្ទាប់ពីប្រទេសទាំងពីរបានរៀបចំលំហាត់សមយុទ្ធយោធារួមគ្នាឈ្មោះ ថា «សមយុទ្ធនាគមាស» ចំនួន ៣ លើក។ សមយុទ្ធនាគមាស លើកទី១ ត្រូវបានរៀបចំឡើងនៅខេត្ត កំពង់ស្ពឺ នាព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ នៅឯវិទ្យាស្ថានកងទ័ពជើងគោក ក្នុងខេត្តកំពង់ស្ពឺ ដែល មានការឧបត្ថម្ភទាំងផ្នែកបរិក្ខារ និងបច្ចេកទេសយោធាយ៉ាងច្រើនសន្ធឹកសន្ធាប់ពីសំណាក់ប្រទេសចិន តាំងពីឆ្នាំ២០០០មក។ ដើម្បីផ្លាស់ប្តូរបទពិសោធ និងកសាងសមត្ថភាពកងទ័ពឱ្យទទួលបានជំនាញថ្មី

---

22 THE DEPLOMAT, "China Pledges New Military Aid to Cambodia" release on November 10, 2015

23 CEN, "ចិន ប្រកាសផ្តល់ជំនួយជាង ២៣០ លានដុល្លារ សម្រាប់អភិវឌ្ឍន៍ និងពង្រឹកសមត្ថភាព មន្ទីរពេទ្យយោធាកម្ពុជា" ចុះផ្សាយថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧

24 ក្រសួងការពារជាតិ, "សម្តេចពិជ័យសេនា ទៀ បាញ់ ជួបពិភាក្សាការងារទ្វេភាគីជាមួយ រដ្ឋមន្ត្រីក្រសួងការពារជាតិចិន", ចេញផ្សាយថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨

បន្ថែមទៀតលើកិច្ចការ មនុស្សធម៌ ការសង្គ្រោះជីវិតក្នុងពេលជួបគ្រោះមហន្តរាយនានា ជាពិសេសការផ្សារភ្ជាប់កិច្ចសហប្រតិបត្តិការ រឹតចំណងមេត្រីភាព រវាងកងទ័ពប្រទេសទាំងពីរ។[25]

វាជាសមិទ្ធផលថ្មីមួយទៀត ក្នុងនាមដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនៃទំនាក់ទំនងការទូតយោធារវាងកម្ពុជា និងចិន។ សមយុទ្ធនេះមានការចូលរួមពីសំណាងកងយោធពលខេមរភូមិន្ទចំនួនជាង ៥០០នាក់ និងកងទ័ពរំដោះប្រជាជនចិនជាង ១០០នាក់។[26]

សមយុទ្ធនេះ មានរបៀបវារៈចំនួន៦ ក្នុងនោះរួមមានសមយុទ្ធបែបជួសជុលផ្លូវបន្ទាន់ សមយុទ្ធស្រាវជ្រាវមីន និងកម្ទេចយុទ្ធភណ្ឌមិនទាន់ផ្ទុះ សមយុទ្ធដំឡើង និងស្ថាបនាស្ពាន បែបមេកានិច និងផ្លូវថ្មើរជើង សមយុទ្ធទប់ទំនប់ទឹក សមយុទ្ធការសង្គ្រោះជនរងគ្រោះ ពីទឹកជំនន់ និងការព្យាបាលប្រជាពលរដ្ឋចេញពីគ្រោះធម្មជាតិជាដើម។[27]





*ទិដ្ឋភាពក្នុងសមយុទ្ធនាគមាស រវាងយោធាកម្ពុជានិងយោធាចិននាពេលកន្លងមក*

[25] Fresh News, "សមយុទ្ធ «នាគមាស ២០១៦» រវាងកងទ័ពកម្ពុជា-ចិន បានចាប់ផ្តើម នៅខេត្តកំពង់ស្ពឺ", ចុះផ្សាយថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ២០១៦

[26] អាស៊ីសេរី, "កម្ពុជា-ចិនបន្តជាប់ពង្រឹងចំណងការទូតយោធាបន្ថែមទៀតក្នុងពិធីបិទលំហាត់យោធា" ចុះផ្សាយថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦

[27] Khmer Times, "យោធាកម្ពុជា-ចិន នឹងធ្វើសមយុទ្ធរួមគ្នាទ្រង់ទ្រាយធំមិនធ្លាប់មានពីមុន" ចុះផ្សាយថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០១៦

ក្រោយពីបានធ្វើសមយុទ្ធយោធារួមគ្នាជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិន នៅចុងឆ្នាំ ២០១៦រួច នៅដើមឆ្នាំ២០១៧ ក្រសួងការពារជាតិកម្ពុជា បានសម្រេចផ្អាកសមយុទ្ធនេះ សម្រាប់ឆ្នាំ ២០១៧ និង២០១៨ ដោយអះអាងថាបណ្តាលមកពីកម្ពុជាត្រូវមមាញឹកក្នុងការប្រយុទ្ធប្រឆាំងការប្រើប្រាស់និងជួញដូរគ្រឿងញៀន និងការត្រៀមការពារដំណើរការរៀបចំបោះឆ្នោត ឃុំ សង្កាត់ និងបោះឆ្នោតថ្នាក់ជាតិ។ [28]

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រសួងការពារជាតិចិនបានសម្រេចផ្តល់រថពាសដែកជិត ១០០ គ្រឿង និងគ្រឿងចក្រមួយចំនួនដល់ក្រសួងការពារជាតិកម្ពុជាដែលជាជំនួយឥតសំណងដែលត្រូវបានដឹកមកដល់កម្ពុជានៅក្នុងខែមីនា ឆ្នាំ២០១៨ ស្របពេលដែលភាគីទាំង ២ រៀបចំធ្វើសមយុទ្ធនាគមាសជាលើកទី ២ ជាមួយគ្នានៅកម្ពុជា។[29]

លំហាត់សមយុទ្ធនាគមាសលើកទី២ ត្រូវបានរៀបចំឡើងរយៈពេល១៥ថ្ងៃ ពីថ្ងៃទី១៥ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ដើម្បីរឹតចំណងសាមគ្គីភាព មិត្តភាព និងអបអរសាទរខួប៦០ឆ្នាំ នៃទំនាក់ទំនងការទូតកម្ពុជា-ចិនដើម្បីពង្រឹងសហគមន៍វាសនារួមកម្ពុជា-ចិន ដែលមានសារៈសំខាន់ជាយុទ្ធសាស្រ្តយូរអង្វែង។ នៅក្នុងសមយុទ្ធនាគមាសលើកទី២នេះ ផ្តោតលើប្រធានបទពីរគឺ ប្រឆាំងភេរវកម្ម និងមនុស្សធម៌។ សព្វាវុធទំនើបៗជាច្រើនត្រូវបានប្រើប្រាសនៅក្នុងសមយុទ្ធនេះដែលរួមមាន យន្តហោះ Z10 បំពាក់កាំជ្រួចបាញ់ចំគោលដៅ, កាំភ្លើងត្បាល់ចូលគោលដៅដែលបានកំណត់, ប្រើប្រាស់រថពាសដែក និងទ័ពថ្មើរជើង, និងប្រើប្រាស់យន្តហោះចុះពីលើអាកាសដើម្បីរំដោះចំណាប់ខ្មាំងជាដើម។[30] នៅក្នុងសមយុទ្ធលើកទី២នេះ មានការចូលរួមពីសំណាក់យោធាកម្ពុជាចំនួន២៨០នាក់ និងយោធាចិនចំនួន១៩០នាក់។ សមយុទ្ធលើកទីពីរនេះក៏មានរាប់បញ្ចូលការបាញ់គ្រាប់ពិត តូចធំនានា សរុបប្រមាណ១៨.០០០គ្រាប់ រួមមានការបាញ់គ្រាប់រ៉ុក្កែតពីឧទ្ធម្ភាគចក្រការវាយប្រហារដោយរថពាសដែកថែមទៀតផង។ មេបញ្ជាការរងនៃកងទ័ពជើងគោកនៃកងទ័ពរំដោះប្រជាជនចិនដែលបានចូលរួមក្នុងសមយុទ្ធនេះ បានថ្លែងថា នៅក្នុងសមយុទ្ធនេះ *«ប្រទេសសម្ព័ន្ធមិត្តទាំងពីរចង់បង្ហាញប្រទេសខាងក្រៅថា ចិន និងកម្ពុជានឹងសហការគ្នាដើម្បីរក្សាសន្តិសុខ និងសន្តិភាព»*។[31]

---

[28] VOA, "ការលុបចោលសមយុទ្ធយោធាកម្ពុជា អាមេរិក ជាគម្លាតនិងការបត់បែនគោលនយោបាយ" ចុះផ្សាយថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧

[29] ភ្នំពេញប៉ុស្តិ៍, "លោក ហ៊ុន សែន អះអាងពីសព្វាវុធដែលត្រូវបានដឹកមកដល់កម្ពុជា ដើម្បីការពារជាតិ", ចុះផ្សាយថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨

[30] ដំណឹងពលរដ្ឋ, "កងទ័ពកម្ពុជា-ចិន ចាប់ផ្តើមលំហាត់សមយុទ្ធ "នាគមាសឆ្នាំ២០១៨"ហើយ នៅភ្នំធំម្រះព្រៅ, ចុះផ្សាយថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៨

[31] ភ្នំពេញប៉ុស្តិ៍, "កងទ័ពកម្ពុជា-ចិន បញ្ចប់សមយុទ្ធនាគមាសឆ្នាំ២០១៨ ជោគជ័យ ដោយបង្ហាញទំនាក់ទំនងយោធារឹងមាំ", ចុះផ្សាយថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨



*ទិដ្ឋភាពក្នុងសមយុទ្ធនាគមាស រវាងយោធាកម្ពុជានិងយោធាចិននាពេលកន្លងមក*

នៅក្នុងខែមិថុនា ឆ្នាំ២០១៨ ដំណើរទស្សនកិច្ចរបស់ឯកឧត្តម Wei Fenghe រដ្ឋមន្ត្រីការពារជាតិចិន នៅរាជធានីភ្នំពេញ ភាគីចិនបានចុះហត្ថលេខា ផ្តល់ជំនួយយោធាក្នុងតម្លៃទឹកប្រាក់ប្រមាណ ១០០លានដុល្លារអាម៉េរិកបន្ថែមដល់កម្ពុជា។

នៅឆ្នាំ២០១៩ លំហាត់សមយុទ្ធនាគមាសលើកទី៣ ត្រូវបានធ្វើឡើងរវាងយោធាកម្ពុជា និងយោធាចិន ដែលសមយុទ្ធលើកនេះមានរយៈពេល២៨ថ្ងៃ ដោយចាប់ផ្តើមពីថ្ងៃទី២៨ ខែកុម្ភៈ និងបញ្ចប់នៅថ្ងៃទី២៧ខែមីនា ហើយក៏ជាសមយុទ្ធដែលមានរយៈពេលយូរជាង និងធំជាងការធ្វើលំហាត់សមយុទ្ធទាំងពីរលើកដំបូងផងដែរ។ ទោះជាយ៉ាងណា នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ទើបលំហាត់សមយុទ្ធនេះត្រូវបានប្រកាសពិធីបើកជាផ្លូវការ។[32] សមយុទ្ធដ៏ធំលើកទី៣នេះ មានគោលដៅកសាងសមត្ថភាព និងជួយឱ្យមេដឹកនាំនៃប្រទេសទាំងពីររក្សាចំណេះដឹងទាន់សភាពការណ៍នៃដំណើរវិវត្តចុងក្រោយនៃបច្ចេកទេស និងបច្ចេកវិទ្យាថ្មី ដើម្បីគោលបំណងបន្សាំកងកម្លាំងទៅនឹងការងារប្រយុទ្ធប្រឆាំងភេរវកម្ម វិស្វកម្មយោធា និងកិច្ចការងារមនុស្សធម៌។ លំហាត់សមយុទ្ធនេះ មានការចូលរួមពីកងទ័ពរំដោះប្រជាជនចិនចំនួន ២៥២នាក់ និងកងទ័ពកម្ពុជាចំនួន ២.៥៤២នាក់ នេះបើយោងតាមការបញ្ជាក់របស់ អគ្គមេបញ្ជាការរងនិងជានាយសេនាធិការចម្រុះ នៃកងយោធពលខេមរភូមិន្ទ។ ចំណែកឯគ្រឿង

[32] RFI, "ឧទ្ធម្ភាគចក្រចិន៦គ្រឿង បានមកដល់កម្ពុជា ដើម្បីត្រៀមចូលរួមសមយុទ្ធនាគមាសឆ្នាំ២០១៩", ចុះផ្សាយថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៩

សព្វាវុធដែលត្រូវបានប្រើប្រាស់សម្រាប់ការធ្វើសមយុទ្ធនេះ រួមមាន ឧទ្ធម្ភាគចក្រ Mi 17, ឧទ្ធម្ភាគចក្រ Z9, រថពាសដែក រថក្រោះ កាំភ្លើងធំ កាំភ្លើងត្បាល់ប្រភេទ៦០មីលីម៉ែត្រ ៨២មីលីម៉ែត្រ និង១០០មីលីម៉ែត្រ អាវុធគាំទ្រពីលើអាកាស និងយន្តហោះគ្មានមនុស្សបើក (Drone) ជាដើម។[33] សមយុទ្ធឆ្នាំ២០១៩ នេះ បានកំណត់យកប្រធានបទការប្រឆាំងភេរវកម្ម និងមនុស្សធម៌ ដែលមានខ្លឹមសារ និងវិធីសាស្ត្រ រួមមាន៖ ទី១ លំហាត់ទីបញ្ជាការចាត់តាំងក្នុងរូបភាពវរសេនាតូច ប្រយុទ្ធប្រឆាំងភេរវកម្មរួមគ្នា ការធ្វើផែនការថ្នាក់វរសេនាតូច ការដាក់ចេញនូវសេចក្ដីប្ដេជ្ញាចិត្តប្រយុទ្ធ ការរៀបចំប្រព័ន្ធបញ្ជា ការបញ្ជាសមយុទ្ធ នៅលើតុ និងការបញ្ជាប្រតិបត្តិការប្រឆាំងភេរកម្ម។ និងទី២ លំហាត់លើទីលាន រួមមាន ការឃ្លាំមើល សង្កេតស៊ើបការណ៍ ការឡោមព័ទ្ធ ការសហការវាយលុក ការវាយកម្ទេចជាដំណាក់កាល ការរំដោះចំណាប់ខ្មាំង ការបោសសម្អាត កម្ទេចជុំរុំភេរវករ និងការងារមនុស្សធម៌ ការសង្គ្រោះប្រជាពលរដ្ឋពីគ្រោះធម្មជាតិ ការបំពេញភារកិច្ចក្រោមឆត្រអង្គការសហប្រជាជាតិ និងវិស្វកម្មជាដើម។ នៅក្នុងសមយុទ្ធរយៈពេលជិត១ខែនេះ កងកម្លាំងនៃភាគីទាំងពីរ ក៏បានហ្វឹកហាត់ជំនាញ ប្រឆាំងភេរវករដោយសកម្មភាព ហ្វឹកហាត់នោះលើ ជំនាញកម្លាំងប្រយុទ្ធ កម្លាំងបម្រើប្រយុទ្ធ ហ្វឹកហាត់បច្ចេកទេសសម្រូតខ្លួន តាមខ្សែពួជធំចុះពីឧទ្ធម្ភាគប្រក ដើម្បីជួយរំដោះចំណាប់ខ្មាំង ពីជំរំភេរវកររចេញពី អគារខ្ពស់ៗ និងច្រើន ការស៊ើបការណ៍រកភូមិសាស្ត្រ ដោយយន្តហោះគ្មានមនុស្សបើក (Drone), ការដោះមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ, ការដោះគ្រាប់បែកគីមី និងបន្សាបជាតិគីមី, ប្រតិបត្តិការរំដោះចំណាប់ខ្មាំងដោយឧត្តម្ភាគចក្រ, ឧទ្ធម្ភាគចក្រកម្ទេចជំរំភេរករ និងកិច្ចការមនុស្សធម៌ជាដើម ។[34]




[33] ដើមអម្ពិល, "នាយឧត្តមសេនីយ៍ ឈុំ សុជាតិ៖ លំហាត់នាគមាស ឆ្នាំ២០១៩ រវាងកងទ័ពកម្ពុជា-ចិន នឹងបញ្ចប់ដោយជោគជ័យ តាមផែនការ", ចុះផ្សាយថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩

[34] ដើមអម្ពិល, "សមយុទ្ធនាគមាសឆ្នាំ២០១៩ រវាងកងទ័ពកម្ពុជា-ចិន ត្រូវបានបិទបញ្ចប់ ជាផ្លូវការនៅព្រឹកនេះ", ចុះផ្សាយថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩




គួរបញ្ជាក់ផងដែរថា សមយុទ្ធនាគមាសលើកទី៣នេះ ត្រូវបានគេមើលឃើញថា ធ្វើឡើងតែប៉ុន្មានខែប៉ុណ្ណោះបន្ទាប់ពីនៅរបាយការណ៍សរុបការងារប្រចាំឆ្នាំ២០១៨ នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានបង្ហាញថា បណ្ដាប្រទេសជិតខាងកម្ពុជានៅតែបញ្ចេញសកម្មភាពដែលរំលោភបំពានលើបូរណភាពទឹកដីកម្ពុជា តាមខ្សែបន្ទាត់ព្រំដែន។ ពេញមួយឆ្នាំ២០១៨កន្លងទៅ មានការហោះហើររបស់កងទ័ពថៃរំលោភលើដែនអាកាសកម្ពុជា ចំនួនសរុប១៤៦លើក។ ខាងវៀតណាមបានធ្វើសកម្មភាពចាក់បេតុងសង់បង្គោលអគ្គីសនី៦ដើម កាលពីខែកក្កដា កន្លងទៅ នៅក្នុងតំបន់សមុទ្រចំណុចជិតមួយគីឡូម៉ែត្រពីខ្សែទឹកប្រវត្តិសាស្ត្រកម្ពុជា-វៀតណាម ក្នុងខេត្តកំពតរបស់កម្ពុជា ដែលរបាយការណ៍បានបញ្ជាក់ថាវៀតណាមបានបញ្ឈប់សកម្មភាពនេះហើយ ខណៈដែលព្រំដែនជាមួយប្រទេសឡាវរបាយការណ៍បានបញ្ជាក់ថា ខាងយោធាឡាវបានឈូសឆាយផ្លូវ ចម្ងាយពី០៨ ម៉ែត្រ ទៅ ២៥ ម៉ែត្រ ចូលក្នុងទឹកដីកម្ពុជា នៅត្រង់ពី០២ចំណុច ចន្លោះបង្គោលលេខ៤១ និងលេខ៤២។[35]

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៩ ក្នុងឱកាសអញ្ជើញចូលរួមពិធីបើកការប្រកួតកីឡាយោធាពិភពលោកលើកទី៧ នៅទីក្រុងអ៊ូហាន គណៈប្រតិភូក្រសួងការពារជាតិកម្ពុជាដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីការពារជាតិចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្ដីកិច្ចសហប្រតិបត្តិការ រវាងកងទ័ពប្រទេសទាំងពីរ កម្ពុជា-ចិន។ ក្នុងឱកាសនោះ រដ្ឋមន្ត្រីការពារជាតិចិន ក៏បានគូសបញ្ជាក់ថា ទំនាក់ទំនងកម្ពុជា-ចិន គឺជាមិត្តភាពដែកថែប ហើយទំនាក់ទំនងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរបានស្ថិតនៅក្នុងកម្រិតខ្ពស់ជាងគេក្នុងប្រវត្តិសាស្ត្រ ជាមួយនឹងការសន្យាថា ចិននឹងនៅតែបន្តផ្ដល់ជំនួយនិងការគាំទ្រដល់ការកសាងកងទ័ព និងការអភិវឌ្ឍវិស័យការពារជាតិ របស់កម្ពុជា។[36]

---

[35] VOA, "វិភាគ៖ សមយុទ្ធ«នាគមាស»បំពេញប្រយោជន៍យុទ្ធសាស្ត្រឱ្យកម្ពុជានិងចិន", ចុះផ្សាយថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩

[36] Fresh News, "រដ្ឋមន្ត្រីការពារជាតិកម្ពុជា-ចិន ចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីកិច្ចសហប្រតិបត្តិការរវាងកងទ័ពប្រទេសទាំងពីរ នៅទីក្រុងប៉េកាំង", ចុះផ្សាយថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩

## ២. ទំហំវិនិយោគ និងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ

យោងតាមការរកឃើញនៃការអង្កេតដ៏ទូលំទូលាយលើ ការវិនិយោគដោយផ្ទាល់ពីក្រៅប្រទេស (FDI) ធ្វើឡើងដោយធនាគារជាតិនៃកម្ពុជា (NBC) និងវិទ្យាស្ថានជាតិស្ថិតិ (NIS) ប្រទេសចិនជាប្រទេសវិនិយោគធំជាងគេនៅក្នុងប្រទេសកម្ពុជា ដែលមានចំនួនរហូតដល់៤៤ភាគរយនៃការវិនិយោគផ្ទាល់ពីបរទេសក្នុងទឹកប្រាក់ ១៩,២ ពាន់លានដុល្លារ គិតពីចន្លោះពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០១៤។[37]

ដោយផ្អែកលើទំនាក់ទំនងជាមិត្តភាព ការគាំទ្រគ្នាទៅវិញទៅមក និងភាពជិតស្និទ្ធគ្នារវាងរដ្ឋាភិបាលនិងរដ្ឋាភិបាល ចំណងទំនាក់ទំនងទ្វេភាគីនេះបានរីកចម្រើនជាបន្តបន្ទាប់នាប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ហើយបានធ្វើឱ្យទំហំពាណិជ្ជកម្មសរុបរវាងកម្ពុជានិងចិនបានកើនឡើងយ៉ាងឆាប់រហ័សដែលសម្រេចបានជាមធ្យម២៦%ក្នុងមួយឆ្នាំៗ ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។

វិនិយោគផ្លូវការរបស់ចិននៅក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា មានទំហំសរុប ២.២១៩.៩១៤.៥២០ ដុល្លារអាម៉េរិក ដោយគិតចាប់តាំងពីការចាប់ផ្តើមការវិនិយោគដំបូងរបស់ចិន នៅក្នុងឆ្នាំ ២០០៤ ហើយតួលេខនេះបានធ្វើឱ្យចិនក្លាយទៅជាប្រភពវិនិយោគទុនបរទេសដ៏ធំបំផុតនៅកម្ពុជា ដែលទំហំវិនិយោគនេះកើនដល់ ៤,៩២ ពាន់លានដុល្លារអាម៉េរិកនៅចន្លោះពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៥។[38] ឆ្នាំ ២០១៥ ទំហំពាណិជ្ជកម្មទ្វេភាគីមានដល់ទៅ ៤.៣២០លានដុល្លារអាម៉េរិក។ [39] ជារៀងរាល់ថ្ងៃមានជើងយន្តហោះចំនួន៣៥ ធ្វើការហោះហើរទៅមករវាងប្រទេសចិន និងកម្ពុជា ហើយក្នុងនោះមានទីក្រុងរបស់ប្រទេសចិនជាង១០ ដែលមានជើងហោះហើរមកកាន់កម្ពុជាដោយផ្ទាល់។[40]

ក្នុងឆ្នាំ២០១៦ ពាណិជ្ជកម្មទ្វេភាគីបានកើនដល់៤,៨ ប៊ីលានដុល្លារអាម៉េរិក ក្នុងនោះការនាំចេញរបស់កម្ពុជា មានទំហំ៨៣០លានដុល្លារអាម៉េរិក និងការនាំចូលមានប្រមាណ៣,៩ប៊ីលានដុល្លារអាម៉េរិក។ ចិនជាប្រទេសវិនិយោគធំជាងគេបំផុតនៅកម្ពុជា ដែលគិតពីដើមទសវត្សរ៍ទី៩០ ដល់ឆ្នាំ ២០១៨ ទំហំវិនិយោគរបស់ចិនមានទឹកប្រាក់ជាង១៧ពាន់លានដុល្លារអាម៉េរិក។ អ្នកវិនិយោគចិនវិនិយោគលើវិស័យមួយចំនួន រួមមាន កម្មន្តសាល សំណង់ វាយនភ័ណ្ឌ និងថាមពលអគ្គិសនី និងប៉ុន្មានឆ្នាំចុងក្រោយនេះចិនវិនិយោគលើវិស័យសំណង់ និងអចលវត្ថុកម្ពុជាឈានមុខគេ។ [41]

គិតត្រឹមឆ្នាំ២០១៦ ចិនបានអនុវត្តគម្រោងធំៗចំនួន១០ នៅកម្ពុជា ដែលសុទ្ធសឹងជាគម្រោងដែលប្រើប្រាស់ប្រាក់កម្ចីពីចិន និងដែលមានទឹកប្រាក់ចាប់ពីជាង ៧៩លានដុល្លារ រហូតដល់ ជាង

---

[37] ភ្នំពេញប៉ុស្តិ៍, "L.Y.P គ្រោងសង់ទីក្រុងចិនមួយនៅកម្ពុជា", ចុះផ្សាយថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦

[38] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC). បរិយាកាសវិនិយោគនៅកម្ពុជា. និន្នាការការអភិវឌ្ឍ

[39] Fresh News, «តើកម្ពុជា-ចិន ភ្ជាប់ទំនាក់ទំនងពីពេលណា? សមិទ្ធផលអ្វីខ្លះកើតចេញពីទំនាក់ទំនងនេះ?», ចុះផ្សាយថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦

[40] គេហទំព័រគណបក្សប្រជាជនកម្ពុជា, "ទំនាក់ទំនងរវាងប្រទេសកម្ពុជា និងចិន", ចេញផ្សាយថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦

[41] Property Area, «ហេតុអីចិនវិនិយោគច្រើននៅកម្ពុជា? តោះស្វែងយល់ពីទំនាក់ទំនងកម្ពុជា-ចិនជាមុនសិន» ចុះផ្សាយថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨

២៤២ លានដុល្លារអាម៉េរិករួមមាន ១.គម្រោងជួសជុលផ្លូវជាតិលេខ ៥៩ (កំរៀង-ភ្នំព្រឹក-សំពៅលូន-ម៉ាឡៃ-កូនដំរី) ដែលមានទឹកប្រាក់ជាង ៧៩ លានដុល្លារអាម៉េរិក, ២.គម្រោងពង្រីកប្រវែងផ្លូវជាតិលេខ ៧៦ ដែលមានទឹកប្រាក់ ជាង ៨៩ លានដុល្លារអាម៉េរិក, ៣.គម្រោងពង្រីកបណ្ដាញអគ្គិសនីទៅតាមទីជនបទ ជំហានទី៣ និងទី៤ ដែលមានទឹកប្រាក់ជាង៩៤ លានដុល្លារអាម៉េរិក, ៤.គម្រោងជួសជុលផ្លូវជាតិលេខ ៥៧ បេ ដែលមានទឹកប្រាក់ជាង ៩៨ លានដុល្លារអាម៉េរិក, ៥.គម្រោងអភិវឌ្ឍន៍ទំនប់ក្នុងគោលដៅច្រើនយ៉ាង(សម្រាប់វិស័យកសិកម្មនៅខេត្តបាត់ដំបង) ដែលមានទឹកប្រាក់ជាង ៩៩ លានដុល្លារអាម៉េរិក, ៦.គម្រោងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រវ៉ៃគោ ជំហានទី១ ដែលមានទឹកប្រាក់ជាង ៩៩ លានដុល្លារអាម៉េរិក, ៧.គម្រោងសាងសង់ផ្លូវជាតិលេខ ២១៤ និងការស្ថាបនាស្ពានឆ្លងទន្លេមេគង្គស្ថិតក្នុងខេត្តស្ទឹងត្រែង ដែលមានទឹកប្រាក់ជាង ១១៣ លានដុល្លារអាម៉េរិក, ៨.គម្រោងសាងសង់ផ្លូវជាតិលេខ ៥៨ ដែលកាត់ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ មានទឹកប្រាក់ជាង ១១៩ លានដុល្លារអាម៉េរិក, ៩.គម្រោងគ្រប់គ្រងគ្រោះមហន្តរាយ និងប្រឆាំងភេរវកម្ម ដែលត្រូវអនុវត្តនៅទូទាំងប្រទេស និងមានទឹកប្រាក់ជាង ១៩២ លានដុល្លារអាម៉េរិក, និង១០.គម្រោងជួសជុលផ្លូវជាតិលេខ៦ (កំណាត់ផ្លូវពីថ្នល់កែង ទៅដល់អង្រ្គង) ដែលស្ថិតនៅក្នុងខេត្តកំពង់ចាម កំពង់ធំ សៀមរាប និងព្រះវិហារ និងមានទឹកប្រាក់ជាង ២៤២ លានដុល្លារអាម៉េរិក(បញ្ចប់ក្នុងខែមិថុនា ២០១៧)។[42]

ចាប់តាំងពីឆ្នាំ២០១៦ រហូតដល់ខែសីហា ឆ្នាំ២០១៩ ទុនវិនិយោគដោយផ្ទាល់ពីសាធារណរដ្ឋប្រជាមានិតចិនមកកាន់កម្ពុជា មានទំហំ ៧,៩ ប៊ីលានដុល្លារអាម៉េរិក ស្មើនឹង ៣៥% នៃទុនវិនិយោគពីបរទេស (FDI) សរុបរបស់កម្ពុជា ហើយការវិនិយោគរបស់ចិន មិនមែនត្រឹមតែវិនិយោគទៅលើវិស័យកាត់ដេរនិងស្បែកជើងប៉ុណ្ណោះទេ ប៉ុន្តែបានគ្របដណ្ដប់ស្ទើរគ្រប់វិស័យទាំងអស់ ពិសេសការវិនិយោគលើវិស័យវារីអគ្គិសនីដែលបច្ចុប្បន្នមានរហូតដល់ ៧កន្លែង ការវិនិយោគលើរោងចក្រអគ្គិសនីដុតដោយធ្យូងថ្ម គម្រោងសាងសង់ស្ថានីយ៍អគ្គិសនីដើរដោយប្រព័ន្ធព្រះអាទិត្យ ដែលមានលទ្ធភាពក្នុងការផ្ដល់អគ្គិសនីសរុបទំហំរហូតដល់ ១.៨៥០មេហ្គាវ៉ាត់។[43] សាធារណរដ្ឋប្រជាមានិតចិន ក៏បានធ្វើការវិនិយោគលើការសាងសង់ព្រលានយន្តហោះនៅខេត្តសៀមរាប ព្រលានយន្តហោះនៅខេត្តកោះកុង ដែលគម្រោងនៅខេត្តកោះកុងនេះ រួមមានកំពង់ផែ អាកាសយានដ្ឋាន និងទីក្រុងរណបមួយដែលមានទំហំប្រមាណ ៤៥.០០០ហិកតា ហើយបើតាមសមាគមសំណង់កម្ពុជាបានប៉ាន់ស្មានថា គម្រោងដែលហៅថា «គម្រោងសាកល្បង» ដែលមានតម្លៃជាទឹកប្រាក់សរុប៣.៨០០លានដុល្លារ និងអាកាសយានដ្ឋានដែលនឹងត្រូវបានសាងសង់ នឹងត្រូវទទួលស្វាគមន៍ភ្ញៀវប្រមាណ១០លាននាក់ក្នុងមួយឆ្នាំ។

នៅខែមករា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសអំពីគម្រោងអភិវឌ្ឍន៍ព្រលានយន្តហោះអន្តរជាតិថ្មីមួយនៅក្នុងស្រុកកណ្ដាលស្ទឹងខេត្តកណ្ដាល ដែលត្រូវបានវិនិយោគរួមគ្នារវាងវិនិ

[42] http://cdc.khmer.biz/projectlist/project_list_updated.asp?OtherDonor=29&status=0&UpdateFrom=1/1/2016&updateto=3/20/2016

[43] ដកស្រង់ពីបទបង្ហាញរបស់ឯកឧត្តម ជា វុទ្ធី អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងសន្និសីទសារព័ត៌មានមួយនៅទីស្ដីការ គណៈរដ្ឋមន្ត្រីនៅព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩

យោគិនក្នុងស្រុក និងក្រុមហ៊ុនរបស់ចិន ក្នុងចំនួនទឹកប្រាក់សរុប ១.៥០០លានដុល្លារអាម៉េរិក។ បន្ថែមពីលើនេះ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងសាធារណការនិងដឹកជញ្ជូនកម្ពុជា ក៏កំពុងតែធ្វើការចរចាជាមួយនឹងក្រុមហ៊ុនចិន ក្នុងការស្ថាបនាផ្លូវល្បឿនលឿនមួយខ្សែបន្ថែមទៀត ពីរាជធានីភ្នំពេញទៅទីក្រុងបាវិត ខេត្តស្វាយរៀង។ លើសពីនេះទៅទៀត ចិនក៏បានវិនិយោគនៅក្នុងវិស័យទូរគមនាគមន៍កម្ពុជាផងដែរ ដោយបានធ្វើការកប់ខ្សែកាបអុបទិចក្រោមដីប្រវែងប្រមាណ ២ម៉ឺនគីឡូម៉ែត្រ និងបណ្ដាញខ្សែកាបអុបទិចក្រោមបាតសមុទ្រ ដែលអាចឱ្យកម្ពុជាតភ្ជាប់ប្រព័ន្ធគមនាគមន៍របស់ខ្លួនទៅក្នុងតំបន់និងពិភពលោក និងក៏អាចជួយជំរុញដល់ការធ្វើពាណិជ្ជកម្មតាមបែប E-Commerce និង អភិបាលកិច្ចតាមបែប E-government ផងដែរ ហើយនេះក៏នឹងផ្តល់នូវលទ្ធភាពងាយស្រួលដល់ក្រុមហ៊ុនពីបរទេសដទៃទៀតសម្រាប់ធ្វើការដាក់ទុនវិនិយោគនៅកម្ពុជាផងដែរ។ [44]

ក្រុមហ៊ុនចិនក៏បាននាំមកនូវការវិនិយោគថ្មីផ្សេងទៀតនៅកម្ពុជា ដូចជាឧស្សាហកម្មផលិតកង់ គ្រឿងសង្ហារឹម គ្រឿងសម្រាប់តាំងបុណ្យគ្រិស្តម៉ាស។ ប៉ុន្មានឆ្នាំចុងក្រោយនេះ ការវិនិយោគចិនត្រូវបានពង្រីកពីរាជធានីភ្នំពេញទៅកាន់ខេត្តផ្សេងៗដូចជា ខេត្តកណ្ដាល កំពង់ស្ពឺ ព្រះសីហនុ ស្វាយរៀង និង តាកែវជាដើម។ ការវិនិយោគមកពីប្រទេសចិន ទៅខេត្តជាប់មាត់សមុទ្រដូចជាខេត្តព្រះសីហនុ ខេត្តកោះកុង និងខេត្តកំពត ដែលមានទំហំទឹកប្រាក់ ២,៦ពាន់លានដុល្លារអាម៉េរិក ស្មើនឹង ១១,៥% នៃទំហំ ក្នុងនោះនៅខេត្តកោះកុងមានទំហំទឹកប្រាក់ ៤៧១ លានដុល្លារអាម៉េរិក ខេត្តព្រះសីហនុមានទំហំទឹកប្រាក់ ២ ប៊ីលានដុល្លារអាម៉េរិក ស្មើនឹង៨,៩% នៃទុនវិនិយោគសរុប និងខេត្តកំពតទំហំទឹកប្រាក់ ១០០លានដុល្លារអាម៉េរិក ស្មើនឹង ០,៥% នៃទុនវិនិយោគសរុប។ គួរបញ្ជាក់ផងដែរថា កម្ពុជាបាននាំចេញកង់ទៅបរទេសសរុបប្រហែល ២លានកង់ក្នុង១ឆ្នាំ ស្មើនឹងជិត៤០០លានដុល្លារសហរដ្ឋអាម៉េរិក និងជាប់ចំណាត់ថ្នាក់លេខមួយក្នុងការនាំចេញកង់ទៅសហភាពអឺរ៉ុប។[45]

ជាមួយគ្នានេះដែរ ចិនក៏បានធ្វើការវិនិយោគដោយយកទិសដៅឆ្ពោះសំខាន់លើវិស័យជាច្រើនទៅកាន់តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុផងដែរ ប៉ុន្តែអ្វីដែលជាការគួរឱ្យកត់សម្គាល់នោះគឺ ក្រុមហ៊ុនចិនបានធ្វើការវិនិយោគលើឧស្សាហកម្មផលិតគ្រឿងសង្ហារឹម និងឈើក្តារក្រាលគេហដ្ឋានសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងជាពិសេសសម្រាប់ផ្គត់ផ្គង់ទៅកាន់ទីផ្សារអឺរ៉ុប ដែលទីផ្សារអឺរ៉ុបតម្រូវឱ្យប្រើប្រាស់ឈើដែលបានពីការដាំដុះ ជៀសវាងការកាប់បំផ្លាញព្រៃឈើ យកទៅធ្វើជាវត្ថុធាតុដើម ហើយដែលផលិតកម្មនេះ នឹងមានតម្រូវការឈើដែលបានពីការដុះ ក្នុងបរិមាណជិត១០ម៉ឺនម៉ែត្រគីបក្នុងមួយឆ្នាំ។

នៅឆ្នាំ២០១៨ គម្រោងទីក្រុងមិត្តភាពកម្ពុជា-ចិន ត្រូវបានចាប់ដំណើរការដោយមានការបោះទុនវិនិយោគរួមគ្នារវាងក្រុមហ៊ុនវិនិយោគចិនដ៏ល្បីល្បាញមួយដែលមានឈ្មោះថា ចុង មិញថូវ បាន

---

[44] ដកស្រង់ពីបទបង្ហាញរបស់ឯកឧត្តម ជា វុទ្ធី អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងសន្និសីទសារព័ត៌មានមួយនៅទីស្តីការ គណៈរដ្ឋមន្ត្រីនៅព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩

[45] ដដែល

បោះទុនវិនិយោគរួមគ្នាក្នុងទឹកប្រាក់ប្រមាណ ១.៥០០ លានដុល្លារអាម៉េរិក ជាមួយនឹងក្រុមហ៊ុនធំមួយនៅក្នុងស្រុក ដើម្បីបង្កើតឱ្យមានការសាងសង់ទីក្រុងមិត្តភាពកម្ពុជា-ចិន នៅលើផ្ទៃដីប្រមាណ ៥៥០ហិកតា ដែលស្ថិតនៅក្នុងតំបន់អភិវឌ្ឍន៍ទីក្រុងរណបថ្មីរបស់អ្នកឧកញ៉ា លី យ៉ុងផាត់ ក្នុងសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វារ ប្រមាណជាង ១០គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ គម្រោងវិនិយោគនេះគ្រោងនឹងសាងសង់សាលារៀន មន្ទីរពេទ្យ អគាររដ្ឋបាលរបស់រដ្ឋ អគារពាណិជ្ជកម្មធំៗ ខ្នាតអន្តរជាតិ ផ្សារទំនើប មជ្ឈមណ្ឌលដឹកជញ្ជូន ឡូជីស្ទីក សេនធ័រ កន្លែងតាំងពិព័រណ៍អន្តរជាតិ និងគម្រោងផ្សេងៗទៀតដែលមាននៅក្នុងទីក្រុងមិត្តភាពកម្ពុជា-ចិននេះ។[46] ហើយទីក្រុងមិត្តភាពកម្ពុជា-ចិននេះ នឹងក្លាយជានិមិត្តរូបមួយដែលបានឆ្លុះបញ្ចាំងអំពីទំនាក់ទំនងដ៏ល្អរវាងប្រទេសទាំងពីរ។

នៅចុងឆ្នាំ២០១៨ ក្រុមហ៊ុនធំៗចំនួន៣របស់ចិន ឈ្មោះ Empire World, Group Bauing និងក្រុមហ៊ុន CFMA បានចុះហត្ថលេខា វិនិយោគលើគម្រោងទីក្រុងរណបថ្មីមួយនៅក្រុងបាវិត ខេត្តស្វាយរៀង ដោយធ្វើការវិនិយោគរួមគ្នាជាមួយនឹងក្រុមហ៊ុនពីរផ្សេងទៀតរបស់កម្ពុជា ដើម្បីកសាងទីក្រុងរណបធំជាងគេនៅក្នុងក្រុងបាវិត[47] ខេត្តស្វាយរៀង។ គម្រោងនេះត្រូវបានបើកការដ្ឋាននៅថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៩ លើផ្ទៃដីសរុបជាង ១.០០០ ហិកតា[48] សម្រាប់ការអភិវឌ្ឍនៅដំណាក់កាលទីមួយលើផ្ទៃដី ៥៧ហិកតា ដោយក្នុងនោះមានដូចជា មជ្ឈមណ្ឌលកម្សាន្ត លំនៅឋាន សួនឧទ្យាន តំបន់ឧស្សាហកម្ម ផ្សារទំនើប អាហារដ្ឋាន កាស៊ីណូ អូតែល អគារសម្រាប់លក់ ដួល អគារបណ្តុះបណ្តាល កន្លែងលេងកីឡា និងអគារស្នាក់នៅដ៏ប្រណិតៗ ជាដើម ទីក្រុងរណបថ្មីនេះគ្រោងនឹងចំណាយពេលប្រមាណ ១៥ឆ្នាំ ដើម្បីបញ្ចប់ការសាងសង់។[49]

ក្រៅពីទីក្រុងរណបធំៗខាងលើនេះ ក្រុមហ៊ុនចិនបាននិងគ្រោងសាងសង់ទីក្រុងរណបនានានៅតាមបណ្តាខេត្តផ្សេងៗទៀត ដូចជា ក្រុងរណបចំនួន២នៅខេត្តកំពង់ចាម ក្រុងរណបចំនួន១នៅ

---

[46] ខេមបូណ្ឌមីស, "ទីក្រុងមិត្តភាពកម្ពុជា-ចិនវិនិយោគ១៥០០លានដុល្លារ កំពុងដំណើរការចាក់ដីដ៏កក្រើកទីតាំង!", ចុះផ្សាយថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨

[47] ក្រុងបាវិត ជាក្រុងដែលស្ថិតនៅស្របជាមួយផ្លូវជាតិលេខ១ ហើយជាច្រករបៀងផ្នែកខាងត្បូងអាស៊ាន និងស្ថិតនៅក្នុងប្រព័ន្ធនៃផ្លូវខ្សែក្រវ៉ាត់១ ផ្លូវ១របស់ចិន ដែលនឹងសាងសង់មកដល់នាពេលខាងមុខ។ ក្រុងនេះក៏ ជាទីក្រុងពិសេស១ ដែលរដ្ឋាភិបាលបាននិងកំពុងដាក់ចូលក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥ ២០២៥ និងជាទីក្រុងមួយដែលជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ឧស្សាហកម្ម និងសេដ្ឋកិច្ច ដែលជាចំណុចកណ្តាលតភ្ជាប់រវាងទីក្រុងហូជីមិញ និងទីក្រុងភ្នំពេញនាពេលអនាគតផងដែរ។ បច្ចុប្បន្នមានជនជាតិចិន និងអ្នកវិនិយោគចិនប្រមាណ៥០,០០០នាក់ បាននិងកំពុងធ្វើការ និងវិនិយោគនៅទីក្រុងនេះ ដែលនៅឆ្នាំ២០២៥ខាងមុខ ទីក្រុងបាវិតនឹងមានមនុស្សរស់នៅប្រមាណ២០ម៉ឺននាក់។

[48] ដើមអម្ពិល, "អស្ចារ្យ! ទីក្រុងរណប តម្លៃរាប់រយលានដុល្លារ ចាប់ផ្តើមបើកការដ្ឋាន នៅក្រុងបាវិត នាថ្ងៃនេះហើយ", ចុះផ្សាយថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩

[49] កោះសន្តិភាព, "ក្រុមហ៊ុនអលចនទ្រព្យចិន បោះទុនវិនិយោគលើគម្រោងទីក្រុងរណបនៅក្រុងបាវិត", ចុះផ្សាយថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩

ខេត្តព្រៃវែង[50] គម្រោងទីក្រុងរណបនៅក្រុងប៉ោយប៉ែត និងគម្រោងវិនិយោគនិងអភិវឌ្ឍន៍ទីក្រុងរណបលើផ្ទៃរាប់រយហិកតារនៅស្រុកបទុមសាគរ និងគិរីសាគរជាដើម។

នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ផ្លូវល្បឿនលឿនពីភ្នំពេញទៅខេត្តព្រះសីហនុ ត្រូវបានបើកការដ្ឋានសាងសង់ជាផ្លូវការដោយសម្តេចតេជោ ដែលមានប្រវែង១៩០គីឡូម៉ែត្រ មានទទឹងតួផ្លូវប្រវែង២៤,៥ម៉ែត្រ ដែលចែកចេញជា ៤គន្លង និងគ្រោងចំណាយថវិកាសាងសង់ប្រមាណ២ពាន់លានដុល្លារអាម៉េរិក ដោយប្រើប្រាស់ថវិកាបដិភាគដែលជាហិរញ្ញប្បទានឥតសំណងពិសេសរបស់រដ្ឋាភិបាលចិនប្រមាណ ១៥០លានដុល្លារអាម៉េរិក។ បើតាមប្រសាសន៍សម្តេចតេជោ ការសាងសង់ផ្លូវនេះ រាជរដ្ឋាភិបាលកម្ពុជាមិនបានខ្ចីលុយពីចិនទេ តែជាការវិនិយោគរបស់ក្រុមហ៊ុនចិនសុទ្ធសាធតាមរូបភាពសាងសង់-ធ្វើអាជីវកម្ម-ផ្ទេរ(BOT) ហើយដីដែលសាងសង់ មិនជាដីដែលរដ្ឋាភិបាលកម្ពុជាផ្តល់ក្រុមហ៊ុនធ្វើផ្លូវទេ តែក្រុមហ៊ុនបានផ្តល់ថវិកាឱ្យរដ្ឋាភិបាល ដើម្បីទិញដីសម្រាប់សាងសង់ផ្លូវ។

## ៣. ការគាំទ្រគោលនយោបាយចិនតែមួយ

ក្រៅពីហុងកុងដែលចាកផុតពីអាណានិគមអង់គ្លេសកាលពីឆ្នាំ១៩៩៧ ហើយបានស្ថិតមកនៅក្រោមការគ្រប់គ្រងរបស់ចិនវិញ កោះតៃវ៉ាន់ដែលមានទំហំ ៣៦.១៩៣គីឡូម៉ែត្រក្រឡា មានប្រជាពលរដ្ឋរស់នៅជាង២០លាននាក់នោះ ដាច់ខាតចិនត្រូវចាត់ទុកជាដែនកោះមួយរបស់ខ្លួនក្រោមរូបភាព«នយោបាយចិនតែមួយ»។ ចំណុចមួយសំខាន់ជាងគេក្នុងអត្ថន័យនៃ «នយោបាយចិនតែមួយ» រាល់បណ្តាប្រទេសទាំងឡាយណា ដែលចង់មានទំនាក់ទំនងការទូតផ្លូវការជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិន ត្រូវតែកាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយនឹងសាធារណរដ្ឋចិន (តៃវ៉ាន់)។

បន្ទាប់ពីព្រឹត្តិការណ៍ផ្ទុះអាវុធថ្ងៃទី០៥-០៦ ខែកក្កដា ឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបិទការិយាល័យតំណាងរបស់តៃវ៉ាន់នៅកម្ពុជា (ការិយាល័យសេដ្ឋកិច្ចនិងវប្បធម៌តៃប៉ិ)។ ក្រោយមក ដើម្បីកសាងទំនាក់ទំនងល្អជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិន រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសគាំទ្រ និងប្រកាន់យក «នយោបាយចិនតែមួយ» ក្នុងទំនាក់ទំនងការទូតរបស់កម្ពុជា។

ក្នុងកិច្ចអនុវត្តការប្រកាសរបស់ខ្លួន ដែលគាំទ្រនិងអនុវត្តនូវ «នយោបាយចិនតែមួយ» តាមសំណើរបស់ប្រទេសចិន កាលពីចុងខែធ្នូ ឆ្នាំ២០០៩ កម្ពុជា បានចាប់បញ្ជូនជនជាតិភាគតិចចិន អ៊ុយហ្គ័រ (Uighur) ចំនួន ២០នាក់ទៅកាន់ប្រទេសចិនវិញ នៅខណៈដែលជនជាតិភាគតិចចិនទាំងនោះបានមកស្វែងរកសិទ្ធិជ្រកកោនពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកជនភៀសខ្លួន នៅក្នុងប្រទេសកម្ពុជា (UNHCR) ។

នៅឆ្នាំ២០១៤ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថាអំពីការហាមឃាត់មិនឱ្យក្រុមប្រឹក្សាអភិវឌ្ឍពាណិជ្ជកម្មក្រៅប្រទេសរបស់តៃវ៉ាន់ បើកការិយាល័យរបស់ខ្លួននៅរាជធានីភ្នំពេញ

[50] ក្រុមហ៊ុនចិន Jiangxi Haihui Utility Co.,Ltd គ្រោងនឹង អភិវឌ្ឍតំបន់នៅមុខសាលាខេត្តព្រៃវែង ទំហំ ៣០០ហិកតា ដែលមានតំបន់កម្សាន្ត ខុនដូ តំបន់ពាណិជ្ជកម្ម និងជាតំបន់ឧស្សាហកម្ម

នោះឡើយ ហើយប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏បានហាមមិនឱ្យមានដាក់ទង់ជាតិតៃវ៉ាន់នៅកម្ពុជានោះដែរ បើទោះបីជាស្ថិតនៅក្នុងថ្ងៃបុណ្យជាតិរបស់តៃវ៉ាន់ក៏ដោយក្តី។

កម្ពុជាបានបង្ហាញជំហរកាន់តែច្បាស់បន្ថែមទៀតរបស់ខ្លួនចំពោះ «នយោបាយចិនតែមួយ» ដោយកាលពីឆ្នាំ២០១៦ ដោយរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចមិនបញ្ជូនជនសង្ស័យមួយក្រុមទៅឱ្យតៃវ៉ាន់តាមការស្នើសុំនោះឡើយ ប៉ុន្តែកម្ពុជាបានបញ្ជូនក្រុមសង្ស័យទាំងនោះទៅឱ្យសាធារណរដ្ឋប្រជាមានិតចិនជំនួសវិញ។

នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៧ ក្នុងពិធីពិសាអាហារសាមគ្គីជាមួយសមាគមខ្មែរ-ចិននៅមជ្ឈមណ្ឌលកោះពេជ្រ សម្តេចតេជោបានមានប្រសាសន៍ថា «*នយោបាយចិនតែមួយគឺជានយោបាយដែលយើងត្រូវគោរពចំពោះអធិបតេយ្យភាពរបស់ចិន ការគោរពអធិបតេយ្យភាពរបស់ចិនមានតម្លៃស្មើនឹងការគោរពអធិបតេយ្យភាពរបស់កម្ពុជាផងដែរ*"។ សម្តេចក៏បានបន្តថា "*ការគោរពអធិបតេយ្យចិន គឺជាចំណុចមួយសំខាន់ណាស់សម្រាប់កម្ពុជា និងសម្រាប់តំបន់អាស៊ីផងដែរ ជាពិសេសអាស៊ីអាគ្នេយ៍ ក្នុងឋានៈអាស៊ានជាដៃគូយុទ្ធសាស្ត្ររបស់ចិន*»។[51]

ចុងក្រោយនេះ ការប្រកាសម្តងហើយម្តងទៀតរបស់កម្ពុជាក្នុងជំហគាំទ្រនយោបាយចិនតែមួយ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ ក្នុងសេចក្តីថ្លែងការណ៍រួមគ្នាមួយរវាងកម្ពុជានិងចិន ស្តីពីលទ្ធផលនៃដំណើរទស្សនកិច្ច៤ថ្ងៃរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា នៅក្នុងចំណុចទី១០បានគូសបញ្ជាក់យ៉ាងដូច្នេះថា៖ "*ភាគីកម្ពុជាសូមបញ្ជាក់សារជាថ្មី នូវការប្រកាន់ខ្ជាប់នូវគោលនយោបាយចិនមួយ ព្រមទាំងទទួលស្គាល់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន ជារដ្ឋាភិបាលស្របច្បាប់តែមួយគត់ តំណាងឱ្យប្រទេសចិនទាំងមូល ហើយតៃវ៉ាន់ជាផ្នែកសំខាន់មួយ នៃបូរណភាពដែនដីរបស់ចិន។ ភាគីកម្ពុជាសូមប្រឆាំងចំពោះការប្រកាសឯករាជ្យរបស់តៃវ៉ាន់គ្រប់ទម្រង់ ព្រមទាំងបន្តគាំទ្រការអភិវឌ្ឍន៍ដោយសន្តិភាពនូវទំនាក់ទំនងចិន និងតៃវ៉ាន់ និងបុព្វហេតុក្នុងការបង្រួបបង្រួមចិន*"។

ជាការពិតណាស់ ការប្រកាន់ជំហរគាំទ្រ នយោបាយចិនតែមួយ មិនមែនត្រឹមតែជាឆន្ទៈនិងការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជានោះទេ តែវាក៏ជាការអនុវត្តស្របទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងធម្មនុញ្ញអាស៊ានផងដែរ។ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់ជំពូកទី៤ អំពីរបបនយោបាយ មាត្រា៥៣ វាក្យខណ្ឌទី២ បានចែងថា "*ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និង គោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក*"។

[51] កោះសន្តិភាព, "នយោបាយចិនតែមួយ នាយករដ្ឋមន្ត្រីប្រកាសជាថ្មីហាមលើកទង់ជាតិកោះតៃវ៉ាន់នៅកម្ពុជា", ចុះផ្សាយថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧

ចំណែកនៅក្នុងធម្មនុញ្ញអាស៊ាន នៅត្រង់វាក្យខណ្ឌទី៧ នៃបុព្វកថា នៃធម្មនុញ្ញរបស់អាស៊ាន បានចែងថា *"**ដោយគោរព**ចំពោះសារៈសំខាន់ជាមូលដ្ឋាននៃមិត្តភាព សហប្រតិបត្តិការ និងគោលការណ៍អធិបតេយ្យភាព សមភាព បូរណភាពទឹកដី ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង គោលការណ៍កុងសង់ស៊ីស និងការឯកភាពគ្នាក្នុងពហុភាព"* ។

## ៤. សារៈសំខាន់នៃតួនាទីរបស់កម្ពុជាក្នុងតំបន់និងពិភពលោក

### ក្របខណ្ឌបញ្ហាសមុទ្រចិនខាងត្បូង

នៅឆ្នាំ២០០២ កម្ពុជាក្នុងនាមជាប្រធានប្ដូរវេនរបស់អាស៊ាន និងជាមិត្តរបស់ចិននិងសមាជិកអាស៊ានដែលជាភាគីជម្លោះ បានជំរុញកិច្ចខិតខំប្រឹងប្រែងសម្រេចបានជាឯកច្ឆន្ទរវាងគ្រប់ប្រទេសជាសមាជិកអាស៊ាន ដោយបង្កើតបាននូវសេចក្ដីប្រកាសស្ដីពីការប្រតិបត្តិសម្រាប់ភាគីជម្លោះក្នុងសមុទ្រចិនខាងត្បូង (Declaration of Conduct for parties in South China Sea Issue : DOC) នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០២ នារាជធានីភ្នំពេញ។ កម្ពុជាក៏បាន បន្តជំរុញក្រមប្រតិបត្តិក្នុងបញ្ហាសមុទ្រចិនខាងត្បូង (COC) កំពុងតែបន្តពិភាក្សា និងពង្រឹងបន្ថែមទៀត ក្នុងការដោះស្រាយក្នុងវិវាទអធិបតេយ្យភាពនេះ ក្នុងទិសដៅ រក្សាសន្តិភាព និងស្ថិរភាពក្នុងដែនឈូងសមុទ្រចិនខាងត្បូង។ កម្ពុជាបានជំទាស់នូវការប៉ុនប៉ងដោះស្រាយទាំងឡាយណា ដែលមិនមានការយល់ស្របគ្នាជាឯកច្ឆន្ទ រវាងគ្រប់ភាគីទាំងអស់នៅក្នុងជម្លោះនេះ។ នៅឆ្នាំ២០១២ ក្នុងកិច្ចប្រជុំកំពូលអាស៊ាននៅរាជធានីភ្នំពេញ ក្នុងខណៈដែលកម្ពុជាបានក្លាយជាប្រធានប្ដូរវេនរបស់អាស៊ាន កិច្ចប្រជុំនៅពេលនោះអាស៊ានមិនបានចេញសេចក្ដីថ្លែងការណ៍ណាមួយឡើយ ព្រោះដោយសារគ្រប់ភាគីទាំងអស់មិនមានការឯកភាពគ្នាទៅលើរបៀបវារៈ ឬការសម្រេចណាមួយស្ដីពីសមុទ្រចិនខាងត្បូងឡើយ។ នៅឆ្នាំនោះ កម្ពុជាបានបញ្ចៀសដោយជោគជ័យនូវស្ថានភាពដែលបណ្ដាប្រទេសជាសមាជិកអាស៊ានជាភាគីក្នុងជម្លោះសមុទ្រចិនខាងត្បូង ព្យាយាមទាញសមាជិកដទៃផ្សេងទៀតឱ្យចូលទៅក្នុងការប្រឈមមុខដាក់គ្នារវាងអាស៊ាននិងចិនក្នុងបញ្ហាជម្លោះបូរណភាពដែនដីរបស់ខ្លួន។ នៅថ្ងៃទី១៨និងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ប្រមុខរដ្ឋាភិបាលកម្ពុជា សម្ដេចតេជោ ហ៊ុន សែន បានបញ្ជាក់ជំហរជាថ្មីម្ដងទៀតថា កម្ពុជានឹងមិនចូលរួមចេញសេចក្ដីថ្លែងការណ៍រួមណាមួយ ចំពោះសាលដីកាតុលាការអន្តរជាតិចំពោះការប្ដឹងចោទប្រទេសចិនពីសំណាក់ប្រទេសហ្វីលីពីន នេះទេ។ យ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជាបានអំពាវនាវដល់ប្រទេសហ្វីលីពីន និង ប្រទេសចិន បន្តដោះស្រាយជម្លោះរបស់ខ្លួននៅសមុទ្រចិនខាងត្បូងដោយសន្តិវិធី។ បន្ថែមពីនេះ បន្ទាប់ពីតុលាការអន្តរជាតិមួយនេះបានកំណត់យកថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១៦ ជាថ្ងៃចេញសាលដីកា ពាក់ព័ន្ធនឹងបណ្ដឹងរបស់ហ្វីលីពីនក្នុងជម្លោះជាមួយចិនលើសមុទ្រចិនខាងត្បូង នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៦ ក្រសួងការបរទេសកម្ពុជា បានចេញសេចក្ដីថ្លែងការណ៍សារជាថ្មីទៀតដើម្បីបញ្ជាក់ពីជំហររដ្ឋាភិបាលកម្ពុជាថានឹងមិនគាំទ្រសាលដីការបស់តុលាការក្រុងឡាអេ ចំពោះជម្លោះសមុទ្រចិនខាងត្បូងរវាងប្រទេសចិននិងហ្វីលីពីននោះទេ៖ *"កម្ពុជាយល់ថាបណ្ដឹងរបស់ប្រទេសហ្វីលីពីន គឺដើម្បីសុំឱ្យតុលាការមជ្ឈត្តកម្មអចិន្ត្រៃយ៍ដោះស្រាយជម្លោះរបស់ខ្លួនជាមួយប្រទេសចិន*

*ហើយ ដែលដំណើរការនេះមិនពាក់ព័ន្ធជាមួយរដ្ឋទាំងអស់ជាសមាជិក ASEAN ឡើយ។ ដោយហេតុនេះកម្ពុជានឹងមិនចូលរួមក្នុងការបញ្ចេញជំហររួមណាមួយចំពោះសាលដីកាតុលាការមជ្ឈត្តកម្មអចិន្ត្រៃយ៍ ដែលនឹងធ្វើការសម្រេចលើវិវាទរវាងប្រទេសហ្វីលីពីន និងប្រទេសចិននោះឡើយ។ ទោះយ៉ាងណាក៏ដោយក្នុងនាមជាមិត្តរបស់ភាគីជម្លោះ និងគោលបំណងរក្សាសន្តិភាព សន្តិសុខ ស្ថិរភាពនៅសមុទ្រចិនខាងត្បូងក៏ដូចជាដើម្បីរក្សាប្រយោជន៍ដ៏ធំធេងសម្រាប់តំបន់ទាំងមូល ដែលបានមកពីដៃគូយុទ្ធសាស្ត្រដ៏ល្អប្រសើររវាង ASEAN និងចិននោះ កម្ពុជាសូមអំពាវនាវដល់ប្រទេសហ្វីលីពីន និងចិនបន្តដោះស្រាយជម្លោះរបស់ខ្លួនដោយសន្តិវិធី"*។ [52]

នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៦ បណ្តាប្រទេសជាសមាជិក ASEAN បានបរាជ័យក្នុងការចេញសេចក្តីថ្លែងការណ៍រួមរបស់អាស៊ាន តាមការចង់បានរបស់ហ្វីលីពីននិងវៀតណាម បន្ទាប់ពីកម្ពុជាបដិសេធការលើកឡើងនានាទៅកាន់តុលាការអន្តរជាតិ ដើម្បីប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិត នៅក្នុងសេចក្តីថ្លែងការណ៍របស់ពួកគេ ដែលចង់បានសេចក្តីថ្លែងការណ៍រួមមួយរបស់រដ្ឋមន្ត្រីការបរទេសអាស៊ានដើម្បី ចេញសេចក្តីសម្រេច កំណត់និងតម្រូវឱ្យមានការគោរពច្បាប់អន្តរជាតិ ដែលប្រទេសទាំងពីរទំនងចង់សម្តៅទៅលើសាលដីកា ពាក់ព័ន្ធនឹងបណ្តឹងរបស់ហ្វីលីពីនក្នុងជម្លោះជាមួយចិនលើសមុទ្រចិនខាងត្បូង។[53]

ជាប្រតិកម្មតបរបស់អ្នកការទូត នៃបណ្តាប្រទេសជាសមាជិកអាស៊ានជាភាគីក្នុងជម្លោះសមុទ្រចិនខាងត្បូង ពួកគេបានចោទប្រកាន់កម្ពុជាថា បានធ្វើឱ្យបរាជ័យក្នុងការប្រកាសនូវសេចក្តីថ្លែងការណ៍រួមរបស់អាស៊ានជាលើកដំបូងក្នុងប្រវត្តិសាស្ត្រ។ ប៉ុន្តែតាមការពិត ពួកគេពុំបានឈ្វេងយល់ឡើយថា ការទាញអាស៊ានទាំងមូលឱ្យទៅប្រឈមមុខជាមួយចិន គឺពុំបានជួយអ្វីជាដុំកំភួនឡើយក្នុងការដោះស្រាយជម្លោះសមុទ្រចិនខាងត្បូង ខណៈដែលចិនគឺជាដៃគូពាណិជ្ជកម្មដ៏ធំមួយរបស់អាស៊ាន ហើយសូម្បីតែប្រទេសមួយចំនួនដែលមានជម្លោះជាមួយនឹងចិន ក៏ទទួលបានប្រយោជន៍សេដ្ឋកិច្ចមិនតិចនោះដែរ ពីការវិនិយោគពីសំណាក់សាធារណរដ្ឋប្រជាមានិតចិនទៅក្នុងប្រទេសរបស់ខ្លួន តែពួកគេបែរជាព្យាយាមស្តីបន្ទោស និងទម្លាក់ការទទួលខុសត្រូវអំពីការមិនអាចចេញសេចក្តីថ្លែងការណ៍រួមរបស់អាស៊ាន ទាំងដែលធម្មនុញ្ញរបស់អាស៊ានបានចែងច្បាស់រួចទៅហើយថា រាល់សេចក្តីសម្រេចទាំងឡាយណារបស់អាស៊ាន គឺត្រូវការការសម្រេចជាឯកច្ឆន្ទពីបណ្តាសមាជិកអាស៊ាន។

**-ក្របខណ្ឌអង្គការសហប្រជាជាតិ**

អង្គការសហប្រជាជាតិ ត្រូវបានបង្កើតឡើងតាំងពីថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៤៥ ក្រោយសង្គ្រាមលោកលើកទី២ ត្រូវបានបញ្ចប់។ ប្រទេសកម្ពុជាបានក្លាយជាសមាជិកអង្គការពិភពលោកនេះនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥ ហើយក្នុងនាមជាសមាជិកនៃអង្គការនេះ កម្ពុជាមានសិទ្ធិនិងសម្លេងមួយ

---

[52] ភ្នំពេញប៉ុស្តិ៍, "កម្ពុជាបញ្ជាក់ជំហរជាថ្មីពីជម្លោះសមុទ្រចិនខាងត្បូង" ចុះផ្សាយថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦

[53] Reuters, "ASEAN deadlocked on South China Sea, Cambodia blocks statement" Issued: on July 25, 2016

ស្មើគ្នានឹងសមាជិកដទៃផ្សេងទៀត ក្នុងការបោះឆ្នោតលើសេចក្តីសម្រេចចិត្តណាមួយរបស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ។ នៅក្នុងក្របខណ្ឌនៃអង្គការសហប្រជាជាតិ មានអង្គសំខាន់ៗចំនួន ៦ ដែលរួមមាន៖ មហាសន្និបាត លេខាធិការដ្ឋាន ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម ក្រុមប្រឹក្សាអាណាព្យាបាល តុលាការអន្តរជាតិ និងក្រុមប្រឹក្សាសន្តិសុខ។ ប៉ុន្តែអង្គដែលមានឥទ្ធិពលជាងគេគឺ ក្រុមប្រឹក្សាសន្តិសុខ និងតុលាការអន្តរជាតិ។ ក្រុមប្រឹក្សាសន្តិសុខជាស្ថាប័នជាន់ខ្ពស់បំផុតរបស់អង្គការសហប្រជាជាតិ ហើយរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ គឺមានលក្ខណៈបង្ខិតបង្ខំតាមផ្លូវច្បាប់ ពោលខុសពីសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ។

នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៨ កម្ពុជាត្រូវបានជ្រើសតាំង ឱ្យធ្វើជាអនុប្រធាននៃសម័យប្រជុំលើកទី៧៣ របស់មហាសន្និបាតនៃអង្គការសហប្រជាជាតិសម្រាប់អណត្តិរយៈពេល១ឆ្នាំ រួមជាមួយប្រទេសចំនួន១៥ផ្សេងទៀត និងប្រទេសសមាជិកអចិន្ត្រៃយ៍ទាំង៥ នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។[54]

ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ កម្ពុជាបានក្លាយទៅជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិប្រចាំឆ្នាំ២០១៩ តាមរយៈការបោះឆ្នោតគាំទ្រ ដោយសំឡេងចំនួន១៨៣លើ១៨៨ នៅក្នុងការបោះឆ្នោតក្នុងមហាសន្និបាតនៃអង្គការសហប្រជាជាតិ។

ជាមួយគ្នានេះដែរ បច្ចុប្បន្ននេះកម្ពុជាបានលេចមុខមាត់ថ្មីនៅលើឆាកអន្តរជាតិ តាមរយៈការដើរតួនាទីជាគ្រូបង្គោលក្នុងការដោះមីនឬអាវុធជាតិផ្ទុះទាំងឡាយដែលបានបន្សល់ពីសង្គ្រាម និងបានក្លាយជាប្រទេសបញ្ជូនកងកម្លាំងថែរក្សាសន្តិភាពក្រោមធ្វជ័អង្គការសហប្រជាជាតិ ទៅបំពេញការងារនៅតាមបណ្តាប្រទេសមានជម្លោះមួយចំនួនដូចជា សូដង់ សូដង់ខាងត្បូង ឆាដ អាហ្វ្រិកកណ្តាល លីបង់ ស៊ីរី សាយប្រឹស និងម៉ាលី។ ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១៧ កម្ពុជាបានបញ្ជូនកងទ័ពមួកខៀវចំនួន ៤.៩៨៥នាក់ ទៅបណ្តាប្រទេសទាំងនោះ។ គិតចាប់ពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ន មជ្ឈមណ្ឌលជាតិរក្សាសន្តិភាព បានបញ្ជូនកម្លាំងមួកខៀវកម្ពុជាសរុបចំនួន ៥.៤៨៦នាក់ ក្នុងនោះស្ត្រី ២៥៤នាក់ ទៅចូលរួមបេសកកម្មចំនួន១០ ក្នុងប្រទេសចំនួន៨ [55]។ រយៈពេល១០ឆ្នាំ កម្ពុជាបានបញ្ជូន កងកម្លាំងខៀវ ទៅបំពេញបេសកកម្មក្រោមធ្វជ័អង្គការសហប្រជាជាតិ មានចំនួនជាង៣ពាន់នាក់ នៅប្រទេសចំនួន៨ដើម្បីថែរក្សាសន្តិភាពលើលោកនិងសកម្មភាពមនុស្សធម៌និង ទទួលបានការកោតសរសើរពីអគ្គលេខាធិការអង្គការសហប្រជាជាតិ។

[54] The Cambodia Daily, "កម្ពុជាជាប់ជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហ ប្រជាជាតិប្រចាំឆ្នាំ ២០១៩", ចុះផ្សាយថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨

[55] ខ្លីៗ, "តើកងកម្លាំងមួកខៀវកម្ពុជាប៉ុន្មាននាក់ ពលីជីវិតនៅក្នុងបេសកកម្មរបស់ UN?", ចុះផ្សាយថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០១៨

**-កិច្ចប្រជុំអាស៊ានបូក៣**

កិច្ចប្រជុំលើកដំបូង នៃបណ្ដាមេដឹកនាំអាស៊ាន ចិន ជប៉ុន និងកូរ៉េខាងត្បូង បានប្រព្រឹត្តទៅនៅក្នុងឆ្នាំ ១៩៩៦ និង ១៩៩៧ ដើម្បីដោះស្រាយបញ្ហាទីផ្សារអាស៊ី-អ៊ឺរ៉ុប។ បន្ទាប់ពីកិច្ចប្រជុំនោះ ចិន និង ជប៉ុន មានគំនិតផ្ដួចផ្ដើមចង់ឱ្យមានកិច្ចប្រជុំកំពូលជាទៀងទាត់មួយរវាងបណ្ដាប្រទេសនៅអាស៊ីបូព៌ា (ចិន ជប៉ុន និងកូរ៉េខាងត្បូង) ជាមួយនឹងបណ្ដាមេដឹកនាំប្រទេសអាស៊ាន។ចាប់តាំងពីពេលនោះមក កិច្ចប្រជុំអាស៊ានបូក៣ បានក្លាយជាវេទិកាមួយដែលមាន "តួនាទីជាអ្នកសម្របសម្រួលកិច្ចសហប្រតិបត្តិការ" រវាងបណ្ដាប្រទេស "សមាជិកអាស៊ាន" និង "ប្រទេសអាស៊ីបូព៌ា"ទាំងបី។

សារៈសំខាន់នៃកិច្ចប្រជុំអាស៊ានបូកបី ត្រូវបានពង្រឹងបន្ថែមនៅក្នុងកាលៈទេសៈនៃវិបត្តិហិរញ្ញវត្ថុអាស៊ី។ ឆ្លើយតបចំពោះវិបត្តិនេះ អាស៊ាន បានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយចិន ជប៉ុន និងកូរ៉េខាងត្បូង។ ចាប់តាំងពីការអនុវត្តសេចក្ដីប្រកាសរួម ស្ដីពី សហប្រតិបត្តិការអាស៊ីបូព៌ា ក្នុងកិច្ចប្រជុំកំពូលនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នៅឆ្នាំ១៩៩៩ នោះមក រដ្ឋមន្ត្រីហិរញ្ញវត្ថុ នៃបណ្ដាប្រទេសអាស៊ានបូកបី បានធ្វើការប្រឹក្សាយោបល់គ្នាយ៉ាងទៀតទាត់ ។

**-កិច្ចប្រជុំកំពូលអាស៊ីបូព៌ា**

កិច្ចប្រជុំកំពូលអាស៊ីបូព៌ា ជាវេទិកាថ្នាក់ដឹកនាំកំពូលសម្រាប់ការសន្ទនាលើបញ្ហានយោបាយ និងសេដ្ឋកិច្ចជាយុទ្ធសាស្ត្រដើម្បីបុព្វហេតុផលប្រយោជន៍រួម ក្នុងគោលដៅលើកស្ទួយសន្តិភាព ស្ថិរភាព និងវិបុលភាពសេដ្ឋកិច្ចក្នុងតំបន់អាស៊ីបូព៌ាទាំងមូល។ កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទីមួយ បានប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៥ នាទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។ កម្ពុជា ក្នុងនាមជាសមាជិកអាស៊ានមួយរូបដែរនោះ កម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំកំពូលលើកដំបូងនេះជាមួយនឹងប្រទេសសមាជិកអាស៊ាន៩ទៀត រួមជាមួយនឹង ចិន ឥណ្ឌា ជប៉ុន កូរ៉េខាងត្បូង និងប្រទេសនូវែលសេឡង់។

**- វេទិកាសភាអាស៊ីប៉ាស៊ីហ្វិក**

វេទិកាសភាអាស៊ីប៉ាស៊ីហ្វិក (Asia Pacific Parliamentary Forum) ហៅកាត់ថា APPF ត្រូវបានបង្កើតឡើងនៅទីក្រុងតូក្យូប្រទេសជប៉ុន កាលពីឆ្នាំ ១៩៩៣ ហើយសភានៃព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកពេញសិទ្ធិកាលពីឆ្នាំ ១៩៩៥ ខណៈដែលបច្ចុប្បន្ននេះ APPF មានសមាជិកពេញសិទ្ធិចំនួន២៧ប្រទេស។ ហើយថ្មីៗនេះ កម្ពុជាក៏បានទទួលធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំលើកទី២៧ នៃវេទិកាសភាតំបន់អាស៊ី ប៉ាស៊ីហ្វិក នៅខេត្តសៀមរាប ចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៧ មករា ឆ្នាំ២០១៩ ផងដែរ ដែលនេះគឺជាជោគជ័យក្នុងវិស័យការទូតរបស់រដ្ឋសភាជាតិកម្ពុជា។ កិច្ចប្រជុំដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៅឆ្នាំ២០១៩នេះ បានប្រព្រឹត្តទៅក្រោមប្រធានបទ "*ការពង្រឹងភាពជាដៃគូ ដើម្បីសន្តិភាព សន្តិសុខ និងការអភិវឌ្ឍប្រកបដោយចីរភាព* " តួយ៉ាងគឺផ្ដោតអំពីបញ្ហាឧបទ្វីបកូរ៉េ និងបញ្ហាជម្លោះសមុទ្រចិនខាងត្បូងដែលមានបណ្ដាប្រទេសជាសមាជិក អាស៊ាន មួយចំនួនពាក់ព័ន្ធក្នុងជម្លោះនោះ និងបញ្ហាសិទ្ធិមនុស្សនៅប្រទេសមីយ៉ាន់ម៉ាផងដែរ។

គួរបញ្ជាក់ផងដែរថា ក្រៅពីជាសមាជិកវេទិកាសភាតំបន់អាស៊ីប៉ាស៊ីហ្វិក APPF, សភាកម្ពុជាក៏ជាសមាជិកនៃវេទិកាអន្តរសភាដទៃទៀតផងដែរ មានជាអាទិ៍៖ សហភាពអន្តរសភា IPU, អន្តរសភាអាស៊ាន AIPA, សភាតំបន់អាស៊ី APA, កិច្ចប្រជុំភាពជាដៃគូសភាអាស៊ីអឺរ៉ុប ASEP, និងវេទិកាសភានិយាយភាសាបារាំង APF ជាដើម។

**- កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង**

កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១៥ ដោយមានសមាជិកសរុប ៦ រួមមាន កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម និងផ្តោតសំខាន់លើសសរស្តម្ភ ៣ និងមានវិស័យអាទិភាពចំនួន ៥ និងត្រូវបានរៀបចំឡើងជារៀងរាល់២ឆ្នាំម្តង តាមបែបប្តូរវេនរវាងក្រុមប្រទេសសមាជិក។[56] ក្នុងកិច្ចប្រជុំកំពូលលើកទី១របស់ខ្លួន នៅខែមីនាឆ្នាំ ២០១៦ ក្រុមប្រទេសសមាជិកទាំង៦បានឯកភាពលើទិសដៅធំៗសំរាប់ យន្តការសហប្រតិបត្តិការ ដោយបានបង្កើតឡើងយន្តការសន្ទនាជាច្រើនដូចជា កិច្ចប្រជុំកំពូល កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ (SOM)។ លើសពីនេះផងដែរ មជ្ឈមណ្ឌលសហប្រតិបត្តិការអំពីធនធានទឹក កិច្ចសហប្រតិបត្តិការអំពីបរិស្ថានទន្លេមេគង្គ-ឡានឆាង មជ្ឈមណ្ឌលស្រាវជ្រាវទន្លេមេគង្គសាកល ក៏ត្រូវបានបង្កើតឡើងផងដែរ ខណៈដែលគម្រោងការណ៍មួយចំនួនត្រូវបានដាក់ឱ្យដំណើរការរួចស្រេចដូចជា វេទិកាសហប្រតិបត្តិការនារី និងវេទិកាសហប្រតិបត្តិការបណ្តាទីក្រុងទេសចរណ៍មេគង្គ-ឡានឆាងជាដើម។

កិច្ចប្រជុំកំពូលសហប្រតិបត្តិការមេគង្គ-ឡានឆាង (MLC) លើកទី២ បាន ប្រារព្ធនាថ្ងៃទី១០ មករា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជាដោយត្រូវបានរៀបចំឡើងក្រោមសហប្រធានរបស់កម្ពុជានិងចិន និងមានការចូលរួមរបស់ប្រមុខរដ្ឋនិងប្រមុខរដ្ឋាភិបាលនៃប្រទេសចំនួន៦ រួមមាន កម្ពុជា ចិន មីយ៉ាន់ម៉ា ថៃ ឡាវ និងវៀតណាម ដែលធ្វើឡើងក្រោមប្រធានបទ "ទន្លេរបស់យើង ដើម្បីសន្តិភាពនិងការអភិវឌ្ឍន៍ប្រកបដោយចីរភាព" នោះ កិច្ចប្រជុំគឺសំដៅជំរុញកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដើម្បីកសាងសហគមន៍មានការទទួលខុសត្រូវ និងផលប្រយោជន៍រួមក្នុងអនុតំបន់។

គួរបញ្ជាក់ផងដែរថា នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ ប្រទេសចិនបានផ្តល់ជំនួយឥតសំណងចំនួន ៧,៣ លានដុល្លារពីមូលនិធិពិសេស LMC ដល់ប្រទេសកម្ពុជាដើម្បីអនុវត្តគម្រោងចំនួន ១៦ នៅកម្ពុជា ដោយគ្របដណ្តប់លើវិស័យជាច្រើនដូចជា កសិកម្ម ទេសចរណ៍ បច្ចេកវិទ្យា សុខភាពសាធារណៈ ការអប់រំ និងស្រាវជ្រាវ ធនធានទឹក និងអភិវឌ្ឍន៍ជនបទ ក្នុងចំណោមវិស័យដទៃទៀត។[57]

នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ ភាគីទាំងពីរកម្ពុជា-ចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការលើគម្រោងនៃមូលនិធិពិសេស មេគង្គ-ឡានឆាង ដែលកម្ពុជាទទួលបានថវិកា

[56] ភ្នំពេញប៉ុស្តិ៍, "កម្ពុជាបានថវិកា ៧,៦៦ លានដុល្លារពីមូលនិធិមេគង្គ-ឡានឆាង", ចុះផ្សាយថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩
[57] Xinhuanet, "Feature: Lancang-Mekong Cooperation puts people first, brings benefits to locals", release on January 09, 2018

ចំនួន ៧,៦៦ លានដុល្លារពីកិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការលើគម្រោងមូលនិធិពិសេស មេគង្គ-ឡានឆាង ដើម្បីគាំទ្រដល់ការអនុវត្តលើផែនការចំនួន ១៩ គម្រោង។[58]

គិតមកដល់បច្ចុប្បន្ននេះ កម្ពុជាបានទទួលគម្រោងសរុបចំនួន ៣៥ ដែលមានវិសាលភាពគ្របដណ្តប់លើសកម្មភាពកិច្ចសហប្រតិបត្តិការក្នុងវិស័យកសិកម្ម ទេសចរណ៍ បច្ចេកទេសព័ត៌មានវិទ្យា អប់រំ និងស្រាវជ្រាវធនធានទឹក អភិវឌ្ឍន៍ជនបទ និងការផ្លាស់ប្តូរផ្នែកវប្បធម៌ និងសាសនា។ គម្រោងមួយចំនួនត្រូវបានបញ្ចប់ជាស្ថាពរ និងគម្រោងដែលនៅសល់ផ្សេងទៀតជិតត្រូវបានបញ្ចប់ ឬមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។[59]

## III. កម្ពុជា-ចិន៖ ពីទំនាក់ទំនងជាយុទ្ធសាស្ត្រទៅជាដៃគូចាក់ទឹកមិនលិច

### ១. កម្ពុជានៅក្នុងយុទ្ធសាស្ត្រផ្លូវមួយខ្សែក្រវាត់មួយ

ក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ដើម្បីចូលរួមវេទិកាខ្សែក្រវាត់ និងផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ពីថ្ងៃទី១៣ ដល់ ១៧ ខែឧសភា ឆ្នាំ២០១៧ ភាគីទាំងពីរបានចុះហត្ថលេខាលើឯកសារកិច្ចសហប្រតិបត្តិការចំនួន ១៣ ក្នុងនោះរួមមាន៖ «ចំណុចគោលនៃផែនការកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីរួមគ្នាបង្កើតកិច្ចសហប្រតិបត្តិការខ្សែក្រវាត់សេដ្ឋកិច្ចផ្លូវសូត្រ និងកិច្ចសហប្រតិបត្តិការផ្លូវសូត្រសមុទ្រសតវត្សទី២១» «អនុស្សរណៈយោគយល់គ្នាស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យហេដ្ឋារចនាសម្ព័ន្ធ» «អនុស្សារ-ណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើការកសាងសមត្ថភាពពាក់ព័ន្ធវិស័យដឹកជញ្ជូន» «ការអនុវត្តផែនការសម្រាប់អនុស្សរណៈយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ (២០១៧-២០២០)» និង «ពិធីសារស្តីពីការបង្កើតស្ថានីយ៍សង្កេតកិច្ចការបរិស្ថានសមុទ្ររួម» ជាដើម[60] ជាមួយនឹងការផ្តល់ជំនួយឥតសំណង ១,២០០លានយន់ ឬស្មើនឹង ១៧៤លានដុល្លារ និងកម្ចីសម្រាប់គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់។

នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧ សាធារណរដ្ឋប្រជាមានិតចិនបានផ្តល់នូវរថយន្តក្រុង១០០ គ្រឿង ជាជំនួយឥតសំណងរបស់រដ្ឋាភិបាលចិនជូនដល់រដ្ឋបាលរាជធានីភ្នំពេញ។ [61]

---

[58] ភ្នំពេញប៉ុស្តិ៍, "កម្ពុជាបានថវិកា ៧,៦៦ លានដុល្លារពីមូលនិធិមេគង្គ-ឡានឆាង", ចុះផ្សាយថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩

[59] ដដែល

[60] "សេចក្តីប្រកាសព័ត៌មានរួមរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន" ចេញផ្សាយដោយអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស នៃទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧

[61] កម្ពុជាថ្មី, "រថយន្តក្រុង១០០គ្រឿង ជាជំនួយឥតសំណងរបស់រដ្ឋាភិបាលចិន នឹងផ្តល់ជូនរដ្ឋបាលរាជធានីនៅរសៀលថ្ងៃទី ១៣ ខែកក្កដានេះ" ចុះផ្សាយថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧

## ២. ការគាំទ្ររបស់ចិនដល់កម្ពុជាក្នុងនីតិកាលទី៥ និងនីតិកាលទី៦នៃរដ្ឋសភា

ការជាប់គាំងនយោបាយនៅកម្ពុជាក្នុងនីតិកាលទី៥នៃរដ្ឋសភា បានក្លាយទៅជាការព្រួយបារម្ភរបស់សាធារណៈមតិ ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រទេសជប៉ុន អាល្លឺម៉ង់ សហភាពអឺរ៉ុប និងជាពិសេសសាធារណរដ្ឋប្រជាមានិតចិន នៅតែបន្តផ្តល់ជំនួយជាបន្តបន្ទាប់ដល់ប្រទេសកម្ពុជា។

នៅឆ្នាំ២០១៤ ខណៈដែលប្រទេសកម្ពុជាកម្ពុជាកំពុងជួបប្រទះនឹងវិបត្តិនយោបាយដែលបង្កឡើងដោយគណបក្សប្រឆាំង នៅក្នុងបទសម្ភាសន៍ជាមួយនឹងទីភ្នាក់ងារព័ត៌មានស៊ីនហួរ ឯកឧត្តមប្រធានាធិបតីចិន ស៊ី ជិនពីង បានគូសបញ្ជាក់ថា «ប្រទេសចិនជ្រោមជ្រែងប្រជាជនកម្ពុជាឱ្យបន្តដើរតាមវិថីនៃការអភិវឌ្ឍដែលសមស្របទៅនឹងលក្ខខណ្ឌនៃប្រទេសរបស់ខ្លួន»។ ជាមួយគ្នានេះដែរ ឯកឧត្តមបានអំពាវនាវឱ្យបង្កើនការវិនិយោគក្នុងវិស័យកសិកម្ម ទេសចរណ៍ និងការអនុវត្តគម្រោងទាំងឡាយ ទាក់ទងនឹងថាមពលទឹក ធ្យូងថ្ម និងតំបន់សេដ្ឋកិច្ចពិសេសក្នុងប្រទេសកម្ពុជា ព្រមទាំងពង្រីកសហប្រតិបត្តិការផ្នែកវប្បធម៌ និងការផ្លាស់ប្តូរទេសចរណ៍ទៅវិញទៅមកផងដែរ។ ជាការឆ្លើយតប សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងថា «រដ្ឋាភិបាលនិងប្រជាជនកម្ពុជា វាយតម្លៃខ្ពស់ចំពោះជំនួយរយៈពេលវែងរបស់ចិន ព្រមទាំងពេញចិត្តនឹងចំណងមិត្តភាពរវាងចិននិងកម្ពុជាយ៉ាងខ្លាំង»។ ហើយសម្តេចក៏បានគូសបញ្ជាក់សារជាថ្មីថា «កម្ពុជានឹងបន្តដើរតួក្នុងន័យស្ថាបនា ដើម្បីបង្កើនចំណងមេត្រីភាពរវាងប្រទេសចិន និងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍»។[62]

បន្ទាប់ពីការបោះឆ្នោតថ្នាក់ជាតិនៅកម្ពុជាបានបញ្ចប់រួច នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣ ក្នុងជំនួបរវាង អគ្គស្នងការនគរបាលជាតិ នាយឧត្តមសេនីយ៍ នេត សាវឿន និងមន្ត្រីសមត្ថកិច្ចជាន់ខ្ពស់នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រទេសចិន លោក លី ជូឈុន (Li Zhuqun) ភាគីចិនបានប្រគល់ឱ្យភាគីកម្ពុជា នូវសម្ភារៈជាច្រើន ដើម្បីបង្កើនការពង្រឹងសន្តិសុខ ក្នុងនោះមានអាវុធខ្លី ១ពាន់ដើម គ្រាប់ចំនួន ៥ម៉ឺនគ្រាប់ និងសម្ភារៈសម្រាប់រក្សាសន្តិសុខមួយចំនួនទៀត។[63]

នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣ យោធាចារ្យជំនាញ ចំនួន១២នាក់ក្នុងកងឯកភាពបោសសម្អាតមីន នៃកងទ័ពរំដោះប្រជាជនចិន បាននាំយកមកនូវជំនាញបច្ចេកទេសនិងបទពិសោធថ្មីៗ លើការងារការហ្វឹកហ្វឺនជំនាញបច្ចេកទេសបោសសម្អាតមីន ទាំងការរុករក ក៏ដូចជាការកម្ទេចមីន និងគ្រឿងឧបករណ៍កាកសំណល់សង្គ្រាមមិនទាន់ផ្ទុះ ជូនដល់កងទ័ពកម្ពុជា ដោយបានប្រព្រឹត្តទៅនៅវិទ្យាស្ថានហ្វឹកហ្វឺនបណ្តុះបណ្តាលកងកម្លាំងរក្សាសន្តិភាព(ឧដុង្គ)។[64]

[62] បណ្ឌិតសភាចារ្យ សុខ ទូច, «នយោបាយការបរទេស ម្សិលមិញ ថ្ងៃនេះ ថ្ងៃស្អែក», ទំព័រទី៤៤, បោះពុម្ពឆ្នាំ២០១៥

[63] សារព័ត៌មានខ្មែរអង្គរ, "ចិន ប្រគល់អាវុធខ្លី ១ពាន់ដើម គ្រាប់ចំនួន ៥ម៉ឺនគ្រាប់ និងសម្ភារៈសម្រាប់រក្សាសន្តិសុខមួយចំនួន" ចុះផ្សាយថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៣

[64] Everyday, "ចិនបង្រៀនជំនាញបច្ចេកទេសបោសសម្អាតមីនដល់កងយោធាកម្ពុជា" ចុះផ្សាយថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៣

នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកអគ្គរដ្ឋទូតចិន តំណាងសាធារណរដ្ឋប្រជាមានិតចិន បានប្រគល់ជំនួយជាសម្ភារៈយោធាដល់កងយោធពលខេមរភូមិន្ទកម្ពុជា ដែលរួមមានរថយន្តទាហាន២៦ គ្រឿង និងឯកសណ្ឋានយោធាចំនួន៣ម៉ឺនឈុត។ [65]

លើសពីនេះទៅទៀត នៅថ្ងៃទី០៥ កញ្ញា ឆ្នាំ២០១៧ ក្រសួងការបរទេសចិនបានចេញសេចក្តីថ្លែងការណ៍គាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចាប់ខ្លួនមេដឹកនាំបក្សប្រឆាំង លោក កឹម សុខា ដោយអ្នកនាំពាក្យក្រសួងការបរទេសចិន លោក Geng Shuang បានថ្លែងច្បាស់ៗថា វាជាកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការការពារសន្តិសុខ និងស្ថិរភាពជាតិ។ ក្រសួងការបរទេសចិន បានគាំទ្រចំពោះកិច្ចការនេះ និងសូមជានាដល់កម្ពុជាក្នុងការថែរក្សាសន្តិសុខផ្ទៃក្នុង ហើយប្រទេសចិននឹងជួយសហការជាមួយប្រទេសកម្ពុជានៅគ្រប់កាលៈទេសៈ។ បើកម្ពុជាមានឧបសគ្គណាមួយ ប្រទេសចិននៅពីក្រោយចាំជួយគាំទ្រដំណើរការនេះ ជោគជ័យរបស់កម្ពុជា ក៏ដូចជាជោគជ័យរបស់ប្រទេសចិន ឧបសគ្គកើតឡើងចំពោះប្រទេសកម្ពុជា ក៏ដូចជាឧបសគ្គរបស់ប្រទេសចិនដែរ។ សង្ឃឹមថា ប្រទេសកម្ពុជាមានស្ថិរភាពនយោបាយ សេដ្ឋកិច្ចល្អប្រសើរយ៉ាងខ្លាំង នាពេលអនាគត។[66]

ក្នុងដំណើរទស្សនកិច្ចនៅកម្ពុជា នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៧ ឯកឧត្តម Wang Jiarui អនុប្រធានសភាចិន បានជួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយសម្តេចអគ្គមហាពញាចក្រី ហេង សំរិន។ លោក វ៉ាង ចៀរ៉ួយ (Wang Jiarui) បានលើកឡើងថា «*កម្ពុជាមានឧបសគ្គ ចិននៅពីក្រោយចាំជួយគាំទ្រកម្ពុជា ហើយជោគជ័យរបស់កម្ពុជា ក៏ដូចជាជោគជ័យរបស់ចិន ឧបសគ្គរបស់កម្ពុជា ក៏ដូចជាឧបសគ្គរបស់ចិនដែរ*»។

ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ២០១៧ ក្នុងជំនួបជាមួយសម្តេចតេជោ ហ៊ុន សែន នៅវិមានសន្តិភាព ឯកឧត្តមអនុប្រធានសភានៃសាធារណរដ្ឋប្រជាមានិតចិន បានបញ្ជាក់អំពីគោលជំហររបស់រដ្ឋាភិបាល ជូនសម្តេចតេជោនាយករដ្ឋមន្ត្រី។ លោក Wang Jiarui បានប្រសាសន៍ថា «*បច្ចុប្បន្ន ទំនាក់ទំនងនៃប្រទេសទាំងពីរបានឈានដល់ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ បានធ្វើឱ្យមានការរីកចម្រើនយ៉ាងខ្លាំងសម្រាប់ទំនាក់ទំនងយើងទាំងពីរ។* »

នៅថ្ងៃទី១១ខែកញ្ញាឆ្នាំ២០១៧ ឯកឧត្តម ចាង ការលី ឧបនាយករដ្ឋមន្ត្រីចិន និងឯកឧត្តម សុង ថាវ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិមជ្ឈិមបក្សកុម្មុយនីស្ត ក្នុងជំនួបជាមួយសម្តេចតេជោ ហ៊ុន សែន នៅសាធារណរដ្ឋចិន បានថ្លែងអះអាងថា ចិននឹងបន្តជួយរាល់ទុក្ខលំបាករបស់កម្ពុជាគ្រប់កាលៈទេសៈទាំងអស់ ហើយបន្តរក្សាទំនាក់ទំនង ដោយមិនមានបរទេសណាមកបំបែកបំបាក់ទំនាក់

---

[65] Radio Australia, "ចិនបន្តផ្តល់សម្ភារៈយោធាដល់កម្ពុជា" ចុះផ្សាយថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៤

[66] កម្ពុជាថ្មី, "ចិនថា៖ "ជោគជ័យរបស់កម្ពុជា ក៏ដូចជាជោគជ័យរបស់ចិន ហើយឧបសគ្គរបស់កម្ពុជា ក៏ដូចជាឧបសគ្គរបស់ចិនដែរ" ចុះផ្សាយថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៧

ទំនងកម្ពុជា-ចិន បានឡើយ។ មន្ត្រីជាន់ខ្ពស់ចិនទាំងនេះ ថែមទាំងសន្យាជួបទប់ស្កាត់ និងការពារមិនឱ្យមាន *បដិវត្តន៍ពណ៌* នៅក្នុងប្រទេសកម្ពុជានោះឡើយ។

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៧ សម្តេចតេជោនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់នៅលើទំព័រ Facebook របស់សម្តេចថា "*មិត្តចិន គឺជាខ្នងបង្អែកដ៏រឹងមាំរបស់កម្ពុជា ហើយបន្តជួយកម្ពុជាគ្រប់កាលៈទេសៈ* "។ សម្តេចតេជោ ថែមទាំងបញ្ជាក់ថា "*ទំនាក់ទំនងរវាងកម្ពុជានិងចិន ដែលមានរយៈពេលប្រមាណជា ៦០ឆ្នាំហើយនោះ នឹងគ្មានបរទេសណាមកបំបែកបាននោះឡើយ។* "

នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៧ ក្នុងឱកាសចូលជួបសម្តែងការគួរសម និងពិភាក្សា ការងារជាមួយសម្តេចតេជោ នៅវិមានសន្តិភាព ឯកឧត្តម លីវ យុនសាន សមាជិកគណៈអចិន្ត្រៃយ៍ការិយាល័យនយោបាយនៃគណកម្មាធិការ មជ្ឈិមបក្សកុម្មុយនីស្តចិន បានថ្លែងអះអាងជាថ្មី បញ្ជាក់ប្រាប់សម្តេចតេជោ ហ៊ុន សែន ថា៖ "*ប្រទេសចិន គឺស្ថិតជាខ្នងបង្អែក ដ៏រឹងមាំសម្រាប់ជួយកម្ពុជា គ្រប់កាលៈទេសៈទាំងអស់។ រដ្ឋាភិបាលចិនគាំទ្រការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន ពេញទំហឹងតែម្តង ហើយនេះក៏ជាសញ្ញាទៅកាន់ពិភពលោកថា កម្ពុជា-ចិន គឺគ្មានបរទេសណាមក បំបែកបំបាក់បានឡើយ។* "

នៅក្នុងដំណើរទស្សនកិច្ចការងាររបស់សម្តេចតេជោប្រមុខរាជរដ្ឋាភិបាល ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ ២០២០ ភាគីកម្ពុជា-ចិនបានឯកភាពជំរុញល្បឿននៃការចរចា និងឈានទៅចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន ឱ្យបានក្នុងពេលឆាប់ៗខាងមុខ ដើម្បីផ្តល់លទ្ធភាពឱ្យកម្ពុជាមានទីផ្សារកាន់តែធំសម្រាប់ផលិតផលរបស់ខ្លួន។ ថ្នាក់ដឹកនាំចិន បានសន្យាជំរុញឱ្យក្រុមហ៊ុនចិនបង្កើនការវិនិយោគនៅកម្ពុជា និងបន្តផ្តល់ជំនួយដល់ការអភិវឌ្ឍន៍កម្ពុជាឱ្យអស់ពីលទ្ធភាព រួមទាំងការអភិវឌ្ឍនៅក្រុងព្រះសីហនុ។[67] ជាមួយគ្នានេះ ប្រធានាធិបតីចិនបានប្រកាសស្វាគមន៍ដំណើរទស្សនកិច្ចរបស់សម្តេចតេជោប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដោយថាសម្តេចអាចអញ្ជើញទៅបំពេញទស្សនកិច្ចនៅប្រទេសចិនពេលណាក៏បាន ហើយលោកប្រធានាធិបតីអាចជួបសម្តេចតេជោច្រើនដង និងញឹកញាប់ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។[68] លើសពីនេះទៅទៀត ប្រមុខរដ្ឋចិន បានប្រកាសដោយឥតអល់អែកថានឹងជួយដល់កម្ពុជាគ្រប់កាលៈទេសៈ ដើម្បីជំរុញការអភិវឌ្ឍប្រទេសកម្ពុជាឱ្យកាន់តែរីកចម្រើនទៅមុខបន្ថែមទៀត ហើយលោកក៏បានប្រកាសផ្តល់ជំនួយតាមតម្រូវការសម្រាប់កម្ពុជា ដែលជាមិត្តដ៏ស្មោះស្ម័គ្រនេះផងដែរ។[69] ដំណើរទស្សនកិច្ចរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជានាពេលនេះ គឺជាសញ្ញាណដ៏ល្អមួយ ដែលវាជាការចាប់ផ្តើមនូវសករាជថ្មីមួយទៀត នៃទំនាក់ទំនងរវាងកម្ពុជា-

[67] សេចក្តីប្រកាសព័ត៌មានក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០

[68] Pressocm.gov.kh, "សម្តេចតេជោ ហ៊ុន សែន ជួបពិភាក្សាការងារជាមួយ ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន", ចុះផ្សាយថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០

[69] Fresh News, "ប្រធានាធិបតីចិន៖ សម្តេចតេជោ និងពលរដ្ឋកម្ពុជា ជាមិត្តដ៏ស្មោះត្រង់របស់ចិន", ចុះផ្សាយថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០

ចិន កម្រិតខ្ពស់បំផុតក្នុងប្រវត្តិសាស្ត្រ ព្រោះវាជាដំណើរទេសស្សនកិច្ចលើកទីមួយ នៃមេដឹកនាំបរទេសទៅកាន់សាធារណរដ្ឋប្រជាមានិតចិន ក្នុងខណៈដែលប្រទេសចិនកំពុងប្រឈមមុខនឹងករណីផ្ទុះជំងឺផ្លូវដង្ហើមបង្កដោយវីរុសកូរ៉ូណា។

## ៣. ចិនត្រូវចាប់កម្ពុជាជាគម្រូនៃទំនាក់ទំនងជាសម្ព័ន្ធមិត្តរបស់ចិន

ជាការពិតណាស់ ទំនាក់ទំនងកម្ពុជា-ចិន ក្នុងសតវត្សរ៍ទី២១ គឺជាទំនាក់ទំនងដែលខុសស្រឡះទាំងស្រុងពីទំនាក់ទំនងរវាងសាធារណរដ្ឋប្រជាមានិតចិន និងរដ្ឋាភិបាលកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលកាលណោះ កម្ពុជាប្រជាធិបតេយ្យឬរបបប៉ុលពត ដែលជាកូនជឹងរបស់ចិន បានដើរតាម និងគោរពយ៉ាងឆ្អិនឆ្អៅនូវជំហរនិងមនោគមវិជ្ជាម៉ៅនិយមរបស់សាធារណរដ្ឋប្រជាមានិតចិន ហើយចិនតាមរយៈកម្ពុជាបានជ្រៀតចូល និងបង្ហាញឱ្យប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍មើលឃើញយ៉ាងច្បាស់នូវឥទ្ធិពលមនោគមវិជ្ជាកុម្មុយនីស្តតាមបែបចិននិយម និងដែលក៏ជាប៉ូលនយោបាយនៃមហាអំណាចថ្មីមួយនៅអាស៊ី ដែលពុំស្ថិតនៅក្រោមឥទ្ធិពលរបស់សហភាពសូវៀតទៀតនោះឡើយ។ ជាការពិតណាស់ ក្រុមឧទ្ទាមក្រហមដែលមាននិន្នាការនិយមកុម្មុយនីស្ត និងដែលត្រូវបានគេមើលឃើញថាមានទំនោរទៅកាន់សាធារណរដ្ឋប្រជាមានិតចិន បានបង្កជាការព្រួយបារម្ភដល់រដ្ឋាភិបាលនៃបណ្តាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល និងបានចាត់ទុកចិនគឺជាការគម្រាមកំហែងធំមួយសម្រាប់ប្រទេសតំបន់នាពេលនោះ។

ទោះបីជាយ៉ាងដូច្នេះក៏ដោយក្តី ក្រៅតែពីការអនុវត្តនិងដើរតាមមនោគមវិជ្ជាម៉ៅនិយម ប្រទេសកម្ពុជាដែលស្ថិតនៅក្រោមការគ្រប់គ្រងនៃរបបកម្ពុជាប្រជាធិបតេយ្យ ពុំបានកសាងនូវសមិទ្ធផលជាប្រយោជន៍អ្វីបន្សល់ទុកដល់អ្នកជំនាន់ក្រោយឡើយ ព្រោះចិននៅពេលនោះក៏ពុំទាន់មានលទ្ធភាពសេដ្ឋកិច្ចគ្រប់គ្រាន់ ដែលអាចជួយដល់របបកម្ពុជាប្រជាធិបតេយ្យដើម្បីអភិវឌ្ឍប្រទេសជាតិបាននោះឡើយ ក្រៅតែពីការផ្តល់ជំនួយមួយផ្នែកនិងអ្នកបច្ចេកទេសចិន និងការដោះដូរទំនិញពីកម្ពុជាជាមួយនឹងសព្វាវុធដែលបញ្ជូនពីសាធារណរដ្ឋប្រជាមានិតចិន ហើយមិនត្រឹមតែប៉ុណ្ណោះ របបកម្ពុជាប្រជាធិបតេយ្យ ដែលមានមានចិនជាបង្អែកថែមទាំងបានបន្សល់ទុកនូវសោនាដកម្មដ៏ជូរចត់បំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជា ដោយសារតែការដើរតាមមនោគមវិជ្ជាម៉ៅនិយមជ្រុល និងថែមទាំងអនុវត្តខុសហួសពីអ្វីមាននៅលទ្ធិម៉ៅនិយមថែមទៀតផង ហើយជាលទ្ធផលប្រជាជនកម្ពុជាយ៉ាងហោចណាស់ ១លាន ៧សែននាក់ត្រូវបានសម្លាប់ក្នុងរបបប្រល័យមនុស្សជាតិមួយនេះ។[70]

ដោយឡែក នៅក្នុងទំនាក់ទំនងទ្វេភាគី កម្ពុជា-ចិន ក្នុងសតវត្សរ៍ទី២១ នេះ សាធារណរដ្ឋប្រជាមានិតចិន មិនអាចចាប់កម្ពុជាដោយប្រើប្រាស់យុទ្ធសាស្ត្រវិនិយោគតែមនោគមវិជ្ជា ដូចក្នុង

[70] ការហៅរបបកម្ពុជាប្រជាធិបតេយ្យ ឬរបប ប៉ុល ពត ថាជារបបប្រល័យជាតិសាសន៍ ហាក់ដូចជាពុំត្រឹមត្រូវនោះឡើយ ព្រោះរបបនេះមិនមែនសម្លាប់តែជាតិសាសន៍ដទៃណាក្រៅតែពីជាតិសាសន៍ខ្លួននោះទេ តែរបបនេះបានប្រល័យជីវិតមនុស្សគ្រប់ជាតិសាសន៍ដោយរាប់ទាំងជនជាតិខ្មែរខ្លួនឯងផងដែរ ឱ្យតែអ្នកទាំងនោះត្រូវបានសង្ស័យថាជាខ្មាំងប្រឆាំងបដិវត្តន៍ ឬអនុវត្តមិនបាននូវច្បាប់និងគោលការណ៍ដែលរបបនេះ ឬកម្មាភិបាលតាមតំបន់នីមួយៗកំណត់។

សម័យសង្គ្រាមត្រជាក់ទៀតនោះទេ។ កម្ពុជាក្នុងសតវត្សរ៍ទី២១ គឺជាសម្ព័ន្ធមិត្តមួយរបស់ចិនដែលមិនអាចខ្វះបានក្នុងការសម្រេចចិត្ត សម្រាប់ការតភ្ជាប់ទំនាក់ទំនងជាមួយអាស៊ាន និងក៏ជាប្រទេសជាដៃគូដ៏ជិតស្និទ្ធដែលចិនចាំបាច់ត្រូវតែផ្តល់ការជ្រោមជ្រែងពេញទំហឹង និងផ្តល់អត្ថប្រយោជន៍ជាយុទ្ធសាស្ត្រដល់កម្ពុជាក្នុងការអភិវឌ្ឍប្រទេស ដើម្បីលើកយកករណីកម្ពុជាធ្វើជាគម្រូម៉ូដែលសម្រាប់បង្ហាញដល់ប្រទេសដទៃផ្សេងទៀត ដែលមានបំណង ឬកំពុងពិចារណាចាប់ចិន និងសម្រាប់ការបង្ហាញឥទ្ធិពលជាវិជ្ជមានក្នុងទំនាក់ទំនងជាមួយប្រទេសដៃគូរបស់ចិនក្នុងនាមខ្លួនជាមហាអំណាច ដែលកំពុងរៀបចំខ្លួននឹងលេចត្រដែតឡើងជាមហាអំណាចទីមួយពិភពលោក។

## ៤. ទំនាក់ទំនងភាពជាដៃគូចាក់ទឹកមិនលិច

ចាប់តាំងពីឆ្នាំ២០១០មក ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-ចិន ត្រូវបានលើកកម្ពស់មួយកម្រិតទៅជាទំនាក់ទំនង «ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ» ដោយកម្ពុជាតែងតែគាំទ្រនយោបាយការបរទេសចិន ជាពិសេសគោលនយោបាយចិនតែមួយ និងគំនិតផ្តួចផ្តើមស្តីពី «ការផ្តួចផ្តើមគំនិងខ្សែក្រវាត់ និងផ្លូវ»។

កិច្ចសហប្រតិបត្តិការភាពដៃគូយុទ្ធសាស្ត្រ គ្រប់ជ្រុងជ្រោយកម្ពុជា-ចិន ត្រូវបានបន្តពង្រឹង តាមរយៈយន្តការគណៈកម្មាធិការសម្របសម្រួល អន្តររដ្ឋាភិបាលកម្ពុជា-ចិន ដែលត្រូវបានបង្កើត ឡើងនៅឆ្នាំ២០១៤ ហើយត្រូវបានរៀបចំប្រជុំ ជារៀងរាល់ឆ្នាំ។ រហូតមកដល់ពេលនេះ កម្ពុជា និងចិន បានរៀបចំប្រជុំចំនួន៥លើករួចមកហើយ ដោយទទួលបានជោគជ័យ និងលទ្ធផលផ្លែផ្កា គួរឱ្យកត់សម្គាល់។ កិច្ចប្រជុំលើកទី៣ នៃគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី០៣ ដល់ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ នៅទីក្រុងប៉េកាំង។[71] កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន លើកទី៤ ប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ នៅខេត្តសៀមរាប ដែលបានលើកប្រធានបទសំខាន់ៗចំនួន៦វិស័យគឺ៖[72]

១-ពង្រឹងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ពិសេសផ្លូវល្បឿនលឿន ទៅខេត្តព្រះសីហនុ ផ្លូវដែក ផ្លូវទឹកនានា និងផ្លូវអាកាស ធ្វើយ៉ាងណាឱ្យមានការហោះហើរត្រង់ ពីចិនមកកម្ពុជា ដើម្បីនាំទេសចរចិនមកទស្សនាកម្ពុជាកាន់តែច្រើន ក៏ដូចជារួមគ្នាជំរុញផែនការ «ផ្លូវមួយខ្សែក្រវាត់មួយ» ដែលមានសារៈសំខាន់ សម្រាប់ភាពដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ កម្ពុជា-ចិន។

[71] "ឯកសារ ជំនួយស្មារតីពាក់ព័ន្ធនឹងសំណួរសម្រាប់បទសម្ភាសន៍ជាលាយលក្ខណ៍អក្សរជាមួយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាស្តីពីដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតីចិន និងទំនាក់ទំនងកម្ពុជា-ចិន" ចេញដោយទីស្តីការគណៈរដ្ឋមន្ត្រី

[72] Grand News, "លោក ហោ ណាំហុង នឹងលើកវិស័យសំខាន់ចំនួន៦ ក្នុងកិច្ចប្រជុំគណៈកម្មាធិការ សម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន លើកទី៤", ចុះផ្សាយថ្ងៃទី២២ មីនា ២០១៧

២- វិស័យថាមពល ភាគីកម្ពុជាស្នើទៅភាគីចិន ឱ្យបន្តជួយដល់កម្ពុជា ក្នុងការរៀបចំផែនការថាមពលប្រើពន្លឺព្រះអាទិត្យ ដែលមានតម្លៃថោក និងជាថាមពលស្អាត លើកទឹកចិត្តឱ្យសហគ្រាសចិន ចូលរួមកសាង និងពង្រឹងបណ្តាញថាមពលអគ្គិសនី នៅតាមទីជនបទ។

៣- វិស័យកសិកម្ម លោកនឹងស្នើសុំភាគីចិន ឱ្យបន្តជួយដល់កម្ពុជា បង្កើតផែនការអភិវឌ្ឍកសិកម្មបែបទំនើប និងបង្កើនកិច្ចសហប្រតិបត្តិការ ដំណាំងកៅស៊ូធម្មជាតិ អង្ករ ដំឡូងមី បន្លែ ពោត ផ្លែឈើជាដើម ព្រមទាំងបន្តជំរុញកិច្ចសហប្រតិបត្តិការ លើការចញ្ចឹមសត្វ និងនេសាទ ដើម្បីបង្កើនកម្រិតបច្ចេកវិទ្យាកសិ-ឧស្សាហកម្ម ដើម្បីនាំផលិតផលទាំងនោះ ចេញទៅលក់នៅបរទេស។

៤- ជំរុញពន្លឿនការសាងសង់កំពង់ផែ នៅខេត្តព្រះសីហនុ ដែលជាច្រមុះនៃការនាំចេញ និងនាំចូលទំនិញដ៏សំខាន់ និងលើកទឹកចិត្តដល់សហគ្រាសចិន ដើម្បីជាការជំរុញតំបន់សេដ្ឋកិច្ចពិសេស ខេត្តព្រះសីហនុ ឱ្យក្លាយជាទីតាំងសំខាន់ៗ សម្រាប់សហគ្រាសចិន ដែលធ្វើការវិនិយោគនៅកម្ពុជា។

៥- វិស័យវប្បធម៌ កម្ពុជាស្នើឱ្យមានការលើកទឹកចិត្ត ដល់ការធ្វើទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការវប្បធម៌ ដើម្បីលើកកម្ពស់ការយល់ដឹង និងការទទួលស្គាល់តម្លៃស្នូល នៃវប្បធម៌បុរាណ និងទំនើបរបស់កម្ពុជា និងចិន។

៦- ជំរុញឱ្យមានកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ ឱ្យបានគ្រប់ជ្រុងជ្រោយ ធ្វើយ៉ាងណាជំរុញឱ្យមានទេសចរចិនមកទស្សនាកម្ពុជា ឱ្យបាន២លាននាក់ នៅឆ្នាំ២០២០

កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន ថ្នាក់អគ្គលេខាធិការលើកទី៥ បានប្រព្រឹត្តទៅនាល្ងាចថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ ដែលធ្វើឡើងដើម្បីធ្វើការបូកសរុបលទ្ធផលការងារដែលសម្រេចបាន ក្នុងពេលកន្លងមក និងដើម្បីធ្វើការពិភាក្សាលើការអនុវត្ត តាមការសម្រេចរបស់ថ្នាក់ដឹកនាំកំពូល នៃប្រទេសទាំងពីរ នៅក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ទៅកាន់ប្រទេសចិន កាលពីខែមករា ឆ្នាំ២០១៩កន្លងទៅ និងត្រៀមរៀបចំសម្រាប់ដំណើរទស្សនកិច្ចរបស់ សម្តេចតេជោ ហ៊ុន សែន ទៅកាន់ប្រទេសចិននាពេលខាងមុខ ព្រមទាំងក៏ដើម្បីត្រៀមរៀបចំសម្រាប់កិច្ចប្រជុំផ្លូវការ នៃគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន លើកទី៥ផងដែរ។[73]

ក្នុងដំណើរទស្សនិច្ចរបស់ ឯកឧត្តម លី ខឺឈាង នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី១០-១១ ខែមករា ឆ្នាំ២០១៨ នៅកម្ពុជា និងជំនួបពិភាក្សារវាង សម្តេចតេជោនាយករដ្ឋមន្ត្រី ជាមួយថ្នាក់ដឹកនាំកំពូលនៃសាធារណរដ្ឋប្រជាមានិតចិន បានធ្វើឱ្យទំនាក់ទំនងមិត្តភាព និង

[73] Fresh News, "ក្រសួងសេដ្ឋកិច្ច និងក្រសួងការបរទេសចិន ប្រជុំគណៈកម្មាធិការសម្របសម្រួល អន្តររដ្ឋាភិបាលកម្ពុជា-ចិន ថ្នាក់អគ្គលេខាធិការលើកទី៥", ចុះផ្សាយថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩

កិច្ចសហប្រតិបត្តិការត្រូវបានពង្រឹងនិងពង្រីកកាន់តែខ្លាំងថែមទៀត។ ប្រការទាំងអស់នេះបានផ្តល់ជាមូលដ្ឋានយ៉ាងសំខាន់ ដល់ការរីកចម្រើនគួរឱ្យកត់សម្គាល់ជាបន្តបន្ទាប់ នៃទំនាក់ទំនងទ្វេភាគីនៅក្នុងវិស័យជាច្រើនដូចជា នយោបាយ សន្តិសុខ សេដ្ឋកិច្ច សង្គម និងវប្បធម៌ បានវិវត្តយ៉ាងខ្លាំង ក្នុងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ។ ទំនាក់ទំនងដែលបានវិវឌ្ឍនិងឆ្ពោះទៅមុខយ៉ាងឆាប់រហ័សដូចនេះ ពិសេសក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងយោធា បានធ្វើឱ្យមានការដាក់ចោទជាចម្ងល់ អំពីវត្តមាននៃមូលដ្ឋានយោធារបស់ចិននៅកម្ពុជាពីសំណាក់សហរដ្ឋអាម៉េរិកផងដែរ។ ការដាក់ការសង្ស័យខាងលើនេះ ក៏ដោយសារតែហេតុផលពីរគឺ ទី១.ការដាក់មន្ទិលសង្ស័យអំពីមូលដ្ឋានយោធាចិននៅកម្ពុជានេះ ក៏ដោយសារតែអាម៉េរិកបានពិនិត្យទៅលើយុទ្ធសាស្ត្ររបស់ចិន ដែលបានកំណត់ចេញក្នុងឆ្នាំ ២០០៥ ក្រោមឈ្មោះថា *ខ្សែកគុជខ្យង* ឬ *String Of Pearls* ដែលតាមរយៈយុទ្ធសាស្ត្រនេះ សហរដ្ឋអាម៉េរិកយល់ថា ចិនទំនងកំពុងតែខិតខំប្រឹងប្រែងពង្រីកឥទ្ធិពលរបស់ខ្លួន នៅតំបន់មហាសមុទ្រឥណ្ឌា តាមរយៈការរៀបចំបង្កើតបណ្តាញមូលដ្ឋានយោធាពីសមុទ្រចិនខាងត្បូង កាត់តាមមហាសមុទ្រឥណ្ឌា រហូតដល់តំបន់ដើមបូព៌ា។ ទី២.គេឃើញមានគម្រោងអភិវឌ្ឍដ៏ធំមួយកន្លែងរបស់ចិននៅក្នុងខេត្តកោះកុង ដែលក្នុងនោះរួមមានកំពង់ផែទឹកជ្រៅ អាកាសយានដ្ឋាន និងទីក្រុងរណបមួយនៅលើផ្ទៃដីទំហំប្រមាណ ៤៥០០០ហិកតា ប៉ុន្តែបញ្ហានេះគេត្រូវតែពិនិត្យមើលឱ្យបានច្បាស់លាស់អំពីរដ្ឋធម្មនុញ្ញកម្ពុជា ដែលបានហាមឃាត់ជាដាច់ខាតមិនអនុញ្ញាតឱ្យមានវត្តមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ក៏ដូចជាខចែងដែលមានក្នុងធម្មនុញ្ញរបស់អាស៊ានផងដែរ។ ទោះជាយ៉ាងណា បន្ទាប់ពីមានការបកស្រាយទាំងហេតុផលនយោបាយ និងមូលដ្ឋានច្បាប់ និងការបង្ហាញជំហររបស់ថ្នាក់ដឹកនាំកម្ពុជា តំណាងសហរដ្ឋអាម៉េរិកក៏បានបង្ហាញអំពីការសាទរនិងក្តីរីករាយ ចំពោះការបង្ហាញជំហរបែបនេះរបស់កម្ពុជាផងដែរ។

## ៤. កំណើននិងឥទ្ធិពលនៃការវិនិយោគ ពាណិជ្ជកម្ម និងទេសចរណ៍ចិនចំពោះកម្ពុជា

ក្នុងក្របខណ្ឌតំបន់ ប្រទេសចិនបានដាក់ចេញនូវគំនិតផ្តួចផ្តើម «ខ្សែក្រវាត់មួយ និងផ្លូវមួយ» បង្កើត «មូលនិធិផ្លូវសូត្រ» និង «ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី» ដើម្បីពង្រឹងភាពជាដៃគូ និងជំរុញការអភិវឌ្ឍបែប «ឈ្នះ-ឈ្នះ» រវាងប្រទេសក្នុងរង្វង់តំបន់ខ្សែក្រវាត់ និងផ្លូវសូត្រ តាមរយៈកិច្ចសហប្រតិបត្តិការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ស្ថាប័ន និងប្រជាជន វិស័យធុរកិច្ច ហិរញ្ញវត្ថុ វប្បធម៌ និងវិស័យគន្លឹះផ្សេងៗទៀត។

ប្រទេសចិនជាដៃគូពាណិជ្ជកម្ម និងវិនិយោគិនដ៏ចម្បងរបស់កម្ពុជា។ ទំហំពាណិជ្ជកម្មទ្វេភាគីក្នុងឆ្នាំ ២០១៧ មាន ចំនួន ៥.៥៧៧ លានដុល្លារអាម៉េរិក កើនឡើងជាង ២១,៧% បើធៀបនឹងឆ្នាំ ២០១៦។ ក្នុងឆ្នាំ ២០១៧ ទំហំវិនិយោគចិនសរុបនៅកម្ពុជាឈរលំដាប់លេខ ១ ធៀបនឹងទំហំវិនិយោគទុនពីប្រទេសដទៃទៀត ដែលមានទំហំសរុបប្រមាណ ១.៦៤៤ លានដុល្លារអាម៉េរិក ខណៈគិតត្រឹមដើមឆ្នាំ២០១៨ ទិន្នន័យពាណិជ្ជកម្មចិនបានបង្ហាញថាមានក្រុមហ៊ុនចិនជាង ២.០០០ បានដាក់ទុន

វិនិយោគនៅកម្ពុជា [74]។ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងចិន និងកម្ពុជា ក្នុងឆ្នាំ២០១៨ មានចំនួន ៧.០០៨ លានដុល្លារអាម៉េរិក កើនឡើងជិត១ពាន់លាន ធៀបនឹងឆ្នាំ២០១៧ ដែលមានចំនួន ៦០៤០លានដុល្លារ ក្នុងនោះ កម្ពុជានាំចេញទៅចិនត្រឹមចំនួន ៨៦៤លានដុល្លារ ខណៈនាំចូលពីចិនមកវិញទំហំ ៦១៨៤លានដុល្លារ។[75] ក្នុងឆ្នាំ២០១៩នេះ ទំហំពាណិជ្ជកម្មសរុបរវាងប្រទេសទាំងពីរ កើនឡើងដល់ចំនួន ៨,២ពាន់លានដុល្លារ ដែលកើនឡើងលើសឆ្នាំ២០១៨ ដល់ទៅប្រមាណ២៧ភាគរយ។[76] លើសពីនេះ ប្រទេសទាំងពីរក៏បានឯកភាពគ្នា ជំរុញទំហំពាណិជ្ជកម្មឱ្យកើនឡើងដល់ ៦.០០០ លានដុល្លារអាម៉េរិក នៅឆ្នាំ ២០២០។[77]

ចំពោះវិស័យទេសចរណ៍ មានក្រុមហ៊ុនអាកាសចរណ៍ចំនួន ១៥ កំពុងធ្វើប្រតិបត្តិការហោះហើរទៀងទាត់ រវាងកម្ពុជានិងចិន។ នៅឆ្នាំ ២០១៧ ទេសចរចិនមានប្រមាណ ១,២ លាននាក់ ដែលធ្វើឲ្យចិនក្លាយជាភ្ញៀវទេសចរអន្តរជាតិច្រើនជាងគេនៅកម្ពុជា វ៉ាដាច់ភ្ញៀវទេសចរជនជាតិវៀតណាមមកទស្សនាកម្ពុជា។ តាមការបញ្ជាក់នៅលើទំព័រហ្វេសបរបស់ក្រសួងទេសចរណ៍ ក្នុងឆ្នាំ ២០១៨ ប្រទេសកម្ពុជាទទួលបានភ្ញៀវទេសចរប្រមាណ ៦,២ លាននាក់ ដែលក្នុងនោះទេភ្ញៀវទេសចរចិនមានប្រមាណជា ១,៩ លាននាក់ ស្មើនឹង៣០ភាគរយនៃចំនួនទេសចរអន្តរជាតិ។ យោងតាមការចុះផ្សាយរបស់ក្រសួងទេសចរណ៍ នៅឆ្នាំ២០១៩នេះកម្ពុជាទទួលទេសចរអន្តរជាតិប្រមាណ ៦,៧ លាននាក់ ដែលស្មើនឹងកំណើន ៨% ក្នុងនោះទេសចរចិនមានប្រមាណជា ២,៥ លាន នាក់ ដែលកើនឡើងរហូតដល់ទៅ២៥% ប្រៀបធៀបនឹងឆ្នាំ២០១៨ [78] ។ កត្តាដែលជំរុញឱ្យភ្ញៀវទេសចរចិន មកកំសាន្តនៅកម្ពុជា កើនឡើងពីមួយឆ្នាំទៅមួយឆ្នាំនោះរួមមានដូចជា គោលដៅទេសចរណ៍វប្បធម៌ អេកូទេសចរណ៍ធម្មជាតិ និងទេសចរណ៍ក្នុងគោលដៅវិនិយោគជាដើម។

តាមការព្យាករណ៍របស់អង្គការទេសចរណ៍ពិភពលោក ចំនួនប្រជាជនចិន នៅក្នុងចំណោម១ពាន់លាននាក់ នឹងមាន៣០០លាននាក់ អាចមានលទ្ធភាពចេញធ្វើដំណើរកំសាន្តបានតួយ៉ាង នៅក្នុងឆ្នាំ២០១៩ ចំនួនប្រជាជនចិន ត្រូវបានអង្គការទេសចរណ៍ពិភពលោក បានព្យាករណ៍ថា ប្រជាជនចិន

[74] ភ្នំពេញប៉ុស្តិ៍, "ជនជាតិចិនខ្លះ ធ្វើឲ្យប៉ះពាល់វិនិយោគិនចិននៅកម្ពុជា", ចុះផ្សាយថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨

[75] ថ្មីៗ, "មន្ត្រីរដ្ឋាភិបាល៖ ការចរចាពាណិជ្ជកម្មសេរីជាមួយចិន មិនមែនដោយសាររឿង EBA នោះទេ", ចុះផ្សាយថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩

[76] ការលើកឡើងរបស់ ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី ជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៅក្នុងពិធីសម្ពោធមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជា (គុនមិញ) នាទីក្រុងគុនមិញ ខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន កាលពីពេលថ្មីៗកន្លងទៅ។

[77] សុន្ទរកថារបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្នុងពិធីជប់លៀងអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៦០ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា-ចិន

[78] ទំព័រហ្វេសប៊ុកផ្លូវការក្រសួងទេសចរណ៍, "បទយកការណ៍៖ ភ្ញៀវទេសចរចិន គឺកំណប់ទ្រព្យដ៏សំខាន់នៅក្នុងវិស័យទេសចរណ៍នៅកម្ពុជា", ចុះផ្សាយថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

អាចបានចេញធ្វើដំណើរកំសាន្តរហូតដល់ទៅ ១៥០ លាននាក់។[79] នេះមានន័យថា បច្ចុប្បន្នមានត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ នៃចំនួនប្រជាជនចិនដែលមានលទ្ធភាពអាចលទ្ធភាពធ្វើដំណើរកំសាន្តទាំង ៣០០លាននាក់ ដែលបានធ្វើដំណើរទេសចរណ៍ចេញក្រៅប្រទេស ហើយស្របពេលដែលសេដ្ឋកិច្ច និងទំហំផលិតផលសរុបប្រចាំឆ្នាំ(GDP) នៃប្រទេសមហាអំណាចអាស៊ីមួយនេះ កំពុងមានវឌ្ឍនភាពទៅមុខជាបន្តបន្ទាប់ នៅថ្ងៃអនាគតចំនួនប្រជាជនដែលនឹងចេញធ្វើដំណើរទេសចរណ៍ទៅកាន់ប្រទេសនានាលើពិភពលោកនឹងមានការកើនឡើងជាលំដាប់។ ក្នុងនោះប្រទេសកម្ពុជា ដែលជាប្រទេសមានសុខសន្តិភាព សុវត្ថិភាព មានគោលដៅទេសចរណ៍សំខាន់ៗជាច្រើនរាប់ទាំងទេសចរណ៍វប្បធម៌ ធម្មជាតិនិងបរិស្ថាន ពិសេសជាប្រទេសដែលមានទំនាក់ទំនងល្អរវាងគ្នាទាំងផ្នែកនយោបាយនិងសេដ្ឋកិច្ចនឹង«ទទួលបានបាននូវភ្ញៀវទេសចរកាន់តែច្រើនជាលំដាប់ ដែលការណ៍នេះវានឹងចាក់បំពេញបន្ថែមទៅក្នុងចរន្តសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើតការងារ មុខរបរ និងផ្តល់វឌ្ឍនភាពដល់វិស័យពាក់ព័ន្ធដទៃផ្សេងទៀត។ ហេតុនេះ កម្ពុជាត្រូវជំរុញការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយអំពីសក្តានុពលវិស័យទេសចរណ៍របស់ខ្លួន ហើយនិងត្រៀមរៀបចំខ្លួនឱ្យបានរួចរាល់សម្រាប់ទទួលយកនូវអ្នកទេសចរចិនដ៏ច្រើនសន្ធឹក ដែលនឹងមកធ្វើដំណើរកំសាន្តនៅក្នុងប្រទេសរបស់ខ្លួន ក្នុងនោះរួមមានការពង្រឹងនូវក្រមប្រតិបត្តិវិជ្ជាជីវៈទេសចរណ៍ ការរៀបចំនូវផលិតផលកសិកម្មនិងកសិឧស្សាហកម្ម សម្រាប់ផ្គត់ផ្គង់ដល់ការហូបចុករបស់ភ្ញៀវទេសចរ ការរៀបចំមធ្យោបាយសម្រាប់ ការធ្វើដំណើរកំសាន្ត ការពង្រីកបង្កើន និងធ្វើពិពិធកម្មរមណីយដ្ឋាននិងគោលដៅទេសចរណ៍ ការត្រៀមផលិតវត្ថុអនុស្សាវរីយ៍តាមរយៈការជំរុញដល់សិប្បកម្មនិងឧស្សាហកម្មផលិតក្នុងស្រុក និងការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យបដិសណ្ឋារកិច្ច និងមគ្គុទេសក៍ទេសចរណ៍ជាដើម។

[79] ទំព័រហ្វេសប៊ុកផ្លូវការក្រសួងទេសចរណ៍, "បទយកការណ៍៖ ភ្ញៀវទេសចរចិន គឺកំណប់ទ្រព្យដ៏សំខាន់នៅក្នុងវិស័យទេសចរណ៍នៅកម្ពុជា", ចុះផ្សាយថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

# សន្និដ្ឋាន

ទំនាក់ទំនងកម្ពុជា-ចិន គឺជាទំនាក់ទំនងជាយុទ្ធសាស្ត្រមួយ ដែលកើតចេញនិងរីកចម្រើនឡើងជាលំដាប់ដោយកត្តាប្រវត្តិសាស្ត្រ ភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច ហើយក៏ជាកត្តាដែលទាញភ្ជាប់ប្រទេសទាំងពីរឱ្យខិតរកគ្នាផងដែរ។ គេអាចនិយាយបានថា សម្តេចព្រះនរោត្តមសីហនុ សម្តេចព្រះបរមរតនកោដ្ឋគឺជាស្ថាបនិកនៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ ហើយសម្តេចតេជោ ហ៊ុន សែន គឺជាអ្នកបន្តនិងជំរុញបង្កើននូវទំនាក់ទំនងក្នុងភាពជាដៃគូល្អបន្ថែមទៀតរវាងប្រជាជាតិទាំងពីរ កម្ពុជា-ចិន។ ហើយការណ៍ដែលមានការរីកចម្រើនជាលំដាប់នេះ មិនអាចកាត់ផ្តាច់បានឡើយ នូវផលប្រយោជន៍នយោបាយ ដែលចិនបានកំណត់យ៉ាងច្បាស់អំពីគោលការណ៍នៃទំនាក់ទំនងការទូតជាមួយខ្លួន ប្រទេសជាដៃគូត្រូវតែគោរពនូវ «នយោបាយចិនតែមួយ»។ ក្រៅពីផលប្រយោជន៍នៃការគាំទ្រនយោបាយចិនតែមួយ កម្ពុជាគឺជាច្រកការទូតយ៉ាងសំខាន់មួយទៅកាន់អាស៊ាន សម្រាប់ចិន ដែលមានបំណងចូលខ្លួនក្នុងសមាហរណកម្មតំបន់ និងជ្រៀតឥទ្ធិពលចូលក្នុងនាមជាមហាអំណាចតំបន់ ក៏ដូចជាពិភពលោក។ ជាមួយគ្នានោះ គេក៏មិនអាចមើលរំលងឡើយអំពី តួនាទីសំខាន់របស់កម្ពុជាក្នុងការសម្របសម្រួលជម្លោះសមុទ្រចិនខាងត្បូង ដែលកម្ពុជាសម្រេចបាននូវសេចក្តីប្រកាសស្តីពីការប្រតិបត្តិសម្រាប់ភាគីជម្លោះក្នុងសមុទ្រចិនខាងត្បូង ក្នុងកិច្ចប្រជុំកំពូលអាស៊ាននៅឆ្នាំ២០០២។ លើសពីនេះទៅទៀត តាមរយៈទំនាក់ទំនងល្អជាមួយកម្ពុជា ចិនក៏ទទួលបាននូវសម្លេងគាំទ្រមួយក្នុងឋានៈកម្ពុជាជាសមាជិកនៃស្ថាប័នអន្តរជាតិ កិច្ចប្រជុំថ្នាក់តំបន់ និងកិច្ចសហប្រតិបត្តិការនានាដូចជា អង្គការសហប្រជាជាតិ អាស៊ាន កិច្ចប្រជុំអាស៊ានបូក៣ កិច្ចប្រជុំអាស៊ាន-ចិន កិច្ចប្រជុំអាស៊ីបូព៌ា កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាន វេទិកាសភាអាស៊ីប៉ាស៊ីហ្វិក គំនិតផ្តួចផ្តើម «ខ្សែក្រវាត់មួយ និងផ្លូវមួយ» និង «ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី» ជាដើម-ល-។ ចំណែកសម្រាប់កម្ពុជា ផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិន បានផ្តល់ឱ្យកម្ពុជានូវផលប្រយោជន៍ជាយុទ្ធសាស្ត្រ ក្នុងនាមចិនជាមហាអំណាចតំបន់និងពិភពលោក ពិសេសគឺផលប្រយោជន៍សេដ្ឋកិច្ចតាមរយៈជំនួយ និងការវិនិយោគដ៏ច្រើនសន្ធឹកសន្ធាប់។ ទំនាក់ទំនងកម្ពុជា-ចិនក្នុងសតវត្សរ៍ទី២១ គឺជាទំនាក់ទំនងជាយុទ្ធសាស្ត្រភូមិសាស្ត្រនយោបាយផង ជាទំនាក់ទំនងក្នុងនាមជាដៃគូគាំទ្រគ្នាទៅវិញទៅមកផង និងជាទំនាក់ទំនងសេដ្ឋកិច្ចស៊ីជម្រៅផងដែរ។

ទោះជាយ៉ាងណាក្តី កម្ពុជាដែលកំពុងស្ថិតនៅលើផ្លូវអភិវឌ្ឍរបស់ខ្លួន ត្រូវការជាចាំបាច់នូវការចូលរួមជ្រោមជ្រែងអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ពីបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនលើវិស័យជាច្រើនផ្សេងទៀត។ ការអនុវត្តនយោបាយការបរទេសចម្រុះពណ៌របស់រាជរដ្ឋាភិបាលកម្ពុជា គឺជាការជ្រើសរើសផ្លូវដ៏ត្រឹមត្រូវមួយ ដែលកម្ពុជាមិនអាចទោរទន់ឬផ្អែកទាំងស្រុងទៅលើមហាអំណាចណាមួយ ហើយប្រឈមមុខទៅនឹងមហាអំណាចណាមួយនោះឡើយ។ អ្វីដែលកម្ពុជាត្រូវធ្វើនៅពេលនេះគឺ ការទាក់ទាញវិនិយោគទុនបរទេសតាមរយៈការធានាបាននូវសន្តិសុខ សន្តិភាព និងការអនុវត្តគោលការណ៍លើកទឹកចិត្តវិនិយោគទុន, ព្រមទាំងបន្តទំនាក់ទំនងល្អជាមួយនឹងបណ្តាប្រទេសនានា ពិសេសមហា

អំណាច ប្រទេសមានការរីកចម្រើនសេដ្ឋកិច្ចខ្ពស់ និងប្រទេសជិតខាងកម្ពុជា ប៉ុន្តែជាការពិតប្រាកដណាស់ ភាពចាំបាច់បំផុត ដែលត្រូវរក្សាឱ្យបាននោះគឺ ឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជា ដែលត្រង់ចំណុចនេះ គឺជាដើមទុនសម្រាប់កម្ពុជា បន្តទំនាក់ទំនងប្រកបដោយមិត្តភាពស្មើមុខមាត់ និងអាចរក្សាសិទ្ធិស្វ័យសម្រេចចិត្តខាងផ្នែកនយោបាយ និងការទូតប្រកបដោយឆន្ទៈ និងការតម្កល់ឧត្តមប្រយោជន៍ជាតិជាអាទិភាព។ លើសពីនេះទៅទៀត សម្រាប់ទិដ្ឋភាពផ្ទៃក្នុង កម្ពុជាមានភាពចាំបាច់ខ្លាំងក្នុងការដោះស្រាយនិងពង្រឹងនូវសមត្ថភាពផ្ទៃក្នុងរបស់ខ្លួនឯង តាមរយៈការបន្តធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈឱ្យមានប្រសិទ្ធភាពខ្ពស់និងប្រកបដោយតម្លាភាព ការពង្រឹងការកសាងធនធានមនុស្ស ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការលុបបំបាត់ភាពអយុត្តិធម៌ក្នុងសង្គម ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ កាត់បន្ថយគម្លាតនៃភាពក្រីក្រ ការលើកទឹកចិត្តដល់ការវិនិយោគក្នុងស្រុក ការពង្រឹងនូវមូលដ្ឋានបម្រើដល់សង្វាក់ផលិតកម្មនៅក្នុងស្រុក ការជំរុញបង្កើនលទ្ធភាពប្រមូលចំណូលពីពន្ធដារនិងពន្ធគយ និងពង្រីកនិងបង្កើតនូវលទ្ធភាពស្វែងរកប្រភពចំណូលបន្ទាប់បន្សំផ្សេងៗទៀតជាដើម៕

# គន្ថនិទ្ទេស


1. https://opendevelopmentcambodia.net/km/topics/chinese-aid/#ref-96513-2
2. គេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
3. http://www.reuters.com/article/2013/04/10/us-cambodia-china-idUSBRE93909D20130410
4. http://china.aiddata.org/
5. http://cdc.khmer.biz/projectlist/project_list_updated.asp?OtherDonor=29&status=0&UpdateFrom=1/1/2016&updateto=3/20/2016
6. https://kohsantepheapdaily.com.kh/article/712854.html
7. https://www.postkhmer.com/សេដ្ឋកិច្ច/lyp-គ្រោងសង់ទីក្រុងចិនមួយនៅកម្ពុជា
8. https://khmer.voanews.com/a/china-backed-us-3-8-billion-project-at-koh-kong-is-emerging-as-a-closed-economy-exclusively-for-chinese-workers-capitalists-and-visitors-/4425993.html
9. https://www.cpp.org.kh/details/119503
10. https://www.dap-news.com/archives/37663
11. http://km.rfi.fr/cambodia/new-high-way-from-PP-to-KPS-22-03-2019
12. https://mod.gov.kh/posts/213
13. https://www.cpp.org.kh/details/10135
14. http://km.rfi.fr/china-military-aids-to-cambodia
15. http://peoplenews.asia/39964/
16. https://www.postkhmer.com/ព័ត៌មានជាតិ/កងទ័ពកម្ពុជា-ចិន-បញ្ចប់សមយុទ្ធនាគមាសឆ្នាំ-២០១៨-ជោគជ័យដោយបង្ហាញទំនាក់ទំនងយោធារឹងមាំ
17. https://www.postkhmer.com/ព័ត៌មានជាតិ/លោក-ហ៊ុន-សែន-អះអាងពីសព្វាវុធដែលត្រូវបានដឹកមកដល់កម្ពុជា-ដើម្បីការពារជាតិ
18. http://km.rfi.fr/cambodia-Cambodia-China-Exercise-10-03-2019
19. https://www.postkhmer.com/ព័ត៌មានជាតិ/លំហាត់នាគមាសកងទ័ពកម្ពុជា-ចិន-បានចាប់ផ្ដើមជាផ្លូវការនៅខេត្តកំពត
20. https://www.dap-news.com/archives/52530
21. https://www.dap-news.com/archives/53277
22. https://www.mod.gov.kh/posts/785
23. https://grandnewsasia.com/detail/24803/
24. http://km.rfi.fr/cambodia/desk-somnop-cambodia-china-xi-jinping-visit-15-10-2016
25. https://thmeythmey.com/?page=detail&id=85276

26. https://bizkhmer.com/articles/75102
27. https://cambonomist.com/news/more-chinese-tourist-comes-to-cambodia-/
28. https://www.facebook.com/cambodia.tourism.ministry/
29. https://Pressocm.gov.kh